ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ សិទ្ធិនារីៈ សិទ្ធិរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាស្ត្រីក្នុងការទទួលបានសេវាសុខភាព និងសង្គម

◆ ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៧៩ ខែមីនា ឆ្នាំ២០២៣

ស្វែងរកការពិត

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៧៩ ខែមីនា ឆ្នាំ២០២៣



ដូនជីនៅវត្តលង្កា ក្រុងភ្នំពេញ មកទទួលសេវាពិនិត្យសុខភាពបឋមដោយឥតគិតថ្លៃរៀបចំដោយក្រុមការងារគម្រោង "ការលើកកម្ពស់សិទ្ធិនិងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម"។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា


### សំបុត្រ

- សិទ្ធិនារី៖ សិទ្ធិរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ........................ ១

### ផ្នែកឯកសារ

- អ៊ុល ហាំ៖ កងស៊ើបការណ៍សម្ងាត់ ........ ៣

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

- ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវ................. ៥
- ការអប់រំពីបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតែសំខាន់... ៩
- និស្សិតវិទ្យាសាស្ត្រសុខាភិបាល មកពីសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាល មូស្លីម ...១១
- កិច្ចសំណេះសំណាលជាមួយ ដូនជី តាជី និងប្រជាជនចំណុះជើងវត្តស្លូនពេជ្រ .......... ១៣
- មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលប័ណ្ណ.... ១៥
- ដំណើរទស្សនកិច្ចសិក្សាស្តីពី សន្តិភាព និងសិទ្ធិមនុស្ស ................................១៧
- អតីតកម្មាភិបាលខ្មែរក្រហម បង្រៀនចៅ .. ២០
- ហែម ហឿន៖ កងដឹកជញ្ជូនត្រីពីបឹង .....២៥
- ឡុក អូន កងចល័តលើកទំនប់ម្ចិប........ ២៨

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

- សិស្សនៃវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន សង្កើប ចូលរួមវេទិកាថ្នាក់រៀន .......... ៣០
- វេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩).... ៣៣
- សិស្សានុសិស្សវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ .. ៣៧
- សិស្សានុសិស្សមកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ ចូលរួមវេទិកាថ្នាក់រៀនចុង ...... ៤១
- មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំសិក្ខាសាលា «ការអប់រំអំពីសុខភាព»..................... ៤៥
- ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌល .......៥២
- យុវជនមកពីឃុំជាំ និងឃុំចាន់មូល ស្រុកមេមត់ រៀនសូត្រ អំពីប្រព័ន្ធសន្តិសុខ ក្នុងរបប... ៥៤
- យុវនារីវ័យក្មេង រួមចំណែកដល់ការប្រារព្ធសិទ្ធិនារី ៨ មីនា តាមរយៈការរំពុក .......... ៥៧

### ផ្នែកស្រាវជ្រាវរកគ្រួសារ

- «**ទួលពិឃាដ**» (ត) .......................... ៦១



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ៖** សូ ហ្វារីណា, សួត វិចិត្រ, លីម អ៊ុភីង, ជ័យ ចាន់ស៊ីណេត, គីម សុវណ្ណដានី, សោម ប៊ុនថន, មេក វិន, ផេង ពង្សរ៉ាស៊ី, ដារ៉ារដ្ឋ មេត្តា, ផាត ពន្លក, ទូច វណ្ណេត, លី ដេវីត, ឡុង ដានី, វី ស៊ីថា, ថុន ស្រីពេជ្រ និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ុភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង


Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# សិទ្ធិនារីៈ សិទ្ធិរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

## ជាស្ត្រីក្នុងការទទួលបានសេវាសុខភាព និងសង្គម

*សូ ម៉ារីណា*



នៅព្រឹកថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាចុះសួរសុខទុក្ខ និងពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន១៤នាក់ នៅក្នុងសាលាបុណ្យវត្តលង្កា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាស្ត្រី មានសិទ្ធិក្នុងការទទួលបានការថែទាំសុខភាព និងសេវាសង្គម ហើយនេះគឺជាសំណងដោយផ្ទាល់ បន្តិចបន្តួច សម្រាប់អ្នករស់រានមានជីវិតជាស្ត្រី បន្ទាប់ពីការទទួលរងគ្រោះក្រោមរបបខ្មែរក្រហម និងបានលះបង់ក្នុងការស្តារនិងអភិវឌ្ឍន៍សង្គមជាតិ និងគ្រួសារ។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាស្ត្រី មានជាង៦០ភាគរយ នៃអ្នករស់រានមានជីវិតទូទៅ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ ក្នុងចំណោមតួលេខនេះ មួយចំនួនគឺជាស្ត្រីមេម៉ាយៗ ស្ត្រីបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងសង្គមឡើងវិញ ទន្ទឹមនឹងការខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់កូនៗឲ្យបានធំធាត់។ ស្ត្រីមានពេលវេលា និងលទ្ធភាពតិចតួច ក្នុងការថែទាំសុខភាពរបស់ខ្លួន

ដោយសារបញ្ហាជីវភាពនិងការតព្វកិច្ចដែលត្រូវបំពេញ។

នៅពេលដែលវ័យរបស់គាត់កាន់តែចាស់ និងស្ថិតក្រោមស្ថានភាពលំបាក ស្ត្រីមួយចំនួនបានចូលមកជ្រកកោន និងចាត់ទុកវត្តអារាម ដូចជា ផ្ទះរបស់គាត់ ហើយបួសជាដូនជីនៅទីនោះ។ វត្តអារាមមិនត្រឹមតែជាទីកន្លែងសក្ការៈ និងទីដែលគាត់អាចសន្សំកុសល ដើម្បីភាពស្ងប់សុខប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យគាត់អាចបន្ធូរអារម្មណ៍តានតឹងបាន។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រីដែលជាយាយជី កាលពីព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារបានចុះទៅសាកសួរសុខទុក្ខយាយជីចំនួន ១៨នាក់នៅវត្តលង្កា ដោយបានណែនាំវេជ្ជបណ្ឌិតជនជាតិហ្វីលីពីន ឈ្មោះថា ដេមី រ៉ៃយ៍ ដែលមានបទពិសោធន៍វះកាត់ជំងឺមហារីកនិងព្យាបាលជំងឺទូទៅជាច្រើនឆ្នាំ ដើម្បីធ្វើការប្រឹក្សាយោបល់អំពីផ្នែកសុខភាពដល់លោកយាយជីនៅទីនោះ។ សេវាកម្មដែលផ្តល់ជូនរួមមាន ការផ្តល់ការពិនិត្យសុខភាពបឋម ដូចជា ការវាស់កម្រិតស្ករក្នុងឈាម សម្ពាធឈាម ចង្វាក់បេះដូង និងការពិនិត្យទូទៅ។ ជាលទ្ធផល ខណៈដែលយាយជីមួយចំនួនមានសុខភាពល្អធម្មតា យាយជីមួយចំនួនតូចមានកម្រិតជាតិស្ករ និងសម្ពាធឈាមខ្ពស់ ហើយយាយជីមួយចំនួនទៀតកំពុងប្រើប្រាស់ថ្នាំព្យាបាលជំងឺលើសឈាម ជំងឺទឹកនោមផ្អែម និងជំងឺបេះដូង។ ទោះបីជាមានបញ្ហាសុខភាពដូចមានរៀបរាប់ខាងលើ យាយជីដែលទទួលបានការពិគ្រោះ មានវិធីគ្រប់គ្រងស្ថានភាពសុខភាពរបស់ខ្លួនបានល្អ។ វេជ្ជបណ្ឌិត ដេមី រ៉ៃយ៍ បានណែនាំដល់យាយជីឲ្យមានការតាមដានសុខភាពរៀងរាល់៣ខែម្តង។

វត្តមានរបស់ក្រុមការងារ រួមទាំងការនាំយកសេវាកម្មសុខភាពមកដល់ទីតាំងផ្ទាល់ កាន់តែធ្វើឲ្យផ្ទះរបស់គាត់កាន់តែមានភាពកក់ក្តៅ និងជួយឲ្យយាយជីចេះថែទាំសុខភាពកាន់តែប្រសើរ។ ការយល់ដឹងនិងការថែទាំសុខភាព អាចជួយឲ្យគាត់មានសុខភាពល្អ ដើម្បីបញ្ចេញសមត្ថភាពជាស្ត្រីគំរូក្នុងការចែករំលែកបទពិសោធន៍ដល់មនុស្សជំនាន់នេះ និងជំនាន់ក្រោយ។ កិច្ចការបន្តិចបន្តួចនេះ ត្រូវបានមើលឃើញថា មានអត្ថន័យពិសេសសម្រាប់អ្នករស់រានជីវិតពីរបបខ្មែរក្រហម។ ការផ្តល់ជូននូវសេវាសុខភាពនិងសង្គមដល់ស្ត្រីដែលជាអ្នករស់រានមានជីវិតទៀតសោត គឺជាការឆ្លើយតបទៅនឹងសិទ្ធិក្នុងការទទួលបានការថែទាំសុខភាពនិងសេវាសង្គម និងចូលរួមចំណែកដើម្បីធ្វើឲ្យការប្រារព្ធទិវាសិទ្ធិស្ត្រីឆ្នាំនេះកាន់តែមានអត្ថន័យជ្រាលជ្រៅ។





នៅព្រឹកថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាចុះសួរសុខទុក្ខ និងពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន១៨នាក់ នៅក្នុងសាលាបុណ្យវត្តលង្កា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ុល ហាំ ៖ កងស៊ើបការណ៍សម្ងាត់ សេ-អ៊ី-អា នៅតំបន់៥ ភូមិភាគពាយ័ព្យ

**សួគ ខិចិត្រ**



កម្មាភិបាលខ្មែរក្រហមនៅតាមមន្ទីរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ុល ហាំ មានអាយុ២៨ឆ្នាំនៅក្នុងឆ្នាំ១៩៧៧ មានទីកន្លែងកំណើតនៅក្នុងឃុំចន្ទាសដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប ស្ថិតនៅតំបន់១០៦ ភូមិភាគឧត្តរ។

នៅឆ្នាំ១៩៦៨ ខ្ញុំចាកចេញពីឪពុកម្ដាយហើយទៅរស់នៅក្នុងវត្តស្នួល អស់រយៈពេលមួយឆ្នាំ។ បន្ទាប់មក ខ្ញុំក៏បានវិលត្រឡប់ទៅរស់នៅជួបជុំក្រុមគ្រួសារវិញរហូតដល់ខ្ញុំធំដឹងក្តី។

ក្រោយមកនៅឆ្នាំ១៩៧២ ខ្ញុំបានចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហមនៅក្នុងកងអន្តភាពលេខ១០៥ តំបន់៥ ភូមិភាគពាយ័ព្យ ដោយមានតួនាទីគឺជាអ្នកកាន់ផ្នែកសេដ្ឋកិច្ច។ រយៈពេលពីរខែក្រោយមក ខ្ញុំផ្លាស់ទៅកាន់អន្តភាពលេខ១០៩ក្រោមការគ្រប់គ្រងរបស់ ធន ដោយធ្វើការចុះពិនិត្យពីស្ថានភាពរបស់ប្រជាជននៅក្នុងស្រុកស្រីស្នំ ខេត្តសៀមរាប។ ធន បានណែនាំឲ្យខ្ញុំចូលរួមទៅក្នុងចលនាបំផុសបំផុលប្រជាជនក្នុងមូលដ្ឋានជាមួយនឹងខ្សែ សេ-អ៊ី-អា។

ធន បាត់តាំងខ្ញុំធ្វើការទំនាក់ទំនងជាមួយនឹងឈ្មោះ គឿន គឺជាអតីតសិស្សរៀននៅសាលាបាត់ដំបង ដើម្បីឲ្យដឹងពីសភាពការណ៍ផ្សេងៗរបស់កងទ័ពបដិវត្តន៍ខ្មែរក្រហម។ គឿន ផ្តល់ដំណឹងមកខ្ញុំថា យើងត្រូវរាយការណ៍ឲ្យកងយន្តហោះរបស់លន់ នល់មកទម្លាក់គ្រាប់បែកនៅភូមិរំលំស្វាយ ស្រុកក្រឡាញ់ខេត្តសៀមរាប។ មួយថ្ងៃក្រោយមកយន្តហោះស្លាបកាត់ចំនួន២គ្រឿងក៏បានទៅទម្លាក់គ្រាប់បែកនៅទីនោះមែន ដោយបានសម្លាប់ប្រជាជនអស់មួយចំនួន។ នៅពេលនោះ ធន បញ្ជូនខ្ញុំនិង គឿន ឲ្យស្វែងរកមន្ទីរបដិវត្តន៍របស់ខ្មែរក្រហម ដើម្បីទម្លាក់គ្រាប់

បែកបន្តទៀត។

លុះដល់ចុងឆ្នាំ១៩៧៣ ខ្ញុំបន្តស៊ើបការណ៍នៅក្នុងភូមិសសៃពង ស្រុកក្រឡាញ់ ខេត្តសៀមរាប និងរាយការណ៍ឲ្យយន្តហោះទៅទម្លាក់គ្រាប់បែកនៅទីនោះ ដែលបណ្ដាលឲ្យកងទ័ពខ្មែរក្រហមចំនួន ៣នាក់ ស្លាប់បាត់បង់ជីវិត។

រហូតដល់ខែមេសា ឆ្នាំ១៩៧៤ ខ្ញុំបន្តធ្វើសកម្មភាពបំផុសបំផុលឲ្យយុទ្ធជនចាកចេញពីកងអង្គភាពលេខ១០៩ ទៅកាន់ផ្ទះរបស់ខ្លួនអស់ចំនួន ២នាក់និង ១នាក់ទៀតរត់ទៅតំបន់ខ្ទាំង ព្រមទាំងធ្វើសកម្មភាពបន្ទុចបង្អាក់ទៅលើផែនការរបស់ខ្មែរក្រហម។ នៅក្នុងឆ្នាំដដែលនោះ អង្គភាពរបស់ខ្ញុំក៏បានផ្លាស់ខ្ញុំទៅកាន់ស្រុកថ្មពួក ខេត្តបាត់ដំបង ដោយភ្ជាប់មកជាមួយនូវសំបុត្រមួយច្បាប់ទៅកាន់ ឌុន គឺជាភ្នាក់ងារសេ-អ៊ី-អា ចាស់នៅតំបន់ខ្ទាំង ដើម្បីបន្តខ្សែរយៈក្នុងដើរបំផុសបំផុលប្រជាជន និងកងទ័ព នៅក្នុងអង្គភាពមួយចំនួនទៀត។

រហូតដល់ខែកក្កដា ឆ្នាំ១៩៧៤ ខ្ញុំបានទាក់ទងជាមួយនឹងខ្សែរយៈសេ-អ៊ី-អា ចំនួន៦នាក់ទៀតដើម្បីពង្រីកកម្លាំង និងបន្តសកម្មភាពរបស់ខ្លួន ដោយក្រោយមក ខ្ញុំរៀបចំផែនការកម្ទេចកងកម្លាំងបដិវត្តន៍ខ្មែរក្រហមដោយរាយការណ៍ឲ្យមានការទម្លាក់គ្រាប់បែកទៅលើភូមិត្រពាំងថ្ម។ កងទ័ពខ្មែរក្រហមចំនួន ៦នាក់បានស្លាប់បាត់បង់ជីវិត និង៤នាក់ផ្សេងទៀតទទួលរងរបួស។ ក្នុងហេតុការណ៍នេះ ខ្ញុំបានបញ្ជូនកម្លាំងក្បត់ សេ-អ៊ី-អា ចំនួន២នាក់ដើម្បីដាក់មីនទៅលើកងកម្លាំងថ្មើរជើងនៅក្នុងភូមិជ្រាប់ ស្រុកព្រះនេត្រព្រះ ដោយបានសម្លាប់កងទ័ពខ្មែរក្រហមចំនួន ៥នាក់ទៀត។

លុះដល់ចុងឆ្នាំ១៩៧៤ ខ្ញុំរាយការណ៍ទៅកាន់ គឿន និង យ៉ាន អំពីសភាពការណ៍របស់កងទ័ពខ្មែរក្រហមនៅខាងកើតភូមិភាស់ និងបញ្ជូនគោលដៅឲ្យយន្តហោះទៅទម្លាក់គ្រាប់បែកនៅទីនោះ។ មនុស្សចំនួន ៩នាក់ បានស្លាប់ និងកុមារចំនួន ១នាក់ ទៀតបានទទួលរងរបួស។

រហូតដល់ខែមករា ឆ្នាំ១៩៧៥ ខ្ញុំពិភាក្សាជាមួយនឹងកងស៊ើបការណ៍សម្ងាត់របស់ សេ-អ៊ី-អា ម្ដងទៀតដើម្បីកម្ទេចកងកម្លាំងបដិវត្តន៍ខ្មែរក្រហម នៅត្រង់ភូមិស្វាយចេក ស្រុកថ្មពួក ខេត្តបាត់ដំបង ដែលបណ្ដាលឲ្យកងទ័ពខ្មែរក្រហមប្រមាណជាចំនួន១៨នាក់បានស្លាប់ និង ៣២នាក់ទៀតទទួលរងរបួស។ ដល់ខែឧសភា ខ្ញុំផ្លាស់ប្ដូរទៅកាន់កងអង្គភាពទ័ពភាគ វរសេនាតូចលេខ៤១៥ វរសេនាធំលេខ ៤០ កងពលទី១ នៃភូមិភាគពាយ័ព្យវិញ ដោយមានតួនាទីជាអនុសេនាធំ នៅក្នុងកងវរសេនាតូចលេខ ៤១៥។ នៅពេលនោះ ហ៊ីង គឺជាគណៈតំបន់ ៥ ណែនាំឲ្យខ្ញុំធ្វើសកម្មភាពបំផុសបំផុលក្នុងជួរកងទ័ពបន្តទៀតជាមួយនឹងខ្សែ សេ-អ៊ី-អា។ ខែសីហា យើងរៀបចំផែនការទំនាក់ទំនងជាមួយកងទ័ពសៀម និងកងកម្លាំងទ័ព អ៊ិនតាំ តាមរយៈចាប់ប្រជាជនខ្មែរណាដែលខស្បាហ៍ចេញ-ចូលទៅក្នុងប្រទេសសៀមឲ្យនាំផ្លូវយើងទៅជួបនឹងកងកម្លាំងរបស់ អ៊ិនតាំ។ ក្រោយមកយើងភ្ជាប់ទំនាក់ទំនងជាមួយនឹងកងកម្លាំងរបស់អ៊ិនតាំ បានជោគជ័យ និងណាត់ជួបគ្នានៅម្ដុំបង្គោលឡាក់លេខ៣៥។ម៉្យាងទៀតកងកម្លាំងរបស់ខ្ញុំ ធ្វើការជួបជាមួយនឹងកងទ័ពរបស់អ៊ិនតាំ នៅផ្លូវគោកខ្សុង ផ្លូវបង្គោល ឡាក់លេខ៣៧ដែរ។

រហូតដល់ឆ្នាំ១៩៧៦ កងកម្លាំងរបស់ខ្ញុំស្វែងរកជំនួយគាំទ្រពីកងកម្លាំងរបស់ អ៊ិនតាំ នៅក្នុងទឹកដីសៀម ទាំងផ្នែកសព្វាវុធ,ស្បៀងអាហារ សំល្លៀកបំពាក់ និងការឃោសនាដទៃផ្សេងទៀតដើម្បីពង្រីកកម្លាំង និងវាយប្រហារពីចំណុចមិនល្អរបស់មេដឹកនាំខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា។ ក្រោយមកដោយសារមានជំនួយមួយចំនួន កងកម្លាំងរបស់យើងបានបន្តសកម្មភាព ដើម្បីបំផុសបំផុលប្រជាជននៅតាមសហករណ៍ រហូតដល់កងទ័ពបដិវត្តន៍ខ្មែរក្រហមចាប់ខ្លួនខ្ញុំនៅក្នុងខែកក្កដា ឆ្នាំ១៩៧៧។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ AVDC-CAM0869។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ អ៊ុល ហាំ ពិតប្រាកដយ៉ាងណានោះទេ?***

# ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិនិត្យសុខភាពបឋមជូនដល់អ្នករស់រានមានជីវិតពីខ្មែរក្រហមនៅភូមិបាក់នឹម

***លីម អ៊ិគីង និង ឌ័យ ចាន់ស៊ីណោត***









ប្រជាជននៅភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត មកពិនិត្យសុខភាពដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ទីក្រុង និងទីប្រជុំជនភូមិទាំងមូលគឺគ្មានប្រជាជនឡើយ។ ភូមិបាក់នឹម គឺជាភូមិជនបទតូចមួយដែលបានទទួលការជម្លៀសដោយបង្ខំដោយខ្មែរក្រហម។ អ្នកភូមិជាច្រើនត្រូវបានទទួលរងនូវពលកម្មដោយបង្ខំ ការអត់ឃ្លាន និងទម្រង់ផ្សេងទៀតនៃការរំលោភបំពាន។ ប្រជាពលរដ្ឋ ចាស់ជរា នៅភូមិបាក់នឹម នៅតែរស់នៅជាមួយការចងចាំដែលនៅតែលងបន្លាចពីរបបខ្មែរក្រហម រួមទាំងការបាត់បង់សមាជិកគ្រួសារ ពលកម្មដោយបង្ខំ និងការអត់ឃ្លាន។ ទោះបីជាពេលវេលាកន្លងផុតទៅក៏ដោយ ក៏ការចងចាំនៃ

របបខ្មែរក្រហមនៅតែបន្តប៉ះពាល់ដល់ជីវិត និងសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនេះ ក្រុមគ្រួសាររបស់ពួកគាត់ និងអ្នកផ្សេងទៀតនៅក្នុងភូមិ ដែលបានឆ្លងកាត់រយៈពេលដ៏ឈឺចាប់នៅក្នុងរបបខ្មែរក្រហម។ រឿងរ៉ាវនៅក្នុងភូមិបាក់នឹម និងអ្នកស្រុក គឺជាការរំឭកអំពីផលប៉ះពាល់យ៉ាងជ្រាលជ្រៅដែលរបបខ្មែរក្រហមធ្វើមកលើជីវិតប្រជាជនកម្ពុជា និងជាកេរដំណែលនៃរបួស និងការបាត់បង់ដែលនៅតែប៉ះពាល់ដល់បុគ្គល និងសហគមន៍ជាច្រើនក្នុងប្រទេសរហូតមកដល់សព្វថ្ងៃ។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាសុខភាពសាធារណៈ និងប្រវត្តិសាស្ត្រខ្មែរក្រហម នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ នៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត ដើម្បីផ្តល់ការពិនិត្យសុខភាពបឋមដោយឥតគិតថ្លៃដល់អ្នកភូមិដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដោយវេជ្ជបណ្ឌិតពីរនាក់មកពីប្រទេសហ្វីលីពីន គឺវេជ្ជបណ្ឌិត ដេមី រ៉ៃយ៍ និងវេជ្ជបណ្ឌិត សូកូរ៉ូ ។ ក្នុងចំណោមអ្នកចូលរួមចំនួន១២០នាក់មានអ្នកភូមិចំនួន៤០នាក់មិនធ្លាប់បានទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យទាល់តែសោះដោយសារបញ្ហាផ្ទាល់ខ្លួន បានចូលរួមក្នុងកម្មវិធីពិនិត្យសុខភាពបឋមលើកទី៣ ជូនអ្នកភូមិបាក់នឹមរបស់ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ អ្នកភូមិ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបជុំគ្នានៅវេលាម៉ោង ៧ ព្រឹក ដើម្បីចាប់ផ្តើមដំណើរការកម្មវិធីពិនិត្យសុខភាពជាមួយវេជ្ជបណ្ឌិតជនជាតិហ្វីលីពីន ២ នាក់។ ឈ្មោះអ្នកភូមិនីមួយៗត្រូវបានហៅម្តងម្នាក់ៗ ដើម្បីពិនិត្យកម្រិតជាតិស្ករ និងឈាម បន្តដោយការពិគ្រោះយោបល់មួយទល់នឹងមួយជាមួយវេជ្ជបណ្ឌិតសម្រាប់ធ្វើរបាយការណ៍លម្អិត និងចេញវេជ្ជបញ្ជា។



យោងតាមវេជ្ជបណ្ឌិត ដេមី រ៉ៃយ៍ ក្នុងអំឡុងពេលពីរថ្ងៃនេះនៃការពិនិត្យសុខភាព យើងបានធ្វើការប្រឹក្សាជាមួយអ្នកភូមិ បានបំពេញរបាយការណ៍នៃប្រភេទជំងឺរបស់អ្នកភូមិចូលទៅក្នុងតារាង និងពិនិត្យសុខភាពសំខាន់ៗជូនអ្នកភូមិដូចជា ការពិនិត្យរាងកាយ ពិនិត្យរោគសញ្ញាសំខាន់ៗដែលលេចឡើង កម្រិតជាតិស្ករក្នុងឈាម និង ពិនិត្យចង្វាក់បេះដូងជាមួយម៉ាស៊ីន







ប្រជាជននៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត មកពិនិត្យសុខភាពដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

វាស់ចង្វាក់បេះដូង ECG ។ ការពិនិត្យសុខភាពបានបង្ហាញលទ្ធផលដូចខាងក្រោម៖

- ១.៥០ភាគរយ នៃអ្នកជំងឺ មានជំងឺទឹកនោមផ្អែមប្រភេទទី ២ ដែលអ្នកជំងឺខ្លះមិនដឹងខ្លួនថាមានជំងឺទឹកនោមផ្អែមឡើយ។
- ២.៨៥ភាគរយ នៃអ្នកជំងឺមានជំងឺលើសឈាម ដែលមានសម្ពាធឈាមចាប់ពីកម្រិតមធ្យមទៅធ្ងន់ធ្ងរ។
- ៣.៣០ភាគរយ នៃអ្នកជំងឺបានបង្ហាញពីភាពមិនប្រក្រតីនៃបេះដូង តាមម៉ាស៊ីនវាស់ចង្វាក់បេះដូង ECG
- ៤.១០ភាគរយ មានសួតរ៉ាំរ៉ៃ
- ៥.៩០ភាគរយ គឺអ្នកជំងឺជាបុរសដែលជក់បារី
- វេជ្ជបណ្ឌិត ដេមី វ៉ៃយ៍ ក៏បានផ្តល់វេជ្ជបញ្ជា និងការណែនាំដល់អ្នករស់រានមានជីវិតនីមួយៗដែលមានជំងឺទឹកនោមផ្អែម និងលើសឈាម ដើម្បីការពារផលវិបាកនៃជំងឺនេះបន្ថែមទៀត។

នៅវេលាម៉ោង៩ព្រឹក ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានចែកអាហារសម្រន់ និងប្រអប់អនុស្សាវរីយ៍ ជូនអ្នកភូមិដែលបានមកចូលរួមកម្មវិធីក្នុងឱកាសនេះអ្នកភូមិគ្រប់គ្នាសម្តែងនូវភាពរីករាយនិងថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់មក បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាពីរនាក់បានសួរពីបញ្ហាសុខភាពនិងយោបល់ពីអ្នកភូមិជុំវិញកម្មវិធីវេទិកាសុខភាពដែលមានរៀបរាប់នៅខាងក្រោម៖

អ្នកស្រី **ម៉ម ណាវ** ភេទស្រី អាយុ៦៣ឆ្នាំ បាននិយាយថា «ខ្ញុំឈឺពាក់កណ្តាលភ្នែក ឈឺតាមសរសៃប្រសាទនិងផ្នែកខាងក្រោមនៃខ្លួន។ ខ្ញុំក៏ឈឺក្រពះដែរ។ ខ្ញុំបានឮអំពីកម្មវិធីពិនិត្យសុខភាពនេះតាមរយៈសាច់ញាតិ ហើយ ខ្ញុំមានអារម្មណ៍ល្អដែលមកពិនិត្យសុខភាពនៅថ្ងៃនេះ»។

**គឹម រ៉េង** ភេទប្រុស អាយុ៥៨ឆ្នាំ បានអះអាងថា «ខ្ញុំឈឺក ស្ពឹកដៃ និងជើង។ ជំងឺនេះបានកើតឡើង ប៉ុន្តែខ្ញុំក៏បានលេបថ្នាំកាលពីមុនមកដែរ។ ថ្ងៃនេះ ខ្ញុំសប្បាយចិត្ត និងពេញចិត្តដែលអាចពិនិត្យសុខភាពបាន»។

**ផ្លូង យឿង** ភេទប្រុស អាយុ៦៦ឆ្នាំ បាននិយាយថា «ពីមុនខ្ញុំមានជំងឺលើសឈាម ប៉ុន្តែថ្ងៃនេះ ខ្ញុំមានអារម្មណ៍ល្អ ខ្ញុំគ្រាន់តែចង់ទៅពិនិត្យសុខភាពដោយឥតគិតថ្លៃ ដើម្បីដឹងពីស្ថានភាពជំងឺបច្ចុប្បន្នរបស់ខ្ញុំ»។ បន្ទាប់ពីពិនិត្យរួច គាត់បាននិយាយថា គាត់មានអារម្មណ៍ធូរស្រាល ហើយសូមលើកម្រាមដៃ១០ដើម្បីថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកស្ម័គ្រចិត្តដែលបានជួយយើង និងបង្កើតកម្មវិធីនេះឡើង។ ខ្ញុំសូមបួងសួងឲ្យអ្នកទាំងអស់ទទួលបានតែសេចក្តីសុខ និងសុភមង្គល»។

**ឈូក ធិញ** ភេទប្រុស អាយុ ៥៩ឆ្នាំ បាននិយាយថា «ខ្ញុំមានបញ្ហាក្រពះ ពោះវៀន ដែលកើតឡើងមុន និងក្រោយពេលហូបបាយ។ ខ្ញុំបានលេបថ្នាំដែលជួយខ្ញុំឲ្យធូរស្រាលមួយរយៈ។ ខ្ញុំពិតជាអរគុណខ្លាំងណាស់សម្រាប់ការពិនិត្យដោយឥតគិតថ្លៃនៅថ្ងៃនេះ ព្រោះខ្ញុំមិនដែលឮ ឬឃើញអង្គការក្រៅរដ្ឋាភិបាលណាដែលមកភូមិនេះ និងធ្វើការងារសប្បុរសធម៌នោះទេ។ បន្ទាប់ពីខ្ញុំបានធ្វើតេស្តឈាម ខ្ញុំមានអារម្មណ៍ធូរស្រាល»។

**ស៊ូ យឹម** ភេទស្រី អាយុ៥៩ឆ្នាំ បានអះអាងថា «ខ្ញុំមានជំងឺទឹកនោមផ្អែម ហើយថ្ងៃនេះ ខ្ញុំមានអារម្មណ៍សប្បាយរីករាយ ខ្លាំងណាស់ មិនដូចថ្ងៃមុនទេ។ ខ្ញុំអរគុណដែលទទួលបានការពិនិត្យដោយឥតគិតថ្លៃនេះ។ វាជួយកាត់បន្ថយបន្ទុករបស់ខ្ញុំ ហើយខ្ញុំអាចប្រើលុយទិញថ្នាំបាន។ តាំងពីឆ្នាំ១៩៧៩ ខ្ញុំមិនដែលឮថាមានអង្គការមិនមែនរដ្ឋាភិបាលមកជួយទេ»។ ស៊ូ យឹម និយាយទាំងគ្មុកគ្មួលនិងស្រក់ទឹកភ្នែកថា «ជារៀងរាល់ថ្ងៃ ខ្ញុំរកបានត្រឹមតែ១ដុល្លារប៉ុណ្ណោះក្នុងមួយថ្ងៃ ហើយថ្ងៃខ្លះ ខ្ញុំស្ទើរតែរកលុយមិនបានទាល់តែសោះ។ ដូច្នេះ ការទទួលបានការគាំទ្រផ្នែកសុខភាពនេះគឺមានតម្លៃណាស់។

ការពិនិត្យសុខភាពបឋមដោយឥតគិតថ្លៃដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកស្ម័គ្រចិត្តនៅភូមិបាក់នឹម គឺជាជំនួយសង្គ្រោះដែលត្រូវការច្រើនសម្រាប់អ្នកភូមិ។ សក្ខីកម្មរបស់ ម៉ម ណាវ, គឹម វ៉េង, ផ្លុង យឿង, ឈួក ធិញ និង ស៊ូ យីម បង្ហាញពីបញ្ហាសុខភាពដែលពួកគាត់បានដោះស្រាយជាយូរមកហើយ ដោយសារលទ្ធភាពទទួលបានសេវាថែទាំសុខភាពនៅមានកម្រិត។ កម្មវិធីពិនិត្យសុខភាពនៅថ្ងៃនេះមិនត្រឹមតែផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃដល់អ្នកភូមិប៉ុណ្ណោះទេប៉ុន្តែថែមទាំងផ្តល់ក្តីសង្ឃឹម និងការដឹងគុណដល់អ្នកភូមិទាំងអស់ផងដែរ។

អ្នកភូមិជាច្រើនបានសម្តែងការដឹងគុណចំពោះកាយវិការសប្បុរស និងបានទទួលស្គាល់ពីភាពកម្រនៃការផ្សារមនុស្សធម៌បែបនេះនៅក្នុងភូមិរបស់ខ្លួន។ គំនិតផ្តួចផ្តើមដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកស្ម័គ្រចិត្តកម្ពុជាមិនត្រឹមតែបានធ្វើឲ្យសុខភាពរបស់អ្នកភូមិប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយកសាងចំណងមិត្តភាពរវាងសហគមន៍ និងអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យកាន់តែរឹងមាំថែមទៀត។ វាពិតជាគួរឲ្យរំភើបចិត្តក្នុងការឃើញទង្វើល្អ និងសប្បុរស ជាពិសេសនៅក្នុងតំបន់ដែលដាច់ស្រយាល ដែលអ្នកភូមិនៅមានកម្រិតក្នុងការទទួលបាននូវសេវាថែទាំសុខភាព។



ប្រជាជននៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត មកពិនិត្យសុខភាពដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ ។
( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )



# ការអប់រំពីបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតែសំខាន់

***គីម សុវណ្ណដានី***



នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការចិត្តសង្គម អន្តរវប្បធម៌ សហការធ្វើសិក្ខាសាលាស្តីពីការអប់រំ និងដោះស្រាយបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរស់នៅក្នុងភូមិរំចេក នៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅអស់រយៈពេល ៤៤ឆ្នាំទៅហើយក្តី តែការនឹកឃើញពីការធ្វើទារុណកម្ម ការបង្អត់អាហារ និងការបង្ខំឲ្យធ្វើការលើសកម្លាំង នៅដក់ជាប់ក្នុងការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដដែល ពិសេសអ្នកដែលមានជីវភាពក្រលំបាក ដែលជារឿយៗតែងតែតូចចិត្ត និងខឹងសម្បារដល់របបខ្មែរក្រហមដែលបានធ្វើឲ្យក្រុមគ្រួសាររបស់គាត់បែកបាក់ បាត់បង់សមាជិកគ្រួសារ រហូតដល់ធ្វើឲ្យគាត់ជួបតែភាពលំបាកមកដល់សព្វថ្ងៃ ផ្ទុយទៅនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានជីវភាពធូធារដែលមិនសូវព្រួយបារម្ភ ឬនឹកឃើញអតីតកាលដ៏ជូរចត់។ ជាក់ស្តែង ទិន្នន័យដែលប្រមូលបានពីការចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី ៥០ ឡើង ដោយអ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ២០២២ កន្លងមកនេះ សរុបមានចំនួន ៣៥៣០៨ ក្នុងចំណោមនេះ មានអ្នកមានវិបត្តិផ្លូវចិត្តចំនួន ៦៥៣៨ ស្មើនឹង ២០%។

គម្រោងជនរងគ្រោះដោយអំពើទារុណកម្ម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ កន្លងមកធ្លាប់បានសហការជាមួយអង្គការចិត្តសង្គម អន្តរវប្បធម៌ បង្កើតកម្មវិធីអប់រំពីបញ្ហាសុខភាពផ្លូវចិត្តដល់ជនរងគ្រោះពីរបបខ្មែរក្រហម និងអតីតកងទ័ពខ្មែរក្រហមរស់នៅខេត្តកណ្តាល និងខេត្តតាកែវ ដែលជាខេត្តគ្រប់គ្រងដោយ តាម៉ុក លេខាភូមិភាគនិរតី នៅក្នុងរបបខ្មែរក្រហម។ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ប្រមាណជា ២២២នាក់ ក្រុមការងាររបស់អង្គការចិត្តសង្គម អន្តរវប្បធម៌ រកឃើញអ្នកមានជំងឺបាត់ស្បាតប្រមាណជា ៦០នាក់ និងមានសភាពធ្ងន់ធ្ងរ មធ្យម និងខ្សោយ។

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការចិត្តសង្គម អន្តរវប្បធម៌ សហការធ្វើសិក្ខាសាលាស្តីពីការអប់រំ និងដោះស្រាយបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរស់នៅក្នុងភូមិរំចេក នៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។ សិក្ខាសាលាប្រព្រឹត្តទៅរយៈពេល២ម៉ោង ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥០នាក់ ដែលធ្លាប់បានផ្តល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រស់នៅស្រុកកោះសូទិន និងស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីចុងឆ្នាំ ២០២២ កន្លងមក។

គោលជំហរ និងកម្មវត្ថុ គឺជាកម្លាំងដ៏រឹងមាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានសេចក្តីរំពឹងថា សង្គមយើងទទួលស្គាល់ការខំប្រឹងប្រែងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានចូលរួមកសាងប្រទេស ពង្រឹងសន្តិភាព និងការអភិវឌ្ឍន៍មួយដើម្បីអនាគតកូនចៅជំនាន់ក្រោយៗទៀត។



នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការចិត្តសង្គម អន្តរវប្បធម៌ សហការធ្វើសិក្ខាសាលាស្តីពីការអប់រំ និងដោះស្រាយបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរស់នៅក្នុងភូមិរំចេក នៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# និស្សិតវិទ្យាសាស្ត្រសុខាភិបាល មកពីសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាល មូស្លីម កម្ពុជា ទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ

**សោម ប៊ុនថន**




នៅរសៀលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ ក្រុមនិស្សិតពេទ្យមូស្លីមចំនួន៥០នាក់ ដឹកនាំដោយឯកឧត្តម សាន់ សាប អ៊ីរដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាលមូស្លីមកម្ពុជា បានមកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានការទទួលស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ ក្រុមនិស្សិតពេទ្យមូស្លីមកម្ពុជាចំនួន៥០នាក់ ដឹកនាំដោយឯកឧត្តម សាន់ សាប អ៊ីរដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាលមូស្លីមកម្ពុជា បានមកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានការទទួលស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅក្នុងឱកាសនោះលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រសាសន៍ថា «មានប្រជាជនចំនួន ៥ លាននាក់ ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលស្មើនឹង ៣៣% នៃប្រជាជនទូទាំងប្រទេសកម្ពុជា ដែលហាក់មិនសូវទទួលបានការយកចិត្តទុកដាក់។ អ្នករស់រានមានជីវិតទាំងនេះបានកសាងប្រទេសឡើងវិញពីបាតដៃទទេ ដែលត្រូវជា មា មីង អ៊ំ យាយ និងតារបស់យើង។ បច្ចុប្បន្នអ្នកទាំងនេះមានវ័យកាន់តែចាស់ៗអស់ហើយ និងចាប់ផ្តើមមានជំងឺ។ នៅក្នុងចំណោម

៣៣% នៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំងនេះកំពុងប្រឈមនឹងជំងឺ១០យ៉ាងដូចគ្នា រួមមាន ១) ជំងឺលើសឈាម ២) ជំងឺក្រពះពោះវៀន ៣) ជំងឺគ្រុនចាញ់ ៤) ជំងឺផ្លូវចិត្ត ៥) ជំងឺបេះដូង ៦) ជំងឺឈឺសន្លាក់ ៧) ជំងឺហឺតរ៉ាំរ៉ៃ ៨) ជំងឺទឹកនោមផ្អែម ៩) ជំងឺរបេង និង១០) ជំងឺស្ពឹកជ្រូក។ នៅពេលមានតុលាការកាត់ទោស អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំងនេះមិនបានទទួលសំណងឡើយ ដោយសារឧក្រិដ្ឋកម្ម និងអំពើប្រល័យពូជសាសន៍មានទំហំធំធេង។ អ្នករស់រានមានជីវិតទាំងនេះខិតខំតស៊ូរកយុត្តិធម៌ហើយក្រោយមកគាត់ធ្លាក់ខ្លួនឈឺ។

លោក ឆាំង យុ បានបន្តថា ខ្ញុំគិតថាយើងគួរតែធ្វើអ្វីបន្តិចជាទឹកចិត្ត ភាពស្មោះត្រង់ ការបរិច្ចាគ (ក្នុងសាសនាអ៊ីស្លាម) ជូនដល់គាត់បន្តិចបន្តួច។ យើងចង់ឲ្យគាត់បានពិនិត្យសុខភាព ហើយយើងត្រូវចុះទៅជួបគាត់នៅភូមិ ទោះមិនអាចបានជួបទាំងអស់ គឺបានត្រឹម ១សែនឬ ២សែននាក់ ក៏យើងធ្វើដែរ។ សព្វថ្ងៃប្រជាជនខ្លះដែលរួចរស់ពីសម័យខ្មែរក្រហមក៏មានជីវភាពធូរធារ ប៉ុន្តែអ្នកខ្លះក៏ក្រីក្រ និងអ្នកខ្លះទៀតពិការ ដូច្នេះយើងមើលថែអ្នកណាដែលពិបាកជាងគេ។ យើងធ្វើតាមលទ្ធភាពយើងអាចធ្វើបាន សំខាន់ចេញពីទឹកចិត្តស្មោះត្រង់។ ខ្ញុំចង់ឲ្យប្អូនៗរួមចំណែកជាមួយយើង គឺប្អូនអាចចុះទៅតាមសហគមន៍ជួបពួកគាត់។ ប្រសិនជាប្អូនឃើញថាគាត់លើសឈាម និងមានជំងឺរបេង តើប្អូនៗត្រូវធ្វើអ្វី? នេះជាកិច្ចការរបស់យើង។

ជាទូទៅយើងផ្តល់អាហារ និងមធ្យោបាយធ្វើដំណើរជូនគាត់ដើម្បីទៅពិនិត្យសុខភាព និងពិនិត្យមើលឈាម។ កិច្ចការនេះតូច និងជាកិច្ចការដែលចាប់ផ្តើមដំបូង ដែលយើងបានគិតគូរពីសុខភាពរបស់អ្នកដែលបានកសាងប្រទេសឡើងវិញ ដែលអ្នកទាំងនេះមិនត្រូវបានគេអើពើ។ ដូច្នេះបានជាយើងឲ្យសិស្ស និងនិស្សិតស្ម័គ្រចិត្តរាប់ពាន់នាក់ទៅជួបសួរសុខទុក្ខគាត់ និងយករបស់បន្តិចបន្តួចដែលគាត់នៅតែគិតថាមានតម្លៃជូនគាត់ ហើយឲ្យគាត់ប្រាប់រឿងរ៉ាវដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមប្រាប់មកយើងវិញ»។

នៅចុងបញ្ចប់កម្មវិធីទស្សនកិច្ច លោក ឆាំង យុ បញ្ជាក់ថា សិស្សនិស្សិតដែលមកទស្សនកិច្ចនៅថ្ងៃនេះ ក៏អាចមកស្រាវជ្រាវនៅបណ្ណាល័យសម្តេចម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងផ្នែកពេទ្យ និងសុខាភិបាលបានដែរ។ បន្ទាប់មកក្រុមនិស្សិតពេទ្យមូស្លីម បានទស្សនាទីតាំង និងកន្លែងតម្កល់ឯកសារនៅក្នុងបណ្ណាល័យសម្តេចម៉ែ។







នៅរសៀលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ ក្រុមនិស្សិតពេទ្យមូស្លីមចំនួន៥០នាក់ ដឹកនាំដោយឯកឧត្តម ស៊ាន់ សាប អ៊ី រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាលមូស្លីមកម្ពុជា បានមកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# កិច្ចសំណេះសំណាលជាមួយ ដូនជី តាជី និង ប្រជាជនចំណុះជើងវត្តស្ទួនពេជ្រ

គីម សុវណ្ណដានី



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាជួបសំណេះសំណាល និងពិនិត្យសុខភាព ដូនដូនជី តាជី និងប្រជាជនចំណុះជើងវត្តស្ទួនពេជ្រ នាព្រឹកព្រលឹមថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នាព្រឹកព្រលឹមថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំការជួបសំណេះសំណាលជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងសាលាឆាន់វត្តស្ទួនពេជ្រ។ ជារៀងរាល់ថ្ងៃសីល ប្រជាជនចំណុះជើងវត្តស្ទួនពេជ្រ ដែលភាគច្រើនមានអាយុចាប់ពី៥០ឆ្នាំឡើង និងជាស្ត្រីចាស់ជរា បានមកសុំសីល ប្រគេនចង្ហាន់ព្រឹកដល់ព្រះសង្ឃដែលគង់នៅក្នុងវត្តស្ទួនពេជ្រ ដើម្បីបញ្ជូនបុណ្យកុសលដល់បុព្វការីជនដែលបានលាចាកលោកនេះទៅហើយ និងឈ្វេងយល់ពីព្រះធម៌នៃព្រះពុទ្ធសាសនា។

វត្តអារាម គឺជាទីកន្លែងសម្រាប់សិស្សដែលមិនមានលទ្ធភាពជួលផ្ទះស្នាក់នៅរៀនសូត្រ ជាកន្លែងស្វែងរកសេចក្តីស្ងប់ក្នុងចិត្តដល់អ្នកមានវិបត្តិផ្លូវចិត្ត ជាកន្លែងសំណាក់បុសំចតសម្រាប់អ្នកដំណើរឆ្ងាយជិត ជាកន្លែងសម្រាប់ទុរគតជន បុជនអនាថាដែលគ្មានលទ្ធភាពចិញ្ចឹមជីវិត ដូនជី តាជី និងជនពិការ (ពិការរាង្គកាយ និងពិការខួរក្បាល) ស្នាក់នៅក្នុងវត្តអារាមរហូតដល់ជីវិតចុងក្រោយបាន មិនតែប៉ុណ្ណោះវត្តអារាមក៏ជាទីកន្លែងដែលផ្តល់ក្តីសង្ឃឹមដល់ទុរគតជនគ្រប់ស្រទាប់វណ្ណៈ។ ក្នុងនោះដែរយើងក៏បានដឹងដែរថា វត្តអារាមក៏បានចូលរួមចំណែកក្នុងការដោះស្រាយវិបត្តិផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដោយការអប់រំកុំឲ្យចងកំហឹងកុំឲ្យសងសឹក តាមវិធីសាស្ត្ររំងាប់ចិត្តតាមធម៌ព្រះពុទ្ធ គឺ «ពៀររំងាប់ដោយការមិនចងពៀរ»។

ក្រោយការដួលរលំនៃរបបខ្មែរក្រហម ស្ទើរ៩០ ភាគរយនៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប្រឈមនឹងវិបត្តិផ្លូវចិត្ត ជំងឺថប់អារម្មណ៍ និងជំងឺបាក់ទឹកចិត្ត។ ក្រោយពេលការបង្កើតឡើងវិញនៃវត្តអារាម ប្រជាជនចាស់ក្មេងប្រុសស្រីដែលកាន់ព្រះពុទ្ធសាសនា ចាប់ផ្តើមប្រណិប័តន៍ និងប្រើប្រាស់ទីវត្តអារាមដើម្បីជួបជុំពិភាក្សាពីវិបត្តិផ្លូវចិត្ត ចែករំលែកទាំងទុក្ខព្រួយ និងក្តីរីករាយ ដែលបានចូលរួមចំណែកក្នុងការផ្សះផ្សា និងព្យាបាលរបួលដល់គ្នាទៅវិញទៅមក។ ដោយឡែកវត្តស្ទួនពេជ្រក៏បានរៀបចំឡើងវិញ និងមានការកសាងស្តូបដើម្បីតម្កល់អដ្ឋិធាតុប្រជាជនដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហមក្នុងបរិវេណវត្តដែរ។

ពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទៅដល់វត្តមានមនុស្សចាស់ និងមនុស្សវ័យកណ្តាលប្រមាណជា ៨០នាក់ កំពុងតែវេរចង្ហាន់ព្រឹក និងសុំសីលនៅក្នុងសាលាឆាន់។ ក្រុមការងារចាប់ផ្តើមរៀបចំ កញ្ចប់អនុស្សាវរីយ៍ និងអាហារពេលព្រឹកជូនដល់ប្រជាជនចំណុះជើងវត្ត ក៏ដូចជាការប្រគេនទេយ្យទានដល់ព្រះសង្ឃគង់នៅក្នុងវត្តស្ទួនពេជ្រ។ ក្រោយពេលកិច្ចសុំសីលបានបញ្ចប់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានណែនាំខ្លួន ដល់ប្រជាជនដែលនៅសាលាឆាន់ អំពីគោលបំណងក្នុងការចុះមកជួបសួរសុខទុក្ខ ក៏ដូចជាការណែនាំអំពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងមានការពិនិត្យសុខភាពបឋមដោយលោកវេជ្ជបណ្ឌិត ដេមី រេយស៍ គឺជាជនជាតិហ្វីលីពីន ដល់អ្នកចូលរួមដែលចង់ពិនិត្យ និងពិគ្រោះជំងឺទូទៅ។ ការពិនិត្យមានដូចជា ៖ ពិនិត្យសម្ពាធឈាម និងកម្រិតជាតិស្ករក្នុងឈាម។

ក្រោយពីការពិនិត្យ និងពិគ្រោះជំងឺរួចរាល់ អ្នកចូលរួមទទួលសេវានេះ មានការរីករាយ និងសប្បាយចិត្ត ក្រៃលែង ដោយលោកតាលោកយាយខ្លះមិនដែលបានទៅពិនិត្យ និងប្រឹក្សាជំងឺជាមួយវេជ្ជបណ្ឌិតកន្លងមកទេ ព្រោះតែការខ្វះខាតថវិកា ក៏ដូចជាការធ្វើដំណើរទៅមណ្ឌលសុខភាព។ ដូនជីមួយចំនួនមានការត្រេកអរ ព្រោះគាត់កំពុងតែបារម្ភពីកម្រិតជាតិស្ករក្នុងខ្លួន និងបញ្ហាជំងឺលើសសម្ពាធឈាម ដោយគាត់មានអាការគួរឲ្យព្រួយបារម្ភមួយចំនួន ដូចជា ៖ ពិបាកសម្រាន្តរោយកញ្ជ្រឹងក ឈឺក្បាលវិលមុខ ស្ពឹកជើង។ល។ ក្រោយការពិនិត្យមានលោកយាយលោកតា ប្រមាណជា ៣៥នាក់ នៃអ្នកចូលរួមពិនិត្យសុខភាពបឋម ៤០នាក់ មានជំងឺលើសឈាម និងប្រមាណ ១០នាក់ មានសញ្ញាណវិវឌ្ឍន៍ទៅរកជំងឺទឹកនោមផ្អែម។







បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាជួបសំណេះសំណាល និងពិនិត្យសុខភាព ជូនដូនជី តាជី និងប្រជាជនចំណុះជើងវត្តស្ទួនពេជ្រ នាព្រឹកព្រលឹមថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលប័ណ្ណសរសើរពីរដ្ឋបាលខេត្តកំពង់ចាម

*សោម ប៊ុនថន*




នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្ត ប្រគល់ប័ណ្ណសរសើរជូនលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារ ឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ប្រគល់ប័ណ្ណសរសើរជូនលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារ ឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកំពង់ចាម។ នៅក្នុងឱកាសនោះ ឯកឧត្តម អ៊ុន ចាន់ដា ក៏បានរំឭកឡើងវិញអំពីប្រជាជនដែលធ្វើការងារនៅតាមវាលស្រែ ទំនប់ និងប្រឡាយគ្មានពេលសម្រាកនៅក្នុងរបបខ្មែរក្រហម ដែលបណ្តាលឲ្យប្រជាជនបាក់កម្លាំង ដែលទាំងនេះយើងត្រូវចងចាំ។

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម គឺជាសាខាមួយក្នុងចំណោមសាខាទាំង៥របស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមមាន ១) មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ២) មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ៣) មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ ៤) មជ្ឈមណ្ឌលឯកសារ កោះថ្ម និង ៥) មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានដើរតួនាទីជាមជ្ឈមណ្ឌលស្រាវជ្រាវសម្រាប់សិស្សនិស្សិត អ្នកស្រាវជ្រាវ និងសាធារណជនជាពិសេសអ្នកដែលរស់នៅក្នុងខេត្តកំពង់ចាម។ មជ្ឈមណ្ឌលឯកសារខេត្ត

កំពង់ចាមមានគោលបំណងផ្តល់នូវប្រភពធនធានសម្បូរបែប ទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងអំពីប្រវត្តិ-សាស្ត្រខ្មែរក្រហមក្នុងចំណោមប្រជាជនដែលរស់នៅក្នុងខេត្តកំពង់ចាម។ បណ្ណសារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រួមមាន ឯកសារចម្លើយ សារភាព សក្ខីកម្មរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ខ្សែភាពយន្ត និងរូបថត។

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តអនុវត្តកិច្ចការងារស្នូលរបស់ខ្លួននៅតាមមូលដ្ឋាន ក្នុងការចងក្រងឯកសារ អប់រំ និងផ្សព្វផ្សាយ ស្តីអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

ចាប់តាំងពីមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបង្កើតឡើងជាផ្លូវការនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ មជ្ឈមណ្ឌលនេះបានបើកទទួលសាធារណជន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គណៈប្រតិភូ គ្រូបង្រៀន សិស្សានុសិស្ស និងយុវជនរាប់ពាន់នាក់ ដែលមកទស្សនកិច្ច និងសិក្សាស្រាវជ្រាវ។



# ដំណើរទស្សនកិច្ចសិក្សាស្តីពី សន្តិភាព និងសិទ្ធិមនុស្ស

**មេក ទិន**



សិស្សានុសិស្សមកពីវិទ្យាល័យតេជោសែន សំរោង ចំនួន ២៨នាក់ គឺស្រីចំនួន ២០នាក់ និងប្រុសចំនួន ០៨នាក់ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំទទួលស្វាគមន៍សិស្សានុសិស្សមកពីវិទ្យាល័យតេជោសែន សំរោង ចំនួន២៨នាក់ គឺស្រីចំនួន ២០នាក់ និងប្រុសចំនួន០៨នាក់ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង»។

កន្លងមក មានសិស្សានុសិស្សចំនួន ២៣នាក់ មកពីវិទ្យាល័យតេជោសែនសំរោង បានមកចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សារបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរួចហើយ។ នេះជាការទទួលស្វាគមន៍សិស្សានុសិស្សនៅវិទ្យាល័យតេជោសែនសំរោង ជាលើកទីពីរនៅក្នុងឆ្នាំ ២០២៣នេះ។ សិស្សានុសិស្សមួយចំនួនក៏បានបង្ហាញនូវចំណាប់អារម្មណ៍មុនពេលធ្វើដំណើរមកកាន់តំបន់ប្រវត្តិ-សាស្ត្រអន្លង់វែងថា «ពិតប្រាកដណាស់ប្រវត្តិសាស្ត្រខ្មែរក្រហមគឺជារឿង”ពិត ដែលយុវជនគ្រប់រូបត្រូវតែដឹងៗ និងខិតខំសិក្សាឈ្វេងយល់ឲ្យកាន់តែច្បាស់ ព្រោះវាជាប្រវត្តិសាស្ត្រដ៏ឃោរឃៅ។ កេរដំណែលដែលបានសេសសល់ពីសម័យខ្មែរក្រហម



សិស្សានុសិស្សមកពីវិទ្យាល័យតេជោសែន សំរោង ចំនួន ២៨នាក់ គឺស្រីចំនួន ២០នាក់ និងប្រុសចំនួន ០៨នាក់ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅតំបន់ប្រវត្តិសាស្ត្រ ពិតជាមានអត្ថន័យធំធេងណាស់សម្រាប់ក្មេងៗជំនាន់ក្រោយដូចជាពួកខ្ញុំ ដោយសារទីតាំងនីមួយៗសុទ្ធតែមានការចងចាំមានអត្ថន័យខុសៗពីគ្នា ហើយមានទាំងរឿងរ៉ាវល្អ និងរឿងរ៉ាវអាក្រក់ៗ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺ យើងបានឈ្វេងយល់ និងដឹងពីការឈឺចាប់ និងទុក្ខលំបាករបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម។ ប្រជាជនខ្មែរគ្រប់រូបត្រូវតែការពារកុំឲ្យប្រទេសជាតិធ្លាក់ចូលទៅក្នុងអតីតកាលម្តងទៀត។ សង្គមជាតិមួយ ប្រសិនបើមិនមានអតីតកាលទេ ក៏មិនអាចមានអនាគតកាលបានដែរ»។

ការសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺពិតជាមានសារសំខាន់ខ្លាំងណាស់ចំពោះសិស្សានុសិស្ស ក៏ដូចជាយុវជនយុវនារីជំនាន់ក្រោយ។ តំបន់ប្រវត្តិសាស្ត្រអន្លង់វែង គឺជាទីតាំងសំខាន់សម្រាប់ផ្តល់នូវចំណេះដឹង ការស្រាវជ្រាវរួមទាំងការផ្តល់នូវគំនិតថ្មីៗជាច្រើនដល់អ្នកសិក្សា។ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺជាប្រវត្តិសាស្ត្រក៏ឃោរឃៅ និងព្រៃផ្សៃ ដោយបានកាប់សម្លាប់ប្រជាជនស្លូតត្រង់អស់ជាង២លាននាក់។ ប្រជាជនគ្រប់រូបត្រូវតែកត់ត្រាប្រវត្តិសាស្ត្រនេះ។

នៅក្នុងកម្មវិធីនេះ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏បានធ្វើការបង្ហាញនូវប្លង់គោល និងគម្រោងអភិវឌ្ឍន៍ស្រុកអន្លង់វែងទាំងមូល ព្រមទាំងលើកយកប្រវត្តិនៃការកកើតខ្មែរក្រហមរហូតដល់មានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ក្នុងឆ្នាំ១៩៧០ មកបង្ហាញដល់សិស្សានុសិស្ស។ បន្ទាប់ពីបណ្ឌិត លី សុខឃាង ធ្វើបទបង្ហាញដល់សិស្សានុសិស្សរួច ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនាំសិស្សានុសិស្សទៅមើលសារមន្ទីរផ្ទះតាម៉ុក។ សារមន្ទីរនេះ គឺជាទីកន្លែងមួយសម្រាប់ផ្តល់នូវចំណេះដឹងដល់សិស្សា-







*សិស្សានុសិស្សមកពីវិទ្យាល័យតេជោសែន សំរោង ចំនួន ២៨នាក់ គឺស្រីចំនួន ២០នាក់ និងប្រុសចំនួន ០៨នាក់ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នុសិស្ស និងជាទីកន្លែងសម្រាប់ភ្ញៀវទេសចរណ៍ចូលមកទស្សនា។ បន្តមកទៀតសិស្សានុសិស្សបន្តដំណើរទៅមើលកន្លែងដុតសព សុន សេន, ចេតិយតាម៉ុក និងទីកន្លែងដុតសពរបស់ ប៉ុល ពត ដែលជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។ ក្រោយពីបានពិនិត្យមើលពីទីតាំងសំខាន់ៗទាំង៤កន្លែងខាងលើនេះរួចរាល់ សិស្សានុសិស្សបានបន្តដំណើរឡើងទៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង (អតីតផ្ទះប្រជុំតាម៉ុក) ស្ថិតនៅលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្ននេះត្រូវបានប្រែក្លាយទៅជាទីកន្លែងអប់រំស្តីពីសន្តិភាព និងសិទ្ធិមនុស្ស ដល់យុវជនជំនាន់ក្រោយ។ នៅក្នុងដំណើរទស្សកិច្ចនេះ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់ ក៏បានដឹកនាំសិស្សទាំងអស់ទៅទស្សនាវត្តអូរគ្រញូង ដើម្បីសិក្សាឈ្វេងយល់ និងគយគន់ទេសភាពនៅទីនោះមុននឹងធ្វើដំណើរត្រឡប់ទៅផ្ទះវិញ។

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចនេះ សិស្សានុសិស្សបានបង្ហាញនូវចំណាប់អារម្មណ៍ទាក់ទងនឹងតំបន់ប្រវត្តិសាស្ត្រអន្លង់វែងដូចខាងក្រោម៖

**សឹង ប៊ុនសុខ** ភេទប្រុស អាយុ២៣ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ តេជោសែនសំរោង បាននិយាយរៀបរាប់ពីចំណាប់អារម្មណ៍របស់ខ្លួនបន្ទាប់ពីបានចូលរួមក្នុងដំណើរទស្សនកិច្ចថា «ជាការពិតណាស់ ខ្ញុំពិតជាមានចិត្តសប្បាយរីករាយជាខ្លាំងនូវពេលដែលខ្ញុំបានមកដល់ស្រុកអន្លង់វែង។ ទោះបីជាដៃ និងជើង របស់ខ្ញុំពិការតាំងពីកំណើត ដែលបង្កឲ្យខ្ញុំពិបាកក្នុងការដើរ មិនដូចមិត្តភក្តិដទៃទៀតក៏ដោយ ប៉ុន្តែខ្ញុំពិតជាសប្បាយរីករាយដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចនេះ។ មិត្តភក្តិខ្ញុំមិនមានការរើសអើងខ្ញុំដែលជាជនពិការឡើយ។ មិត្តភក្តិខ្ញុំតែងតែលើកទឹកចិត្ត និងជួយទុក្ខធុរៈខ្ញុំជានិច្ច។ ខ្ញុំយល់ថាសង្គមជាតិយើងបច្ចុប្បន្ននេះមិនមានការរើសអើងជនពិការ មិនរើសអើងពណ៌សម្បុរ ឬពូជសាសន៍នោះទេ។ ខ្ញុំរីករាយដែលបានចូលរួមកម្មសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រនៅតំបន់អន្លង់វែង។

# អតីតកម្មាភិបាលខ្មែរក្រហម បង្រៀនចៅៗ ពីប្រវត្តិសាស្ត្រខ្មែរក្រហម

## និងភាពជាអ្នកដឹកនាំដែលមិនបង្កគ្រោះថ្នាក់ដល់សង្គមជាតិ

*ផេង ពង្សរ៉ាស៊ី*



ព្រុំ ពុំ ជាអតីតកងឈ្លប និងកងសន្តិសុខនៅមន្ទីរសន្តិសុខទួលដើងចាប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អតីតកម្មាភិបាលខ្មែរក្រហមពីររូប បង្រៀនចៅៗរបស់ខ្លួនពីប្រវត្តិសាស្ត្រខ្មែរក្រហម និងក្រើនរំឭកចៅៗឲ្យមានការប្រុងប្រយ័ត្នចំពោះការឃោសនានានាដែលនាំឲ្យឈានដល់ការបំផ្លិចបំផ្លាញគ្រួសារ សហគមន៍ និងប្រទេសជាតិ។ ការលើកឡើងរបស់អតីតកម្មាភិបាលខ្មែរក្រហមទាំងពីររូបនេះ បានធ្វើឡើងនៅក្នុងវេទិកាអប់រំសហគមន៍មួយកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង នៅក្នុងបរិវេណវត្តស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ វេទិកានេះ មានការចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ១៥នាក់ និងក្មេងៗជំនាន់ក្រោយដែលជាសិស្សានុសិស្ស និងត្រូវជាចៅៗរបស់អ្នករស់រានមានជីវិតទាំងនោះចំនួន ២១នាក់ ក្រោមការសម្របសម្រួលពីមេភូមិស្រះតាអឹម។ ដោយមានបទពិសោធន៍ក្រាស់ក្រែលឆ្លងកាត់ច្រើនជំនាន់អំប្រុសទាំងពីរគឺ ស្រី នឿន និង ព្រុំ ពុំបានចែករំលែក និងស្ម័គ្រចិត្តបង្រៀនដល់ចៅៗទាំងអស់របស់គាត់អំពីបទពិសោធន៍ផ្ទាល់ខ្លួនទាក់ទងនឹងការចូលរួមធ្វើបដិវត្តន៍ ការអនុវត្តតួនាទីក្នុងរបបខ្មែរក្រហម ការភ័យខ្លាចនានាដែលកើតចេញពីការអនុវត្តគោលនយោបាយរបស់ខ្មែរក្រហមមកលើប្រជាជនទូទៅនាពេលនោះ និងការបង្ហាញពីភាពសោកស្តាយចំពោះការលះបង់អាយុជីវិតបម្រើជាកម្មាភិបាលខ្មែរក្រហម។

ស្រី នឿន អាយុ៧៣ឆ្នាំ គឺជាអតីតកម្មាភិបាលខ្មែរក្រហមបម្រើការជាប្រធានកងធំ ឬប្រធាន «យ» គ្រប់គ្រងមនុស្ស ៣០០នាក់ នៅក្នុងឃុំអង្គរស បានរៀបរាប់ប្រាប់ចៅៗទាំង ២១នាក់ អំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងឃុំអង្គរស និងបានបង្ហាញឈ្មោះកម្មាភិបាលដឹកនាំក្នុងភូមិស្រះតាអឹមចំនួន ១៨នាក់ ដែលត្រូវបានសម្លាប់ចោលក្នុងឆ្នាំ១៩៧៨ ដោយកម្មាភិបាលខ្មែរក្រហមខាងភូមិភាគនិរតី។ អ្នកស្លាប់ទាំងនោះគឺជាកម្មាភិបាលដែលបានដឹកនាំ

ប្រជាជនឲ្យចូលបម្រើក្នុងជួរបដិវត្តន៍ក្រោយការធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ភ្លាមៗក្នុងឆ្នាំ១៩៧០ និងជាអ្នកដែលបានដឹកនាំភូមិស្រះតាអឹម តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់មានព្រឹត្តិការណ៍ចាប់ខ្លួននៅឆ្នាំ១៩៧៨។ ស្រី នឿន ក៏បានបញ្ជាក់ប្រាប់ចៅៗថា រឿងរ៉ាវដែលបានកើតឡើងគឺជារឿងរ៉ាវពិត ហើយគាត់គឺជាកម្មាភិបាលខ្មែរក្រហមម្នាក់ដែលមានវ័យក្មេងជាងគេកាលពីជំនាន់នោះ ដែលមានមោទកភាពខ្ពស់ក្នុងការបំពេញភារកិច្ចជូនអង្គការ និងបដិវត្តន៍។ អ្វីដែលធ្វើឲ្យអ៊ំ ស្រី នឿន ភ័យខ្លាចជាងគេក្នុងពេលដែលគាត់កំពុងបំពេញភារកិច្ចជាកម្មាភិបាលដឹកនាំកងធំ គឺកំហុសខុសសីលធម៌ទី៦របស់បក្ស ដែលកំហុសនេះអាចធ្វើឲ្យគាត់ធ្លាក់បុណ្យសក្តិពីប្រធានកងធំ និងពីតំណែងបក្ខជនដែលខំកសាងមកជាយូរមកហើយ។ នឿន បាននិយាយលេងសើចនៅក្នុងវេទិកាថា គាត់មានរូបរាងស្អាតបាត និងមានស្រីៗស្រឡាញ់ច្រើន គឺមានទាំងស្ត្រីខ្មែរ និងស្ត្រីជនជាតិចិនទៀតផង។ ខាងក្រោមនេះ ជាសម្តីរបស់អ៊ំ ស្រី នឿន៖

«ខ្ញុំសុំលើកឡើងអន្លង់៣ដែលយើងបានជួបប្រទះ។ អន្លង់ទី១) គឺអន្លង់សង្គ្រាម អន្លង់ទី២) គឺអន្លង់អត់ឃ្លាន និងអន្លង់ទី៣) គឺអន្លង់ជំងឺ។ ទាំងបីចំណុចនេះ សូមកូនៗចៅៗចងចាំឲ្យច្បាស់ថា អន្លង់ទី១ គឺអន្លង់សង្គ្រាម ដែលត្រង់នេះតាចង់បញ្ជាក់ថា ចាប់តាំងពីឆ្នាំ១៩៧៥មក ក្រែងកូនៗចៅៗមិនជឿ តាបានប្រឡូកផ្ទាល់នៅក្នុងសង្គ្រាម។ តានិយាយត្រឹមឆ្នាំ១៩៧៥មកចុះ! មិននិយាយពីពេលមុនមកទេ។ បើនិយាយពីឋានន្តរសក្តិវិញ ក៏ខ្ពស់បន្តិចដែរ ហើយបើនិយាយពីក្មេងវិញ តាក៏នៅក្មេងជាងគេដែរបើប្រៀបជាមួយនឹងកម្មាភិបាលចាស់ៗ។ ឥឡូវកម្មាភិបាលចាស់ៗស្លាប់អស់ហើយ ដោយសារគេយកទៅវាយចោល។ ជាក់ស្តែងនៅក្នុងភូមិស្រះតាអឹម ហ្នឹង បើតាមតាស្រង់ឈ្មោះ គឺមានរហូតដល់ទៅ១៨នាក់ឯណោះ ដែលសុទ្ធតែជាកម្មាភិបាលជាន់ខ្ពស់ ដូចជា បង ចឹង សាក់, បង អ៊ុង ណៃ, បង ជា ឆឹម, បង លឹម នួន, បង ឃួន ប៉េង, បង ញឹវ ឈិន, ញឹវ ឃឹម, រស់ ផុន, ជា ផុន, ជុំ ខិន, ជុំ អិន, រស់ ខន, ស្រី សារុន និង គឹម ម៉ៅ។ អ្នកទាំងអស់នេះ សុទ្ធតែត្រូវបានយកទៅសម្លាប់ចោល។ កម្មាភិបាលមួយចំនួនអង្គការសម្លាប់នៅភ្នំឈើកាច់ និងមួយចំនួនទៀតសម្លាប់តាមផ្លូវ។ ជាក់ស្តែងដែលតាបានដឹងច្បាស់ គឺបងរបស់តាម្នាក់ឈ្មោះ ជុំ ខិន ត្រូវគេវាយចោលតាមផ្លូវ ហើយកម្មាភិបាលប៉ុន្មាននាក់ខាងលើហ្នឹង គេយកទៅទម្លាក់អន្លង់នៅភ្នំឈើកាច់។ មានតែកម្មាភិបាលប៉ុន្មាននាក់ប៉ុណ្ណោះ ដែលទទួលរងការវាយដោយព្រនង់។ ឯអ្នកឯទៀតជាពិសេសមេធំៗ គឺត្រូវចូកដោយត្រាក់ទ័រ ទម្លាក់ចូលក្នុងរណ្តៅ ដែលមានជម្រៅ ៤ម៉ែត្រ បណ្តោយ៦ម៉ែត្រ និងទទឹង៣ម៉ែត្រ។ តាដឹងនេះ គឺដឹងតាម អា ហួន ដែលគាត់ស្រាវជ្រាវនៅកន្លែងនោះ។ កាលពីជំនាន់នោះ តាក៏វិះៗនឹងទៅ (ស្លាប់) ដែរ។ តា និងមិត្តភក្តិជិតស្និទ្ធបំផុតម្នាក់ទៀតបានបបួលគ្នាទៅជាមួយនឹងគេដែរ គឺទៅកាន់ស្រុកលិច ប៉ុន្តែមេកងម្នាក់បានឃាត់មិនឲ្យទៅ ព្រោះតាចេះធ្វើចង្ក្រង់ចងនៅកគោ ដើម្បីបន្លឺជាសំឡេងពិរោះ ទើបតា



ស្រី នឿន ជាអតីតប្រធានកងធំ (ប្រធានយ) គ្រប់គ្រងមនុស្ស៣០០នាក់នៅឃុំអង្គរស ស្រុកមេសាង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបខ្លួនដល់សព្វថ្ងៃ។ បងប្អូនរបស់តាដែលចូលបដិវត្តន៍ជាច្រើននាក់ ត្រូវបានអង្គការយកទៅសម្លាប់អស់ហើយ។ ចាប់តាំងពីឆ្នាំ១៩៧៥មក តាមានតួនាទីជាប្រធានកងធំបុក៏ហៅថាប្រធាន«យ» ដែលត្រូវដឹកនាំមនុស្សប្រមាណ ៣០០នាក់ ។ តាខិតខំធ្វើការងារណាស់ និងមិនប្រព្រឹត្តខុសពីបញ្ជាអង្គការនោះទេ ជាពិសេសសីលធម៌ទី៦ របស់អង្គការគឺការមិនសេពកាមគុណ។ និយាយឲ្យអស់ទៅ មូលហេតុដែលមិនហ៊ានល្មើសនឹងសីលធម៌ទី៦ គឺដោយសារតែទីមួយ) ខ្លាចអស់ឋានន្តរសក្តិ និងទីពីរ) ខ្លាចអស់សិទ្ធិពីបក្សជនរបស់អង្គការ។ រូបរាងតាកាលនេះ គេហៅថា «អំពៅបីសាច់» ដែលសំដៅលើរូបរាងស្អាត និងមានស្រីស្រឡាញ់ច្រើន។ ប៉ុន្តែតាមិនហ៊ានប្រព្រឹត្តទេ។ មានទាំងស្ត្រីចិន និងស្ត្រីខ្មែរដែលចង់ស្រឡាញ់តា។ តាសូមបញ្ជាក់ទៅចៅៗថា ខ្មែរក្រហមសម្លាប់ប្រជាជនទាំងពីរប្រភេទគឺ ទីមួយ) សម្លាប់ដោយចុងកាំភ្លើង ត្បូងចប និងធ្វើទារុណកម្ម និងទីពីរ) គឺសម្លាប់ដោយមិនឲ្យស៊ីគ្រប់គ្រាន់បង្កើនកម្លាំងពលកម្មខ្លាំង និងពុំមានថ្នាំសង្កូវសម្រាប់ព្យាបាលជំងឺ។ ជាចុងក្រោយខ្ញុំសុំបញ្ជាក់ឡើងវិញចំពោះអន្ទង់សង្គ្រាម និងអន្ទង់អត់ឃ្លាននៅក្នុងសម័យខ្មែរក្រហមយើងគេចផុតហើយ ប៉ុន្តែសព្វថ្ងៃនេះនៅអន្ទង់មួយទៀតគឺអន្ទង់ជំងឺ ដូចជាជំងឺកូវីដ-១៩ និងផ្តាសាយបក្សីជាដើម ដែលយើងគ្រប់គ្នាកំពុងហែលឆ្លង»។

ព្រុំ ពុំ អាយុ៧៨ឆ្នាំ គឺជាអតីតកងឈ្លប និងកងសន្តិសុខនៅមន្ទីរសន្តិសុខស្រុកទួលដើងចាប។ បច្ចុប្បន្ន គាត់រស់នៅជាមួយប្រពន្ធនៅភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ពុំ បានចាប់ផ្តើមការនិយាយជាមួយចៅៗទាំងអស់ពីកំហុសរបស់មេដឹកនាំបដិវត្តន៍ពីមុនៗមកដែលអ្នកទាំងនោះភាគច្រើនគឺជាអាចារ្យវត្ត ដែលបាននាំប្រទេសកម្ពុជាធ្លាក់ក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហម។ ពុំ បានបង្ហាញការសោកស្តាយរបស់ខ្លួនក្នុងការចូលបម្រើបដិវត្តន៍ខ្មែរក្រហម និងបានចាត់ទុកបទពិសោធន៍របស់គាត់ថា «បានអារសាច់មួយដុំបោះចូលមាត់ខ្លា»។ ពុំ បានរំឭកថា គាត់បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ គឺដោយសារតែមានការអំពាវនាវពីសម្តេចព្រះ នរោត្តម សីហនុ បន្ទាប់ពីថ្ងៃរដ្ឋប្រហារកាលពីខែមីនា ឆ្នាំ១៩៧០រួច។ ក្នុងពេលនោះ គាត់យល់



ព្រុំ ពុំ ជាអតីតកងឈ្លប និងកងសន្តិសុខនៅមន្ទីរសន្តិសុខទួលដើងចាប ឡើងរៀបរាប់ពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមប្រាប់សិស្សានុសិស្ស។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឃើញថា ការចូលធ្វើបដិវត្តន៍គឺមានន័យណាស់ ព្រោះគាត់អាចចូលរួមក្នុងការដណ្តើមអំណាចប្រគល់ជូនសម្តេចឪវិញ។ ប៉ុន្តែ គាត់បានភ្ញាក់ខ្លួននៅក្រោយពេលដែលខ្មែរក្រហមចូលកាន់កាប់ប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ ពុំនៅតែស្ម័គ្របម្រើខ្មែរក្រហមរហូតដល់ឆ្នាំ១៩៧៩។ នៅចំពោះមុខចៅៗរបស់គាត់ ពុំ បានអប់រំអ្នកទាំងនោះឲ្យធ្វើការសម្រេចចិត្តនិងពិចារណាឲ្យបានច្បាស់លាស់ មុននឹងជឿជាក់លើការឃោសនាបុរ្សអូសទាញពីនរណាម្នាក់ ព្រោះថា ការសម្រេចចិត្តនេះអាចនឹងនាំមកខ្លួនវិញនូវវិប្បដិសារីបុការឈឺចាប់ដែលគ្មានថ្ងៃបំភ្លេចបាន។ ចុងបញ្ចប់នៃការលើកឡើងរបស់គាត់ អ៊ំប្រុស ពុំបានសំណូមពរដល់ចៅៗទាំងអស់ឲ្យយកចិត្តទុកដាក់ក្នុងការរៀនសូត្រពីប្រវត្តិសកម្មភាពទាំងអស់ដែលបានកើតឡើងនាពេលកន្លងមក រួមទាំងការលំបាកវេទនា ការទម្លាក់គ្រាប់បែក ការចាប់ចង ការកាប់សម្លាប់ ការសាមគ្គីគ្នា ការស្មោះត្រង់នឹងគ្នា និងការរក្សាសុខសន្តិភាពជាមួយគ្នាឲ្យយូរតទៅមុខទៀត។ ខាងក្រោមនេះ ជាសម្តីរបស់អ៊ំប្រុស ព្រុំ ពុំ ដែលបាននិយាយទៅកាន់ចៅៗរបស់គាត់ក្នុងវេទិកាអប់រំសហគមន៍៖

«ខ្ញុំឈ្មោះ ព្រុំ ពុំ កើតនៅឆ្នាំ១៩៤៩។ គិតដល់ឥឡូវ ខ្ញុំមានអាយុ៧៤ឆ្នាំហើយ។ ចំពោះប្រវត្តិសាស្ត្រនេះ ខ្ញុំបានចូលរួមច្រើនណាស់។ កាលពីមុនអាណានិគមនិយមបារាំង អ្នកដឹកនាំសុទ្ធតែជាអាចារ្យ ដូចជាអាចារ្យពោធិ៍កំបោរ អាចារ្យស្វា អាចារ្យលក្ខណ៍...។ កាលនោះអ្នកដែលតស៊ូគឺសុទ្ធតែជាអាចារ្យ ហើយ សា ឡុត ស ហៅ ប៉ុល ពត នេះ គឺអ្នកដឹកនាំក្រោយៗទេ។ នៅឆ្នាំ១៩៥៩ កាលនោះតាបានដឹងក្តីហើយ និងបានចូលរៀនដំបូងនៅវត្តច័ន្ទគ្រីស្នា។ នៅឆ្នាំ១៩៦៦ តាបានបួសជាសង្ឃ។ ពេលនោះ តាបានស្តាប់ឮការប្រជុំនៅក្នុងសភាជាតិ ដែលការប្រជុំនេះតែងតែកើតមានទំនាស់ទាស់គ្នារហូតរវាងថ្នាក់ដឹកនាំក្នុងសម័យសង្គមរាស្ត្រនិយម ទាក់ទងនឹងខ្មែរខៀវ ខ្មែរក្រហម និងខ្មែរស។ ក្នុងពេលនេះ តាដឹងថាអំណាចមានពីរគឺ មួយ ទំនោរទៅរកសេរីនិយមខាងអាមេរិក និងមួយទៀតខាងកុម្មុយនីស្តនិយម ហើយខាងសម្តេច គឺអព្យាក្រឹត។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ បានកើតឡើង ដោយចោទ



ស្រី នឿន ជាអតីតប្រធានកងធំ (ប្រធានយ) គ្រប់គ្រងមនុស្ស៣០០នាក់នៅឃុំអង្គរស ស្រុកមេសាង ឡើងរៀបរាប់ពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមប្រាប់សិស្សានុសិស្ស។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រកាន់សម្តេច សីហនុ ថាបានចូលដៃជើងជាមួយវៀតកុង។ មានបាតុកម្មកើតឡើងច្រើនណាស់ដើម្បីប្រឆាំងទៅនឹង លន់ នល់។ ប្រជាជនជាច្រើន រួមទាំងរូបខ្ញុំ បានប្រឆាំងជាមួយ លន់ នល់ ដើម្បីទាមទារឲ្យសម្តេច សីហនុ យាងមកគ្រប់គ្រងប្រទេសវិញ។ ខ្ញុំបានសឹកពីបួសនៅក្រោយថ្ងៃរដ្ឋប្រហារ និងបានចូលរួមក្នុងចលនាខ្មែររំដោះ ដើម្បីផ្តួលរំលំរបប លន់ នល់ តាមការអំពាវនាវរបស់សម្តេច សីហនុ។ ម៉្យាងមូលហេតុដែលចូលបម្រើបដិវត្តន៍នេះ គឺដោយសារមើលឃើញពីទុក្ខវេទនារបស់បងប្អូននៅក្នុងភូមិ ដោយសារតែការទម្លាក់គ្រាប់បែកបំផ្លាញអស់ផ្ទះសម្បែង អាយុជីវិតមនុស្ស និងសត្វពាហនៈ។ គាបានចូលតស៊ូក្នុងព្រៃម៉ាគី ប៉ុន្តែវាហាក់ដូចជា «អារសាច់មួយដុំបោះចំមាត់ខ្លា» អ៊ីចឹង។ នេះគឺមានន័យថា ប្រជាជនដែលរត់ចូលព្រៃម៉ាគីទាំងអស់ដែលស្ម័គ្រចិត្តចូលព្រៃដើម្បីយាងសម្តេចឪមកវិញ គឺបែរធ្លាក់ទៅក្នុងស្ថានភាពបម្រើក្នុងចលនាខ្មែរក្រហមដោយមិនដឹងខ្លួន។ ប៉ុន្តែកាលនេះ ទាំងអ្នកដែលចូលបម្រើក្នុងជួរបដិវត្តន៍ និងប្រជាជនទាំងអស់ព្រួយបារម្ភណាស់ គឺបារម្ភពីយន្តហោះទម្លាក់គ្រាប់បែក ពីច្បាប់ព្រៃរបស់ខ្មែររំដោះដែលគាបសង្កត់លើប្រជាជន និងពីការនាំយកសាច់ញាតិទៅសម្លាប់ចោល ដោយសារតែមានបងប្អូនធ្វើការខាងលន់ នល់។ ដូច្នេះ មិនថាតែប្រជាជនទេ ទោះបីជាអ្នកធ្វើការបម្រើឲ្យខ្មែររំដោះ ក៏មិនសប្បាយចិត្តដែរ។ ចឹងហើយបានថា ការលំបាកវេទនាក្នុងពេលនោះ យើងមិនអាចគណនាបានទេ។ ទាំងអស់នេះគឺដោយសារតែឥស្សរជននយោបាយពេលនោះ ដែលបានធ្វើឲ្យមានការលំបាកដល់ប្រជាជន។ គាគ្រាន់តែចង់ប្រាប់ថា បើនរណាមកអូសទាញយើង យើងគប្បីពិចារណាសិនថា តើគួរជឿឬមិនជឿ។ ប្រសិនជាយើងមិនបានពិចារណាទេ យើងប្រាកដជាដើរចូលភ្លើងហើយ។ ឧទាហរណ៍ជាក់ស្តែងក្នុងឆ្នាំ១៩៧០ អ៊ីចឹង គឺមិនត្រឹមតែមិនបានសម្តេច សីហនុ មកវិញទេ ប៉ុន្តែថែមទាំងធ្លាក់ខ្លួនចូលក្នុងមាត់ខ្លាទៅវិញ។ សរុបមក គាសុំឲ្យចៅៗទាំងអស់យកចិត្តទុកដាក់ក្នុងការរៀនសូត្រពីប្រវត្តិសកម្មភាពទាំងអស់ដែលបានកើតឡើង រួមទាំងការលំបាកវេទនា សកម្មភាព ទម្លាក់គ្រាប់បែក ការចាប់ចងការកាប់សម្លាប់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្មែរកាលឆ្នាំ១៩៧០ដល់១៩៧៩។ កូនចៅទាំងអស់ ក៏គួរយល់ហើយថា ប្រពៃណីរបស់យើងគឺការសាមគ្គីគ្នា ហើយសូមកុំបែកបាក់សាមគ្គីគ្នាដូចកាលពីជំនាន់មុនឲ្យសោះ ព្រោះវានាំមកនូវភាពអន្តរាយ និងសម្លាប់គ្នា។ យើងត្រូវតាំងចិត្តថា យើងមានសញ្ជាតិដូចគ្នា ត្រូវស្មោះត្រង់នឹងគ្នា និងរក្សាសុខសន្តិភាពជាមួយគ្នាឲ្យយូរតទៅមុខទៀត។ ដូច្នេះក្នុងឱកាសនេះគាយល់ថា វេទិកាអប់រំសហគមន៍ពិតជាមានតម្លៃណាស់សម្រាប់ចៅៗទាំងអស់បានសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្ររបស់ខ្មែរ។ គាចង់ឲ្យមានវេទិកាបែបនេះបន្តទៀត»។



នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សថ្នាក់ទី១២នៃវិទ្យាល័យអង្គរសចំនួន២១នាក់ គឺស្រី១៣នាក់ និងប្រុស៨នាក់ចូលរួមវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ក្រោមប្រធានបទ «អតីតកម្មាភិបាលខ្មែរក្រហមបានបង្ហាញការសោកស្តាយពីការលះបង់ជីវិតដើម្បីបដិវត្តន៍» ដែលរៀបចំធ្វើដោយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហែម ហឿន ៖ កងដឹកជញ្ជូនត្រីពីបឹងទន្លេសាប

ជាវ៉ារដ្ឋ មេត្តា



អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តពោធិ៍សាត់សម្ភាសន៍ជាមួយ ហែម ហឿន កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។ (ម៉ូសា ហានីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហែម ហឿន ភេទប្រុស អាយុ៧២ឆ្នាំ។ សព្វថ្ងៃខ្ញុំរស់នៅភូមិព្រែកតាគង់ ឃុំអន្លង់វិល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុ២២ឆ្នាំ។ ខ្ញុំមានប្រពន្ធ និងមានកូនចំនួន ២នាក់ គឺកូនទី១) ឈ្មោះ ហឺ ក្រោយមកបានស្លាប់ និងកូនទី២) ឈ្មោះ ហួយ។

នៅពេលយោធាខ្មែរក្រហមចូលមកដល់ភូមិខ្ញុំ យោធាខ្មែរក្រហមជាច្រើននាក់បានទៅចងអង្រឹងដេកនៅក្រោមផ្ទះរបស់ខ្ញុំ ព្រោះផ្ទះរបស់ខ្ញុំធំទូលាយ។ ចំណែកខ្ញុំស្នាក់នៅខាងលើផ្ទះ ប៉ុន្តែខ្ញុំមិនហ៊ានរំខានយោធាខ្មែរក្រហមទេ ព្រោះខ្ញុំខ្លាចយោធាទាំងនោះ។ ថ្ងៃមួយនៅក្នុងឆ្នាំ១៩៧៥ ពេលខ្ញុំត្រឡប់មកពីភ្ជួរស្រែនៅពេលយប់ស្រាប់តែមេបញ្ជាការកងទ័ពស្រុកខ្មែរក្រហមឈ្មោះ ហួង ហៅខ្ញុំចុះមកក្រោម។ ខណៈនោះខ្ញុំកំពុងស្លៀកកន្សែង និងខោខ្លី។ ពេលខ្ញុំចុះមកឃើញយោធាខ្មែរក្រហមពីរនាក់កាន់កាំភ្លើងខ្លី រួចបណ្ដើរខ្ញុំទៅមាត់ស្ទឹង ជិតដើមអំពិលទឹកធំមួយដើម។ ខ្ញុំដើរបានបន្តិចយោធាខ្មែរក្រហមបញ្ជាឲ្យខ្ញុំឈប់និងអង្គុយចុះ។ ខ្ញុំនឹកក្នុងចិត្តប្រសិនបើខ្ញុំអង្គុយចុះ យោធាខ្មែរក្រហមបាញ់ជាមិនខាន ព្រោះកាលនោះខ្មែរក្រហមសម្លាប់មនុស្សហើយបណ្ដែតតាមទឹកស្ទឹងទាំងដៃនៅជាប់ចំណង។ យោធាខ្មែរក្រហមសួរខ្ញុំ «អ្នកឯងពាក់ស័ក្តិប៉ុន្មាន?» ខ្ញុំឆ្លើយប្រាប់យោធានោះថា ខ្ញុំមិនមានពាក់ស័ក្តិអ្វីទេ ព្រោះខ្ញុំមិនដែលធ្វើជាទាហាន។ យោធាខ្មែរក្រហមនោះសួរខ្ញុំទៀតថា «តើមិត្តធ្លាប់ធ្វើកងកុម្ម៉ង់ដូរ ដែរឬទេ?» ខ្ញុំក៏ឆ្លើយថា សម័យនោះអាយុដំណាលខ្ញុំ អ្នកណាក៏ធ្លាប់ធ្វើកងកម្ម៉ង់ដូរដែរ។ «ចុះកងកម្ម៉ង់ដូរមិត្តដែលទៅវាយនៅទីណាទេ?» ខ្ញុំក៏ឆ្លើយតាមត្រង់ថា ខ្ញុំទៅវាយនៅស្វាយទោលព្រៃដំរីប្រហែលជាមួយសប្ដាហ៍ដែរ។

ខ្មែរក្រហមគំរាមខ្ញុំថា ប្រសិនជាមិត្តធ្លាប់ធ្វើជាទាហាន ហើយឆ្លើយកុហក យើងដឹងថ្ងៃណានឹងយកខ្ញុំទៅថ្ងៃនោះ។ ខ្ញុំពង្រឹងស្មារតី ហើយតបវិញថា «ប្រសិនជាខ្ញុំធ្លាប់ធ្វើទាហានមែន សូម្បីធ្លាប់ធ្វើរយៈពេល១ថ្ងៃ ក៏បងអាចយកខ្ញុំទៅបានដែរ»។ បន្ទាប់មកយោធាខ្មែរក្រហមក៏ឲ្យខ្ញុំត្រឡប់មកផ្ទះវិញនៅ

ប្រហែលម៉ោងជិត១រំលងអធ្រាត្រ។ មិនបានប៉ុន្មានផង ខ្មែរក្រហមបានជម្លៀសខ្ញុំទៅឃុំបឹងកន្ទួត។ ខ្ញុំរស់នៅឆ្ងាយពីក្រុមគ្រួសារ និងធ្វើការងារយ៉ាងលំបាក។ កាលនោះខ្ញុំរៀបការ និងមានកូនម្នាក់ឈ្មោះ ហឺ មាន អាយុ១ខួប។ កូនខ្ញុំមិនហូបបបរទេ ប្រហែលជាវាឃើញចុងកៅ លាយបន្លែចូលឡើងពណ៌ក្រហម ហើយក្រោយមកវាក៏ស្លាប់ដោយអត់អាហារ។

តមកទៀតខ្មែរក្រហមចាត់តាំងខ្ញុំទៅ ទន្លេសាប រកត្រីសម្រាប់សហករណ៍។ ខ្ញុំធ្វើការនៅទីនោះរយៈពេលប្រាំពីរខែ ទើបអង្គការចាត់តាំងខ្ញុំឲ្យដឹកត្រីពីបឹងទន្លេសាបមកដាក់នៅតាមសហករណ៍វិញ។ ខ្ញុំធ្វើការកងដឹកជញ្ជូនបានរយៈពេលមួយឆ្នាំកន្លះ។ នៅរវាងពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ខ្ញុំនៅតែបររទេះសេះដឹកត្រីពីទន្លេសាបចែកតាមសហករណ៍ដដែល។ ការងារនេះខ្ញុំដឹករៀងរាល់ ២ទៅ ៣ថ្ងៃម្តង។ មិនយូរប៉ុន្មានខ្មែរក្រហមផ្លាស់ខ្ញុំទៅនៅសមរភូមិក្រោយ នៅចាកាបវិញ។ នៅចាកាប យើងទទួលរបបអង្ករមួយកំប៉ុងសម្រាប់សមាជិកគ្នាចំនួន ៨ នាក់។ បន្ទាប់មកខ្មែរក្រហមប្រើខ្ញុំឲ្យជញ្ជូនអង្ករដាក់ឃ្លាំងនៅចន្លោះពីម៉ោង ១១ដល់ម៉ោង ១២យប់។ ដោយសារតែខ្ញុំហូបបុកបានតិចតួច ហើយធ្វើការងារធ្ងន់ទៀតធ្វើឲ្យខ្ញុំចុះខ្សោយ។ ខ្ញុំលីអង្ករចេញពីឡានទី១អស់ លុះចូលដល់ឡានទី ២ ខ្ញុំលីអង្ករបានតែ ២បាវ ប៉ុណ្ណោះស្រាប់តែញ័រជើងដួលទៅលើដី ដោយសារតែហេវហត់ខ្លាំងពេក។ អង្ករដែលខ្ញុំលីក្នុងមួយបាវមានទម្ងន់ដល់ទៅ ១២០គីឡូក្រាម។ ពេលនោះ គណៈស្រុកនៅទីនោះដែលមានចិត្តធម៌បានជួយលើកខ្ញុំ ហើយសួរនាំខ្ញុំនិងឲ្យខ្ញុំសម្រាក។ ខណៈនោះ គណៈស្រុកសួរខ្ញុំពីការហូបចុក។ ខ្ញុំប្រាប់គាត់ថា ប្រធានកងចែកអង្ករមួយកំប៉ុងសម្រាប់សមាជិកចំនួន ៨ នាក់។ បន្ទាប់មក គណៈស្រុកក៏ទៅរករឿងខាងពាណិជ្ជកម្ម។ ចាប់តាំងពីពេលមកទើបយើងទទួលរបបអង្ករមួយកំប៉ុងសម្រាប់មនុស្សពីរនាក់ ហើយថែមទាំងមានអង្ករដំណើប និងស្ករទៀតផង។ ពេលយើងត្រឡប់មកវិញខ្ញុំនិងសមាជិកក្រុម ៨ នាក់សប្បាយចិត្តរហូតដល់ដេកមិនលក់ ព្រោះបានហូបឆ្អែត។ នៅពេលថ្ងៃយើងត្រូវទៅវាយថ្មនៅវាលវង់ ស្តេចយស បន្ទាប់ពីវាយថ្មបានហើយ ទើបយើងដឹកតាមរទេះសេះយកទៅចាក់នៅបំពេញផ្លូវជង្ហុកម្តុំពោធិ៍ ក្នុងមួយថ្ងៃដឹកពីរជើង គឺពេលព្រឹកនិងពេលល្ងាច ។

មួយរយៈក្រោយមក ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យរៀនក្រឡឹង និងផ្សារដែក នៅវត្តបុស្សី ស្ថិតនៅក្នុងស្រុកម៉ោងបុស្សី ខេត្តបាត់ដំបង។ នៅទីនោះខ្ញុំឃើញខ្មែរក្រហមសាងសង់រោងធំៗ និងវែងសម្រាប់ក្រឡឹង និងផ្សារដែក។ នៅចុងឆ្នាំ១៩៧៨ ស្ថានភាពក្នុងប្រទេសមានការប្រែប្រួល ទើបអង្គការបញ្ជូនខ្ញុំឲ្យត្រឡប់មកនៅកាចាបវិញ។

នៅដើមឆ្នាំ១៩៧៩ មុនពេលកងទ័ពវៀតណាមវាយចូលមក អង្គការចាត់តាំងខ្ញុំឲ្យដឹកខោអាវពីឃ្លាំងនៅកាចាបទៅដាក់នៅសាលាគំរូ។ បន្ទាប់ពីដឹកខោអាវរួច អង្គការចាត់តាំងឲ្យដឹកគ្រាប់ពីផ្សារពោធិ៍សាត់មកវិញ។ ក្រោយពីដឹកដល់គោលដៅហើយ អង្គការបានផ្តាច់ស្ពានចោល ទាំងអស់រួចនាំគ្នាឡើងលើភ្នំ។ ខ្ញុំអត់បាយរយៈពេល៣ថ្ងៃ ដូច្នេះក៏បេះស្លឹកថ្នឹង និងស្លឹកជន្ទង់ហូបបំបាត់ភាពស្រេកឃ្លាន។ ខ្ញុំមានបំណងរកផ្លូវរត់ត្រឡប់ក្រោយ ក៏កាប់ដើមឈើជាសញ្ញាចំណាំ។ នៅតាមផ្លូវ ខ្ញុំជួបគណៈស្រុកដឹកនាំកងទ័ពឡើងលើភ្នំ ដែលក្រុមរបស់គាត់កំពុងសម្រាកនៅក្រោមដើមឈើធំៗ។ គណៈស្រុកនោះបានស្រែកហៅខ្ញុំ ធ្វើឲ្យខ្ញុំភិតភ័យយ៉ាងខ្លាំងព្រោះគិតថា ហៅខ្ញុំយកទៅសម្លាប់។ ប៉ុន្តែគណៈស្រុកនោះមិនបានសម្លាប់ខ្ញុំទេ គឺហៅខ្ញុំមកប្រាប់ឲ្យត្រឡប់ទៅផ្ទះជួបប្រពន្ធកូនវិញ ព្រោះរត់មកនេះមិនដឹងគោលដៅទៅទីណាទេ។ ខ្ញុំប្រាប់គាត់ថា «ខ្ញុំរត់ទៅណារួច ព្រោះកងទ័ពស្គាល់ខ្ញុំ»។ គណៈស្រុកប្រាប់ខ្ញុំបន្ថែមថា «ប្រាប់ថា ទទួលបញ្ជាពីអញទៅដឹកគ្រាប់នៅចុងថ្នល់»។ ខ្ញុំក៏ត្រឡប់មកក្រោយវិញ។ ភ្លាមៗនោះស្រាប់តែកងទ័ពខ្មែរក្រហមជាច្រើនចេញមកហើយស្រែកថា «រត់ចូលយួនហើយៗ»។ ខ្ញុំថា ខ្ញុំទទួលបញ្ជាពីបងឲ្យទៅដឹកគ្រាប់នៅចុងថ្នល់។ ទាហានខ្មែរក្រហមក៏ឲ្យខ្ញុំចាកចេញ

និងប្រាប់ថា «បើចឹងទៅឲ្យលឿនហើយប្រញាប់មកវិញ ព្រោះកងទ័ពវៀតណាមចូលដល់ចាកាបហើយ»។ នៅតាមផ្លូវក្នុងព្រៃ ខ្ញុំឃើញសាកសពប្រជាជនមកពីខេត្តស្វាយរៀងជាច្រើន ត្រូវបានខ្មែរក្រហមសម្លាប់ ព្រោះកម្មាភិបាលខ្មែរក្រហមនៅខេត្តពោធិ៍សាត់មិនចូលចិត្តប្រជាជនមកពីបូព៌ាទេ។ ខ្ញុំធ្វើដំណើរតាមសាលាគំរូឡើងដល់ថ្នល់ជាតិទើបជួបកងទ័ពវៀតណាមជាច្រើនហើយកងទ័ពទាំងនោះមកព័ទ្ធជុំវិញខ្ញុំ បន្ទាប់មកបានហុចខិតបណ្ណឲ្យខ្ញុំអាន។ ខ្ញុំភិតភ័យខ្លាំងណាស់ ព្រោះខ្លាចកងទ័ពវៀតណាមអាកខ្ញុំជាមួយធាងត្នោត និងវះពោះច្រកស្មៅ។ ខ្ញុំអានអក្សរក្នុងខិតបណ្ណនោះស្ទើរតែតែមិនរួច ដែលសរសេរថា «បងប្អូនជនរួមជាតិ កងទ័ពវៀតណាមមកជួយបងប្អូនហើយ សូមបងប្អូនកុំភិតភ័យ» ប៉ុន្តែខ្ញុំនៅតែភ័យញ័រដៃជើង។ កងវៀតណាមមិនបានធ្វើបាបខ្ញុំទេ។ ខ្ញុំបន្តដំណើរមកដល់ចម្ការមួយ ក៏ជួបបងប្រុស ហើយបងរបស់ខ្ញុំក៏បេះឪឡឹកឲ្យខ្ញុំហូប។ ដោយសារឃ្លានពេក ខ្ញុំហូបឪឡឹកទាំងសម្បក។ ក្រោយមក ខ្ញុំជួបជាមួយប្រពន្ធកូន។

រឿងរ៉ាវដែលខ្ញុំចងចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហម គឺខ្ញុំឃើញខ្មែរក្រហមសម្លាប់បងប្អូនរបស់ខ្ញុំ និងមិត្តរបស់ខ្ញុំផ្ទាល់ភ្នែក។ នៅពេលខ្ញុំមានអាហារហូបចុកគ្រប់គ្រាន់ ខ្ញុំតែងនឹកឃើញដល់របបខ្មែរក្រហម។ ខ្ញុំធ្លាប់បានចូលរួមស្តាប់សវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុន្តែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដូចជា នួន ជា បែរជាឆ្លើយថាមិនដឹងថាមានការសម្លាប់មនុស្សដែលធ្វើឲ្យខ្ញុំមិនជឿ នួន ជា និងមិនអាចទទួលយកទេ។ ការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យជាប់ពន្ធនាគារអស់មួយជីវិត គឺធ្វើឲ្យខ្ញុំពេញចិត្ត ព្រោះវាគឺជាយុត្តិធម៌ និងជាសំណងសម្រាប់ប្រជាជនកម្ពុជាទូទាំងប្រទេស ក៏ដូចជាការចងក្រងឯកសារទុកឲ្យកូនចៅជំនាន់ក្រោយបានដឹង។



ដំណាំចេកដាំនៅក្បែរផ្ទះរបស់ ហែម ហឿន ស្ថិតនៅភូមិព្រៃតាគង់ ឃុំអន្លង់វិល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ (ម៉ូសា ហាទីន/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឡុក អួន កងចល័តលើកទំនប់ម្រេច

ផាត ពន្លក



ឡុក អួន អាយុ៦៨ឆ្នាំ (ឆ្នាំ២០២២) រស់នៅភូមិក្រាំងម្តេង ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឡុក អួន អាយុ៦៨ឆ្នាំ (ឆ្នាំ២០២២) រស់នៅភូមិក្រាំងម្តេង ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត។ ខ្ញុំមានបងប្អូន ៦នាក់។ កាលពីកុមារខ្ញុំចូលរៀនដល់ត្រឹមថ្នាក់ទី៦ ក្នុងសង្គមចាស់ នៅសាលានៅក្នុងភូមិ។ នៅពេលនោះខ្ញុំបានឈប់រៀនមកជួយធ្វើការងារឪពុកម្តាយនៅផ្ទះ ដោយសារគ្រួសារខ្ញុំមានជីវភាពក្រីក្រខ្លាំង។

នៅឆ្នាំ១៩៧០បានកើតមានរដ្ឋប្រហារ និងបានផ្លាស់ប្តូរទៅជារបបសាធារណរដ្ឋខ្មែរ ដែលគ្រប់គ្រងដោយ លន់ នល់។ ប៉ុន្តែការផ្លាស់ប្តូររបបដឹកនាំបានបន្តរឲ្យមានភាពវឹកវរយ៉ាងខ្លាំងនៅក្នុងភូមិ។ នៅពេលនោះ មានកងទ័ពរំដោះខ្មែរក្រហមជាច្រើនបានចូលមកក្នុងភូមិដាច់ស្រយាលដើម្បីឃោសនា ចំណែកមន្ត្រីរដ្ឋការ និងគ្រូបង្រៀនបានរត់ប្រមូលផ្តុំគ្នានៅតាមទីប្រជុំជនដើម្បីត្រៀមទប់ទល់នឹងកងទ័ពរំដោះខ្មែរក្រហម។ ក្រោយមកក៏មានការវាយប្រយុទ្ធគ្នារវាងកងទ័ពរំដោះខ្មែរក្រហម និងកងទ័ព លន់ នល់ ធ្វើឲ្យមន្ត្រីរដ្ឋការ និងគ្រូបង្រៀនរត់គេចខ្លួនពីភូមិស្រុក។

នៅឆ្នាំ១៩៧២ ខ្ញុំនិងក្រុមគ្រួសារបានរស់នៅ និងធ្វើស្រែចម្ការនៅក្នុងភូមិដដែល។ រយៈពេលមួយឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានបង្កើតសហករណ៍រួមនៅក្នុងភូមិដែលដឹកនាំដោយ សមមិត្តឌុល។ នៅពេលនោះ យោធាខ្មែរក្រហមជាច្រើនបានចូលមកស្នាក់នៅក្នុងភូមិរបស់ខ្ញុំរយៈពេល៧ថ្ងៃ ដើម្បីត្រៀមចេញទៅវាយប្រយុទ្ធនៅសមរភូមិមុខ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានឡើងកាន់អំណាច។ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យចូលធ្វើការងារនៅក្នុងកងចល័ត និងបញ្ជូនទៅលើកទំនប់ម្រេច និងត្រពាំងបឹង។ ចំណែកនៅរដូវធ្វើស្រែចម្ការ ប្រធានកងបានដកខ្ញុំឲ្យមកធ្វើការងារដក និងស្ទូងនៅតាមវាលស្រែវិញ។

បន្ទាប់ពីចប់ការងារដកស្ទូង ប្រធានកងបានបញ្ជូនខ្ញុំឲ្យទៅលើកទំនប់ម្រេចដដែល ដោយប្រើឲ្យខ្ញុំរែកដីជាមួយបង្គីដែលមានទំហំធំៗ។ ខ្ញុំត្រូវរែកដីទៅចាក់ក្បាលទំនប់ខ្ពស់ ដែលសម្លឹងពីលើក្បាលទំនប់ឃើញមនុស្សធ្វើការងារនៅខាងក្រោមតូចៗ។ នៅ

ទីនោះ ខ្ញុំឃើញមនុស្សស្លាប់ជាបន្តបន្ទាប់ដោយសារមានជំងឺ ដោយសារខ្វះខាតថ្នាំពេទ្យសម្រាប់ព្យាបាលជំងឺ ដូច្នេះក្រុមគ្រូពេទ្យខ្មែរក្រហមបានយកថ្នាំអាចម៍ទន្សាយ ទឹកដូងមកធ្វើជាសេរ៉ូម សម្រាប់ចាក់ឲ្យអ្នកជំងឺនៅតាមកងចល័ត។ ពេលខ្លះ ខ្ញុំឃើញឈ្លបខ្មែរក្រហមបានមកចាប់ចងមនុស្សដែលកំពុងធ្វើការងាររួចបណ្ដើរជាជួរចេញទៅបាត់។ ខ្ញុំមិនចាំឈ្មោះអ្នកដែលត្រូវបានឈ្លបខ្មែរក្រហមចាប់ខ្លួនទាំងនោះទេ។ នៅពេលខ្ញុំឃើញទិដ្ឋភាពបែបនេះ ខ្ញុំតក់ស្លុតយ៉ាងខ្លាំង ប៉ុន្តែទោះបីយ៉ាងណាខ្ញុំនៅតែខិតខំធ្វើការងារជូនខ្មែរក្រហម។ ខ្មែរក្រហមបានឲ្យខ្ញុំហូបបបរបីពេលក្នុងមួយថ្ងៃ ដែលមិនគ្រប់គ្រាន់សម្រាប់ខ្ញុំ ឡើយ និងធ្វើឲ្យខ្ញុំហត់ហេវយ៉ាងខ្លាំង។ មិនត្រឹមតែប៉ុណ្ណោះ ខ្មែរក្រហមបានហាមខ្ញុំនិងប្រជាជនមិនឲ្យដើររកអាហារដើម្បីមកហូបបន្ថែមឡើយ ដូចជា មាន់ដែលយើងចិញ្ចឹមបាន។ នៅសម័យនោះ ខ្មែរក្រហមបានលុបបំបាត់សាសនា វត្តអារាម និងទំនៀមទម្លាប់ប្រពៃណី។

នៅឆ្នាំ១៩៧៩ កងទ័ពខ្មែរក្រហមបានវាយចូលមក និងមានការវាយប្រយុទ្ធគ្នាជាមួយយោធាខ្មែរក្រហម។ ដោយសារខ្លាចមានគ្រោះថ្នាក់ ខ្ញុំធ្វើដំណើរដោយថ្មើរជើងសំដៅទៅលើភ្នំកាគខាងជើង។ នៅតាមផ្លូវខ្ញុំបានឃើញសាកសពប្រជាជនជាច្រើន។ បន្ទាប់ពីវាយប្រយុទ្ធគ្នាបានស្ងប់ស្ងាត់ ទើបខ្ញុំវិលត្រឡប់មករស់នៅភូមិកំណើត និងប្រកបរបរធ្វើស្រែរហូតដល់សព្វថ្ងៃ។



បរិវេណផ្ទះរបស់ ឡុក អួន នៅភូមិក្រាំងម្ដេង ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សនៃវិទ្យាល័យ សម្ដេចតេជោ ហ៊ុន សែន សង្កើប ចូលរួមវេទិកាថ្នាក់រៀន

## ចុងសប្ដាហ៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ៖ «សង្គ្រាមដែលកងទ័ពរំដោះខ្មែរក្រហមប្រយុទ្ធជាមួយទាហាន លន់ នល់»

*ទូច វណ្ណាក និង លី ដេវីត*









នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សវិទ្យាល័យ សម្ដេចតេជោ ហ៊ុន សែន សង្កើប ថ្នាក់វិទ្យាសាស្ត្រពិត ចំនួន ៥៥នាក់ បានមកចូលរួមវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សវិទ្យាល័យ សម្ដេចតេជោ ហ៊ុន សែន សង្កើប ថ្នាក់វិទ្យាសាស្ត្រពិត ចំនួន៥៥នាក់បានមកចូលរួមវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ វេទិកាថ្នាក់រៀននេះធ្វើឡើងក្នុងគោលបំណងបង្កើនចំណេះដឹងដល់សិស្សានុសិស្សស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជានាពេលអនាគត។

ជាកិច្ចចាប់ផ្តើម លោក ផេង ពង្ស៉ារ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ចាប់ផ្តើមធ្វើបទបង្ហាញរបស់ខ្លួនស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយបានផ្តោតទៅលើព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម រួមមាន ការធ្វើរដ្ឋប្រហាររបស់ លន់ នល់, ការផ្ទុះសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជន និងការកាប់សម្លាប់ទៅលើប្រជាជន។ ជាចុងក្រោយលោក ផេង ពង្ស៉ារ៉ាស៊ី ពន្យល់បន្ថែមទៅលើនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងប្រល័យពូជសាសន៍។

បន្ទាប់ពីការធ្វើបទបង្ហាញរបស់វាគ្មិន បានបញ្ចប់, លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តដឹកនាំកិច្ចពិភាក្សាទៅលើប្រធានបទការផ្ទុះឡើងសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ មិនយូរប៉ុន្មានបន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើង។ កងទ័ពរំដោះខ្មែរក្រហមបានធ្វើសង្គ្រាមប្រឆាំងទាហាន លន់ នល់។ សង្គ្រាមដែលកងទ័ពរំដោះខ្មែរក្រហមបានប្រយុទ្ធជាមួយទាហាន លន់ នល់ គឺរួមមាន៖ សង្គ្រាមផ្លូវគោក សង្គ្រាមផ្លូវទឹក និងសង្គ្រាមប្រជាជន។ នៅពាក់កណ្តាលឆ្នាំ១៩៧០ កងទ័ពរំដោះខ្មែរក្រហមចូលមកដល់ភូមិសាស្ត្រនានានៅក្នុងខេត្តកំពង់ចាម។ ទាហាន លន់ នល់ បានប្រើប្រាស់យន្តហោះទម្លាក់គ្រាប់បែកនៅភូមិសាស្ត្រណាដែលមានវត្តមានកងទ័ពរំដោះខ្មែរក្រហមឈរជើង។ កងទ័ពរំដោះខ្មែរក្រហមអាចបានត្រឹមតែព្យាយាមបាញ់កាំភ្លើងពីដីសំដៅទៅលើយន្តហោះទម្លាក់គ្រាប់បែករបស់ទាហាន លន់ នល់ និងបានដកកងកម្លាំងរបស់ខ្លួនចេញពីភូមិសាស្ត្រទម្លាក់គ្រាប់បែក។ បន្ទាប់ពីការទម្លាក់គ្រាប់បែក ទាហានថ្មើរជើង លន់ នល់ ត្រូវបានបញ្ជូនទៅកាន់ភូមិសាស្ត្រទម្លាក់គ្រាប់បែក និងបន្តឈរជើងនៅទីនោះ។

ចន្លោះពីឆ្នាំ១៩៧១ និង១៩៧២ កងទ័ពរំដោះខ្មែរក្រហមធ្វើសង្គ្រាមផ្លូវគោកជាមួយទាហាន លន់ នល់ ដោយបានបើកការវាយប្រហារទៅលើបន្ទាយ លន់ នល់ និងរំដោះតំបន់ផ្សេងៗជាបន្តបន្ទាប់។ ចាប់តាំងពីឆ្នាំ១៩៧៣ ទាហាន លន់ នល់ ត្រូវបានដាក់ឲ្យឈរជើងនៅព្រំប្រទល់ទីរួមខេត្តកំពង់ចាម ដើម្បីត្រៀមប្រយុទ្ធតទល់ជាមួយកងទ័ពរំដោះខ្មែរក្រហមដែលបានដាក់កម្លាំងឡោមព័ទ្ធទីរួមខេត្ត។ ដោយមិនអាចឆ្លងកាត់តំបន់រំដោះតាមផ្លូវគោកបាន ទាហានលន់ នល់ ប្រើប្រាស់ផ្លូវទឹកតាមដងទន្លេមេគង្គ ដើម្បីដឹកសម្ភារសឹក និងស្បៀងចូលទៅទីរួមខេត្តកំពង់ចាម។ កងទ័ពរំដោះខ្មែរក្រហមតែងតែបើកការវាយប្រហារដោយបានបណ្តែតគ្រាប់បែកបង្កប់កាត់ទន្លេ និងបាញ់ចេញពីច្រាំងទន្លេ។ កងទ័ពរំដោះខ្មែរក្រហមធ្វើសង្គ្រាមផ្លូវទឹកជាមួយទាហានជើងទឹក លន់ នល់ រហូតដល់ឆ្នាំ១៩៧៥។ បន្ថែមលើបទបង្ហាញដែលលោក ស៊ាង ចិន្តា លើកឡើងខាងលើនេះ កងទ័ពរំដោះខ្មែរក្រហមក៏បានធ្វើសង្គ្រាមប្រជាជនក្នុងគោលបំណងរក្សាការគាំទ្ររបស់ប្រជាជនរស់នៅក្នុងមូលដ្ឋានចំពោះការធ្វើសង្គ្រាមយកឈ្នះទាហាន លន់ នល់។



នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ថ្នាក់វិទ្យាសាស្ត្រពិត ចំនួន ៥៥នាក់ បានមកចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាចុងបញ្ចប់នៃវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះ សិស្សទាំងអស់បានចុះទស្សនកិច្ចសិក្សាទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ និងការជួបសន្ទនាដោយផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ នៅពេលមកដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍លោក តុង សុភា និងអ្នកស្រី ប៊ុន ឈួមឡោម អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលស្វាគមន៍សិស្សានុសិស្ស និងនិយាយប្រាប់អំពីបទពិសោធន៍ និងការបាត់បង់សាច់ញាតិក្នុងរបបខ្មែរក្រហម។

បន្ទាប់ពីវេទិកាថ្នាក់រៀនបានបញ្ចប់ យុវសិស្សចូលរួមបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

សិស្ស **ធីម ស្រីពីន** រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិតនៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប បង្ហាញទស្សនយល់ឃើញរបស់ខ្លួនថា «ខ្ញុំសប្បាយចិត្តនៅពេលមកដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ខ្ញុំយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម រួមមាន ប្រវត្តិមេដឹកនាំខ្មែរក្រហម, ការធ្វើការងារហួសកម្លាំង, ការបែកបាក់គ្រួសារ និងការបាត់បង់សាច់ញាតិ។ ខ្ញុំនឹងយកចំណេះដឹងដែលទទួលបានពីវេទិកាទៅចែករំលែកជាមួយមិត្តភក្តិ និងសាកសួរយាយអំពីបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហម»។

សិស្ស **នៅ ស្រីស** រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិតនៃវិទ្យាល័យសម្តេចតេជោ ហ៊ុនសែន សង្កើប លើកឡើងថា «វេទិកាថ្នាក់រៀនចុងសប្តាហ៍គឺល្អសម្រាប់ខ្ញុំដែលកំពុងរៀនថ្នាក់ទី១២ និងត្រៀមប្រឡង ពីព្រោះខ្ញុំទទួលបានចំណេះដឹងច្រើនបន្ថែមទៀតលើមុខវិជ្ជាដែលខ្ញុំបានរៀននៅក្នុងថ្នាក់»។

សិស្ស **ខួន សុភា** រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិតនៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប និយាយថា «ការឃើញរូបភាព ការស្តាប់បទបង្ហាញរបស់លោកគ្រូ ការស្តាប់បទពិសោធន៍របស់អ៊ំៗដែលឆ្លងកាត់របបខ្មែរក្រហម និងការចុះទៅដល់ទីតាំងចេតិយរំឭក ធ្វើឲ្យខ្ញុំយល់ដឹងអំពីទុក្ខលំបាក និងវិនាសកម្មបន្សល់ទុកពីរបបខ្មែរក្រហម។ ខ្ញុំនឹងនាំយកចំណេះដឹងដែលខ្ញុំទទួលបានពីវេទិកានេះ ទៅប្រាប់មិត្តភក្តិផ្សេងទៀតដែលមិនបានមកចូលរួមវេទិកានេះ»។







នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ថ្នាក់វិទ្យាសាស្ត្រពិត ចំនួន ៥៥នាក់ បានមកចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ក្រោមប្រធានបទ៖ «ការអប់រំកុមារក្នុងរបបខ្មែរក្រហម»

***លី ដេវីត និង ទូច វណ្ណេត***






នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការអប់រំកុមារក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ចំនួន៥៥នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ«ការអប់រំកុមារក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ចំនួន ៥៥នាក់ ។ វេទិកាអប់រំសហគមន៍នេះ រៀបចំធ្វើនៅក្រោមផ្ទះប្រជាជនដែលជាអតីតកន្លែងស្នាក់នៅ និងបង្រៀនកុមារក្នុងរបបខ្មែរក្រហម ក្នុងគោលបំណងដើម្បីបង្កើតឱកាសឲ្យមានកិច្ចសន្ទនាអន្តរជំនាន់រវាងអ្នកកើតមុន និងក្រោយរបបខ្មែរក្រហម និងជំរុញឲ្យមានការយល់ដឹងអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងកម្រិតសហគមន៍ក្នុងរបបខ្មែរក្រហម។





នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការអប់រំកុមារក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ចំនួន៥៥នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាកិច្ចចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានធ្វើបទបង្ហាញស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗរួមមាន៖ រដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០, ការផ្ទុះឡើងសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, និងការឡើងកាន់អំណាចរបស់ខ្មែរក្រហម ។ បន្ទាប់ពីបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបំបាត់វិស័យអប់រំជាផ្លូវការ។ ការអប់រំត្រូវបានធ្វើឡើងនៅក្រៅសាលារៀនឬនៅក្រោមផ្ទះប្រជាជន។ គ្រូបង្រៀនគឺជាកសិករដែលមានចំណេះដឹងតិចតួច។ ការអប់រំគឺជាការរៀនសូត្រ និងបំពាក់បំប៉នឧនយោបាយ។ ខ្មែរក្រហមចង់ឲ្យកុមារធ្វើការជាជាងរៀនសូត្រ។ កុមារនៅក្នុងរបបខ្មែរក្រហមត្រូវបានបំបែកចេញពីគ្រួសារ និងដាក់នៅក្នុងកងកុមារដើម្បីធ្វើការងារ និងរៀនសូត្រជាមួយគ្រូបង្រៀនរបស់ខ្លួន។

**មួង សុម៉ាលី** អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអតីតកងកុមារក្នុងរបបខ្មែរក្រហម បានរំឭកទៅកាន់យុវសិស្សដែលចូលរួមអំពីបទពិសោធន៍របស់ខ្លួនថា «ខ្ញុំមានអាយុប្រហែល១០ឆ្នាំ។ ដូច្នេះ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅក្នុងកងកុមារ។ ខ្ញុំត្រូវបានបញ្ជូនទៅរៀនសូត្រនៅក្នុងកងកុមារ ដែលមានមិត្តនារី ឈាង គឺជាគ្រូបង្រៀនកុមារមូលដ្ឋាន។ កងកុមារបែងចែកជាក្រុមកុមារា និងក្រុមកុមារី ដែលមានកុមារទាំងអស់ប្រមាណ ២០-៣០នាក់។ នៅពេលព្រឹក ខ្ញុំនិងកុមារផ្សេងទៀត ត្រូវក្រោកនៅម៉ោង៦ព្រឹកដើម្បីទៅរៀនជាមួយអ្នកគ្រូ ឈាង នៅក្រោមផ្ទះរបស់អ្នកភូមិ។ អ្នកគ្រូ ឈាងបង្រៀនអក្សរ

និងលេខ រហូតដល់ម៉ោង៩ ទើបខ្ញុំទៅធ្វើពលកម្ម ដូចជា សែងអាចម៍គោចេញពីក្រោមផ្ទះអ្នកភូមិ និង ដើរកាត់ដើមទន្ទ្រានខែត្រដើម្បីយកមកធ្វើជីដាក់ស្រូវ។ រហូតដល់ម៉ោង១២ថ្ងៃត្រង់ អ្នកគ្រូ ឈាង ដឹកនាំកុមារទាំងអស់ ទៅហូបបាយនៅរោងបាយសហករណ៍។ បន្ទាប់ពីសម្រាកថ្ងៃត្រង់បានបន្តិច កុមារទាំងអស់ត្រូវបន្តសែងអាចម៍គោយកមកដាក់ទុកនៅកន្លែងធ្វើជី។ នៅពេលនោះ មិនទាន់មានសាលា និងម៉ោងសិក្សាជាប់លាប់ទេ។ ការបង្រៀនរបស់អ្នកគ្រូ ឈាង គឺគាត់ដើរបង្រៀនសិស្សចល័តនៅតាមផ្ទះរបស់អ្នកភូមិ»។

បន្ទាប់ពីការចែករំលែកបទពិសោធន៍នៅក្នុងកងកុមារ និងការរៀនសូត្រនៅក្នុងរបបខ្មែរក្រហមរបស់ សុម៉ាលី បានបញ្ចប់ សិស្សបានចោទសួរសំណួរជាច្រើនទាក់ទងរបបខ្មែរក្រហម និងការអប់រំក្នុងរបបខ្មែរក្រហមដែលចំណាយអស់រយៈពេលជិតមួយម៉ោង។

កម្មវិធីបន្ទាប់គឺការចុះទស្សនកិច្ចសិក្សាទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ ដើម្បីឈ្វេងយល់បន្ថែមទៅលើរឿងរ៉ាវរបស់ជនរងគ្រោះ បទពិសោធន៍របស់អ្នករស់រានមានជីវិត និងទីតាំងសម្លាប់ក្នុងរបបខ្មែរក្រហម និងទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដើម្បីឈ្វេងយល់អំពីការងារស្រាវជ្រាវចងក្រង និងអប់រំផ្សព្វផ្សាយប្រវត្តិសាស្ត្រខ្មែរក្រហម។

ចុងបញ្ចប់នៃវេទិកាអប់រំសហគមន៍នេះ សិស្សានុសិស្សបង្ហាញទស្សនយល់ឃើញរបស់ខ្លួនដូចខាងក្រោម ៖

សិស្ស ឡាយ សុខលាប ថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ទឹង បានចែករំលែកចំណេះដឹងដែលខ្លួនទទួលបានថា «ខ្ញុំមានអារម្មណ៍សប្បាយចិត្តយ៉ាងខ្លាំង ដែលទទួលបានឱកាសចូលរួមវេទិកាអប់រំសហគមន៍ ពីព្រោះខ្ញុំទទួលបានចំណេះដឹងនិងបទពិសោធន៍ថ្មីៗពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលបាននាំប្រទេសកម្ពុជាធ្លាក់ក្នុងវិនាសកម្ម។ នៅថ្ងៃនេះ ខ្ញុំដឹងអំពីការអប់រំកុមារក្នុងរបបខ្មែរក្រហម ដែលធ្វើឡើងនៅក្រោមផ្ទះប្រជាជន។ ការរៀនសូត្រនៅពេលនោះ គឺផ្តោតលើការធ្វើការងារជាជាងការរៀន។ ខ្ញុំនឹងខិតខំប្រឹងប្រែងរៀនសូត្របន្ថែមទៀត និងចូលរួមកសាងប្រទេសជាតិ។ នាពេលបច្ចុប្បន្ននេះ ខ្ញុំមានឱកាសរៀនសូត្រពេញលេញ ប៉ុន្តែចាស់ៗជំនាន់មុនមិនមានឱកាសនោះឡើយ ដោយសារតែសង្គ្រាម និងរបបខ្មែរក្រហម»។

សិស្ស អៀវ សុម៉ានី ថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ទឹង បានលើកឡើងថា «ខ្ញុំពេញចិត្តចំពោះវេទិកាអប់រំសហគមន៍នេះដែលអាចឲ្យខ្ញុំយល់ដឹងអំពីរបបខ្មែរក្រហមរួមមានជីវិតប្រចាំថ្ងៃ, ការធ្វើការងារហួសកម្លាំង, ការអប់រំ, ការបង្អត់អាហារ, និងការស្លាប់បាត់បង់ជីវិតរបស់ប្រជាជនក្នុងរបបខ្មែរក្រហម។ ខ្ញុំក៏ទទួលបានឱកាសស្តាប់ពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំពិតជាអាណិតប្រជាជនក្នុងសម័យនោះយ៉ាងខ្លាំង»។



នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការអប់រំកុមារក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ទឹង ចំនួន៥៥នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការអប់រំកុមារក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ទឹ ចំនួន៥៥នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្ស សាន ស្រីពៅ ថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ទឹ ចែករំលែកចំណេះដឹងថ្មីក្នុងរបបខ្មែរក្រហមដែលខ្លួនទទួលបានពីវេទិកាអប់រំសហគមន៍នេះថា «វេទិកានេះធ្វើឲ្យខ្ញុំទទួលបានអារម្មណ៍ដូចរស់ក្នុងស្ថានភាពរបស់កុមារក្នុងរបបខ្មែរក្រហម ដែលខ្វះភាពកក់ក្តៅ ខ្វះការអប់រំ និងការហូបចុកមិនគ្រប់គ្រាន់។ នេះគឺជាចំណេះដឹងថ្មីដែលខ្ញុំទទួលបានពីវេទិកានេះ»។








# សិស្សានុសិស្សវិទ្យាល័យ ឈើន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍

## ក្រោមប្រធានបទ «សង្គ្រាមរវាង លន់ នល់ និងខ្មែរក្រហម និង ការឡើងកាន់អំណាចរបស់ខ្មែរក្រហម»

**ទូច វណ្ណាត**







*សិស្សានុសិស្សមកពីវិទ្យាល័យ ឈើន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ក្រោមប្រធានបទ «សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម និង ការឡើងកាន់អំណាចរបស់ខ្មែរក្រហម កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។ (លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលជាសាខាមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើ«សង្គ្រាមរវាងលន់នល់ និងខ្មែរក្រហម និងការឡើងកាន់អំណាចរបស់ខ្មែរក្រហម។» វេទិកាថ្នាក់រៀនជាលើកទី ២ ក្នុងខែមីនា ឆ្នាំ២០២៣ នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់សិស្សានុសិស្សពីប្រវត្តិសាស្ត្រខ្មែរក្រហម និងស្តាប់អំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាកិច្ចចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈ-មណ្ឌលឯកសារខេត្តកំពង់ចាម ធ្វើបទបង្ហាញរបស់ខ្លួនស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយបានផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ រួមមានរដ្ឋប្រហារលន់នល់ ការផ្ទុះឡើងនូវសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម និងការឡើងកាន់អំណាចរបស់ខ្មែរក្រហម។



សិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ក្រោមប្រធានបទ «សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម និង ការឡើងកាន់អំណាចរបស់ខ្មែរក្រហម កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។
( លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

លោក ស៊ាង ចិន្តា បានបន្តពន្យល់អំពីបរិបទប្រវត្តិសាស្ត្រ តាមរយៈការចាក់បញ្ចាំងវីដេអូរឯកសារ និងការបង្ហាញឯកសាររូបថត ទៅកាន់សិស្សានុសិស្សចូលរួម។ ជាចុងក្រោយ លោកស៊ាង ចិន្តា ពន្យល់បន្ថែមទៅលើនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងប្រល័យពូជសាសន៍។

សិស្សឈ្មោះ ប៉េង អេងលាង ថ្នាក់ទី១១-អេ (A) ផ្នែកវិទ្យាសាស្ត្រពិតវិទ្យាល័យ ឈីន លាន ហាន់ជ័យ បានចូលរួមវេទិកាថ្នាក់រៀនលើកឡើងថា «ការស្តាប់បទបង្ហាញរបស់លោកគ្រូ ការចាក់បញ្ចាំងវីដេអូរឯកសារ និងការឃើញរូបភាព ផ្តល់ចំណេះដឹងថ្មីៗដល់ខ្ញុំយ៉ាងច្រើន។ ខ្ញុំមានការអាណិតអាសូរដល់ប្រជាជនខ្មែរដែលឆ្លងកាត់សង្គ្រាម និងរបបខ្មែរក្រហម ដែលបានបន្សល់ទុកវិនាសកម្ម និងការបំផ្លិចបំផ្លាញដល់ប្រទេសជាតិ។ ខ្ញុំនឹងនាំយកអ្វីដែលខ្ញុំទទួលបានពីវេទិកានេះទៅប្រាប់មិត្តភក្តិផ្សេងទៀត និងសួរលោកយាយ លោកតា របស់ខ្ញុំដែលបានឆ្លងកាត់ពេលនោះ»។

កម្មវិធីបន្ទាប់ គឺការចុះទៅកាន់ទីតាំងប្រវត្តិសាស្ត្រ គឺវត្តរកាគយ គឺជាអតីតបន្ទាយទាហាន លន់ នល់ និងទីតាំងសមរភូមិក្តៅរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។

បន្ទាប់ពីរដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ អ្នកភូមិជាច្រើនចូលរួមបាតុកម្មដង្ហែទៅកាន់ទីរួមខេត្តកំពង់ចាម និងបន្តទៅទីក្រុងភ្នំពេញ។ នៅចុងឆ្នាំ១៩៧០ កងទ័ពរំដោះខ្មែរក្រហមវាយយកបានភូមិសាស្ត្រខេត្តកំពង់ចាម។ ទាហានថ្មើរជើង លន់ នល់ ត្រូវបានបញ្ជូនមកឈរជើងនៅបន្ទាយទាហាន ស្ថិតនៅក្នុងវត្តរកាគយដើម្បីទប់ទល់ជាមួយកងទ័ពរំដោះខ្មែរក្រហម។ សមរភូមិប្រយុទ្ធរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម បានផ្ទុះឡើងទាំងផ្លូវគោកនិងផ្លូវទឹក។ នៅឆ្នាំ១៩៧២ បន្ទាយទាហាន លន់ នល់ នៅវត្តរកាគយត្រូវបានវាយបែកដោយកងទ័ពរំដោះខ្មែរក្រហម។ ទាហាន លន់ នល់ ត្រូវបានដកមកឈរជើងនៅកោះរកាដើម្បីប្រយុទ្ធជាមួយកងទ័ពរំដោះខ្មែរក្រហមដែលបានបន្តរំដោះទីតាំងជាច្រើនជុំវិញទីរួមខេត្តកំពង់ចាម។ បន្ទាប់មក វត្តរកាគយ ត្រូវ





សិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ក្រោមប្រធានបទ «សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម និង ការឡើងកាន់អំណាចរបស់ខ្មែរក្រហម កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។
( លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

បានប្រើប្រាស់ទៅជាកន្លែងភស្តុភាររបស់កងទ័ពរំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាម ត្រូវឡោមព័ទ្ធជុំវិញដោយកងទ័ពរំដោះខ្មែរក្រហម។ ទាហាន លន់ នល់ ប្រើប្រាស់ផ្លូវទឹក ដែលជាច្រកចេញចូលសំខាន់ក្នុងការដឹកជញ្ជូនសម្ភារសឹក ស្បៀង និងប្រជាជននៅទីរួមខេត្តកំពង់ចាម ចេញទៅកាន់ទីក្រុងភ្នំពេញ តាមរយៈនាវាម៉ារីនទាហាន លន់ នល់។ ការចេញចូលតាមផ្លូវទឹកនេះត្រូវបានកងទ័ពរំដោះខ្មែរក្រហមវាយប្រហារជាបន្តបន្ទាប់។

សិស្សឈ្មោះ អែម ប៊ុនរុង ថ្នាក់ទី១១- អេ(A) ផ្នែកវិទ្យាសាស្ត្រពិតវិទ្យាល័យ ឈីន លាន ហាន់ជ័យ បានចុះទៅដល់ទីតាំងប្រវត្តិសាស្ត្រជាលើកទី១ ចែករំលែកថា «នៅពេលលោកគ្រូរំឭកថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាថ្ងៃដែល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីអំណាច។ ខ្ញុំហាក់ដូចជាត្រូវបានពញ្ញាក់ស្មារតី និងរំឭកអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់នេះដែលបណ្តាលឲ្យមានការកកើតឡើងនូវសង្គ្រាម និងរបបខ្មែរក្រហម»។ សិស្ស អ៊ែម ប៊ុនរុង បានបន្ត «ខ្ញុំចុះទៅទីតាំងវត្តរការគយ ស្ថិតនៅតាមបណ្តោយទន្លេមេគង្គ គឺជាអតីតសមរភូមិក្តៅរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ ខ្ញុំបានដឹងរឿងរ៉ាវជាច្រើនកើតឡើងនៅវត្តរការគយ។ បច្ចុប្បន្នវត្តរការគយគឺមានសភាពស្ងប់ស្ងាត់អមជាមួយទេសភាពទន្លេយ៉ាងត្រជាក់ ក៏ប៉ុន្តែកាលពី៥៣ឆ្នាំមុនវត្តរការគយនេះគឺជាសមរភូមិប្រយុទ្ធគ្នា»។

ការចងចាំអំពីជនរងគ្រោះក្នុងរបបខ្មែរក្រហម និងការស្តាប់អំពីបទពិសោធន៍ជីវិតរបស់អ្នករស់រានមានជីវិតគឺជាផ្នែកសំខាន់មួយនៃវេទិកាថ្នាក់រៀននេះ៖

សិស្សានុសិស្សចូលរួមទាំងអស់បានបន្តចុះទៅកាន់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ដែលស្ថិតនៅកណ្តាលវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ នៅពេលទៅដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍នេះ សិស្សទាំងអស់ត្រូវបានបែងចែកជា២ក្រុម ដែលក្រុមនីមួយៗមានឱកាសជួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

សិស្សក្រុមទី១) គឺត្រូវជួបជាមួយលោកតុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានភូមិចំការសាមសិប។ លោក តុង សុភា បាននិយាយប្រាប់សិស្សក្រុម ទី១អំពីទីតាំងសម្លាប់ប្រជាជននៅក្នុងឃុំគគរក្នុងរបបខ្មែរក្រហម, បទពិសោធន៍ និងការបាត់បង់ឪពុកនិងគោលបំណងនៃការសាងសង់ចេតិយរំឭកនេះឡើង។

ចំណែកឯ សិស្សក្រុមទី ២ គឺត្រូវជួបជាមួយឈ្មោះ មួង ស៊ាងលី អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ៊ំស្រី មួង ស៊ាងលី គឺជាអតីតកងចល័តនារី និងបានចែករំលែកទៅកាន់សិស្សក្រុមទី ២ អំពីបទ



សិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ក្រោមប្រធានបទ «សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម និង ការឡើងកាន់អំណាចរបស់ខ្មែរក្រហម កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។
( លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

ពិសោធន៍ ការធ្វើការងារហួសកម្លាំង និងការហូបចុកមិនគ្រប់គ្រាន់ក្នុងរបបខ្មែរក្រហម។ ការជួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតនៅចេតិយរំពុកនេះ គឺជាឱកាសល្អមួយសម្រាប់សិស្សដែលជាក្មេងជំនាន់ក្រោយអាចសួរនាំទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអំពីបទពិសោធន៍ និងបង្កើនការចង់ដឹងរឿងរ៉ាវកើតឡើងក្នុងមូលដ្ឋានក្នុងរបបខ្មែរក្រហម។

កិច្ចសន្ទនាអន្តរជំនាន់នៅចេតិយរំពុកសម្រាប់សហគមន៍នេះអស់រយៈពេលជិត២ម៉ោង។ សិស្សឈ្មោះ ឈីន គុងហេង ថ្នាក់ទី១១-អេ (A) ផ្នែកវិទ្យាសាស្ត្រពិត វិទ្យាល័យ ឈីន លាន ហាន់ជ័យ បង្ហាញពីចំណាប់អារម្មណ៍ថា «ខ្ញុំយល់ដឹងអំពីសារសំខាន់ការចងចាំអំពីជនរងគ្រោះដែលស្លាប់ក្នុងរបបខ្មែរក្រហម និងរឿងរ៉ាវជីវិតរបស់អ្នករស់រានមានជីវិតដូចជាលោកតា លោកយាយ និងអំប្រុស អំស្រីរបស់ខ្ញុំដែលបានឆ្លងកាត់របបនេះ។ នៅពេលដែលខ្ញុំវិលត្រឡប់ទៅផ្ទះវិញ ខ្ញុំនឹងសួរលោកតារបស់ខ្ញុំអំពីរឿងរ៉ាវដែលគាត់បានឆ្លងកាត់»។





# សិស្សានុសិស្សមកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍

## ក្រោមប្រធានបទ៖ តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?

ផេង ពង្សរ៉ាស៊ី







សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ក្រោមប្រធានបទ៖ តើខ្មែរក្រហមជានរណា? រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រសិនបើត្រឡប់ទៅមើលអតីតកាល កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាថ្ងៃដែល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ហើយប្រទេសចាប់ផ្តើមមានសង្គ្រាម។ ការធ្វើរដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ និងការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ ឲ្យប្រជាជនចូលព្រៃម៉ាគីប្រឆាំងនឹងរបប លន់ នល់ បានធ្វើឲ្យខ្មែរក្រហមក្តោបយកឱកាសឡើងកាន់អំណាចយ៉ាងឆាប់រហ័ស។ បើរាប់ពីឆ្នាំ១៩៧០ មកទល់នឹងបច្ចុប្បន្ននេះគឺមានរយៈពេល៥៣ឆ្នាំមកហើយ។

គ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យានៅវិទ្យាល័យ សុខ អាន ដូងខ្ពស់ បុរីជលសារ ឈ្មោះ ឌូ សុង បានប្រាប់ឲ្យដឹងថា មេរៀនប្រវត្តិសាស្ត្ររបបសាធារណរដ្ឋខ្មែរ ទើបត្រូវបានបញ្ចប់ការបង្រៀននៅពេលថ្មីៗនេះ ហើយគាត់កំពុងរៀបចំកិច្ចតែងការបង្រៀនសម្រាប់ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងខែបន្ទាប់

ទៀត។ សិស្សចំនួនបីនាក់គឺ ភោន ហ៊ុយ, សារី ស៊ីមា និង សារី យិស្មី បានប្រាប់ថា ខ្លួនបានដឹងថាមានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទម្លាក់ សម្តេចព្រះនរោត្តម សីហនុ ដោយសេនាប្រមុខ លន់ នល់ តាមរយៈគ្រូបង្រៀន។ សិស្សទាំង៣នាក់បានបង្ហាញពីការចង់ចេះចង់ដឹងបន្ថែមថា ខ្លួនចង់ដឹងព្រឹត្តិការណ៍ជាច្រើនទៀត នាំដល់ការកកើតរបបខ្មែរក្រហម។ លោកគ្រូ ឌូ សុង បាននិយាយទាំងទឹកមុខរីករាយដូច្នេះ «ខ្ញុំសប្បាយរីករាយ ដែលសិស្សរបស់ខ្ញុំមានឱកាសបានមកចូលរួមធ្វើទស្សនកិច្ចសិក្សា និងចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំក៏កំពុងតែត្រៀមមេរៀនសម្រាប់ការបង្រៀនមេរៀននេះនៅខែក្រោយដែរ។ សិស្សរបស់ខ្ញុំនៅមិនទាន់មានចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមទេ។ ខ្ញុំសង្ឃឹមថា វេទិកានេះនឹងជួយសិស្សរបស់ខ្ញុំឲ្យទទួលបានចំណេះដឹងច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេសពីលោកគ្រូផ្ទាល់»។

នៅវេលាម៉ោងប្រមាណជា ៨ព្រឹក ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលស្វាគមន៍សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ បូរីជលសារ ចំនួន២៤នាក់ ក្រោមការដឹកនាំពីគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាចំនួន២នាក់ ក្នុងដំណើរទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្តាហ៍។ សិស្សានុសិស្សបានចូលទស្សនាពិព័រណ៍រូបថតនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តតាកែវ អមជាមួយការពន្យល់បន្ថែមពីលោក ផេង ពង្សរ៉ាស៊ី គឺជានាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដែលជាគ្រូខទ្ទេស។

នៅវេលាម៉ោងប្រមាណជា៨ នឹង១៥នាទីព្រឹក សិស្សានុសិស្សបានចូលទៅបន្ទប់ថ្នាក់រៀនដើម្បីចូលរួមវេទិកាពិភាក្សាលើប្រធានបទ «តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?»។ ដំបូង សិស្សានុសិស្សត្រូវបានណែនាំឲ្យបំពេញតារាងស្ទាបស្ទង់មតិដើម្បីវាស់ស្ទង់ចំណេះដឹងមុនពេលចាប់ផ្តើមវេទិកា។ បន្ទាប់មកទៀត គ្រូខទ្ទេសចាប់ផ្តើមការពិភាក្សាពីប្រធានបទខាងលើ។ ដោយមូលហេតុប្រធានបទនេះ មានទម្រង់ជាសំណួរ



សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ទស្សនកិច្ចសិក្សាចេតិយរំឭកនៃការចងចាំ នៅភូមិទួលធាតុ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។
(ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ ទស្សនកិច្ចសិក្សាមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់ ស្ថិតនៅឃុំគុស ស្រុកត្រាំកក់ រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្រាប់ គ្រូខ្ទេសបានសួរសំណួរទាំងនេះទៅកាន់សិស្សតែម្តង ដើម្បីចង់ដឹងពីការឆ្លើយតបមកវិញចំពោះការយល់ដឹងលើប្រធានបទនេះ។ គ្រូខ្ទេសសួរសំណួរទី១៖ តើខ្មែរក្រហមជានរណា? ទៅកាន់អ្នកចូលរួម។ ពុំមានអ្នកចូលរួមណាម្នាក់ឆ្លើយសំណួរនេះបានទេ។ ប្រហែល៥នាទីក្រោយមក គ្រូខ្ទេសបន្តសំណួរទី ២ ៖ តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា? សំណួរនេះ ក៏គ្មានអ្នកឆ្លើយដែរ។

បន្ទាប់មក គ្រូខ្ទេសបានចាប់ផ្តើមពន្យល់ពីការបង្កើតចលនាខ្មែរឥស្សរៈនៅក្នុងទសវត្សរ៍ឆ្នាំ១៩៤០, ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរក្នុងឆ្នាំ១៩៥១, និងការផ្លាស់ប្តូរឈ្មោះបក្សជាបន្តបន្ទាប់ រហូតទាល់តែខ្មែរក្រហមអាចដណ្តើមកាន់កាប់ប្រទេសកម្ពុជាបាននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ក្នុងការពិភាក្សានេះ គ្រូខ្ទេសបានពន្យល់យ៉ាងក្បោះក្បាយពីការរីកចម្រើនរបស់ក្រុមបដិវត្តន៍ដែលរស់នៅក្នុងព្រៃ ដោយមូលហេតុពីរយ៉ាងគឺ ទី១) ដោយសារមានព្រឹត្តិការណ៍ទម្លាក់គ្រាប់បែក និង ទី២) ដោយសារការគោរពស្រឡាញ់របស់ប្រជាជនទៅលើសម្តេចព្រះ នរោត្តម សីហនុ។

នៅវេលាម៉ោងប្រមាណជា១១កន្លះព្រឹក វេទិកាថ្នាក់រៀនត្រូវបានបញ្ចប់ បន្ទាប់ពីគ្រូខ្ទេសធ្វើបទបង្ហាញបន្ថែមពីនិយមន័យនៃអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍រួច។ នៅចុងបញ្ចប់នៃកម្មវិធីវេទិកាសាធារណ គឺជាការវាស់ស្ទង់ចំណេះដឹងសិស្សក្រោយការទទួលបានចំណេះដឹងថ្មី និងការពិភាក្សាពីចម្ងល់ដែលមាន។ ក្រៅពីសំណួរទាក់ទងនឹងប្រធានបទ គ្រូខ្ទេស បានផ្តល់ឱកាសឲ្យមានការសួរសំណួរដែលទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហមទាំងមូលដែរ។ សិស្សានុសិស្សចំនួន៦នាក់បានសួរសំណួរទៅកាន់គ្រូខ្ទេស ដែលសំណួរទាំងនោះទាក់ទងនឹងការកើតមាននិងការបញ្ចប់សង្គ្រាមស៊ីវិល, មូលហេតុនៃការជ្រើសរើសយកសាឡុតស ធ្វើជាលេខាបក្សជំនួស, ការស្លាប់របស់ ប៉ុល ពត, សុន សេន និង វន វ៉េត, និងការបណ្តេញជនជាតិវៀតណាមចេញរបស់ខ្មែរក្រហម។

ក្នុងពេលជាមួយគ្នានេះដែរ យុវសិស្សបីនាក់បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនបន្ទាប់ពីបានចូលរួមនៅក្នុងវេទិកាពិភាក្សានេះថា ខ្លួនបានរៀនសូត្រច្រើនគួរសមទាក់ទងនឹងព្រឹត្តិការណ៍រដ្ឋប្រហារ ការកើតមានសង្គ្រាមស៊ីវិល ការទម្លាក់គ្រាប់បែក ការកើតមានរបបខ្មែរក្រហមដែលនាំឲ្យមានការបិទសិទ្ធិសេរីភាពប្រជាជន និងវិធីសាស្ត្រ



សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ ទស្សនកិច្ចសិក្សាមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់ ស្ថិតនៅឃុំគុស ស្រុកត្រាំកក់ រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទប់ស្កាត់អំពើប្រល័យពូជសាសន៍។ ខាងក្រោមនេះជាការលើកឡើងរបស់សិស្សទាំង៣នាក់៖

ភោន ហ៊ុយ ភេទប្រុស អាយុ១៧ឆ្នាំ៖ «ក្រោយពីបានចូលរៀននៅព្រឹកនេះ ខ្ញុំបានដឹងអំពីរបបខ្មែរក្រហម ដូចជា ការធ្វើទារុណកម្ម ការបំបិទសិទ្ធិមនុស្ស ការហូបអាហារមិនគ្រប់គ្រាន់ ការធ្វើការងារធ្ងន់ៗរបស់ប្រជាជន ជាពិសេសការធ្វើរដ្ឋប្រហារទម្លាក់ សម្តេច ព្រះនរោត្តម សីហនុ និង វិធីសាស្ត្រការពារអំពើប្រល័យពូជសាសន៍»។

សារី ស៊ីម៉ា ភេទស្រី អាយុ ១៩ឆ្នាំ៖ «បន្ទាប់ពីបានចូលរៀនក្នុងវេទិកាថ្នាក់រៀន ខ្ញុំបានដឹងថានៅក្នុងសម័យ លន់ នល់ មានការទម្លាក់គ្រាប់បែកប្រជាជនបានជម្លៀសខ្លួនពីជនបទទៅទីក្រុង និងមានសង្គ្រាមស៊ីវិល។ បន្ថែមជាងនេះទៀត ខ្ញុំមានការយល់ដឹងកាន់តែច្បាស់អំពីការធ្វើរដ្ឋប្រហារ សម្តេច ព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ និងមូលហេតុដែលធ្វើឲ្យខ្មែរក្រហមទទួលបានជ័យជម្នះយ៉ាងឆាប់រហ័សនៅ ឆ្នាំ១៩៧៥។ ចំណែកនៅក្នុងសម័យខ្មែរក្រហម ខ្ញុំបានដឹងពីការជម្លៀសរបស់ប្រជាជន ការធ្វើការហួសកម្លាំង និងការសម្លាប់យ៉ាងឃោរឃៅទៅលើអ្នកចេះដឹង និងប្រជាជនទូទៅ»។

សារី យិស្មី ភេទស្រី អាយុ១៨ឆ្នាំ៖ «ខ្ញុំបានដឹងអំពីគោលនយោបាយរបស់ខ្មែរក្រហម និងការកាន់អំណាចរបស់ខ្មែរក្រហម ជាពិសេស ធ្វើឲ្យខ្ញុំដឹងពីវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត»។

នៅរសៀលថ្ងៃ១៨ ខែមីនា ឆ្នាំ២០២៣ ដដែល សិស្សានុសិស្សទាំងអស់បានធ្វើដំណើរទៅកាន់ភូមិត្រពាំងស្វាយ ឃុំតាភេម ដើម្បីពិនិត្យមើលសំណង់ចេតិយ និងផ្ទាំងពាក្យស្លោកស្តីអំពីការចងចាំប្រវត្តិ-សាស្ត្រខ្មែរក្រហម។ អត្ថន័យរបស់ពាក្យស្លោកនេះបង្ហាញឲ្យឃើញពីគន្លឹះសំខាន់ៗមួយចំនួនក្នុងការរារាំងការកកើតអំពើប្រល័យពូជសាសន៍គឺ ការយល់យោគគ្នា អត់ឱនឲ្យគ្នា និងចេះអធ្យាស្រ័យគ្នា។ នៅទីតាំង មេភូមិត្រពាំងស្វាយឈ្មោះ សួស រ៉ា គឺជាអតីតកម្មាភិបាលខ្មែរក្រហម បានរៀបរាប់ពីប្រវត្តិរបស់គាត់ឆ្លងកាត់របបខ្មែរក្រហម និងបានអប់រំណែនាំសិស្សានុសិស្សឲ្យខិតខំរៀនសូត្រ និងការពារកុំឲ្យកើតមានរបបខ្មែរក្រហមម្តងទៀត។ លោកមេភូមិក៏បានពន្យល់ថា សំណង់ចេតិយដែលស្ថិតនៅជិតប្រមាណ១៥ម៉ែត្រ ពីផ្ទាំងពាក្យស្លោកនេះ គឺជាសមិទ្ធិផលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងឃុំតាភេម សម្រាប់ប្រើប្រាស់ជាទីតាំងរួមក្នុងការតម្កល់អដ្ឋិធាតុសាច់ញាតិបងប្អូនដែលបានស្លាប់កាលពីជំនាន់ខ្មែរក្រហម។

បន្ទាប់ពីបញ្ចប់ទស្សនកិច្ចសិក្សានៅភូមិត្រពាំងស្វាយ យុវជនទាំងអស់បានធ្វើដំណើរបន្តទៅកាន់ទីតាំងសម្លាប់ដ៏ធំមួយក្នុងស្រុកត្រាំកក់ កាលពីជំនាន់ខ្មែរក្រហមគឺទីតាំងសម្លាប់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលជាគោលដៅចុងក្រោយសម្រាប់ទស្សនកិច្ចសិក្សារបស់សិស្សវិទ្យាល័យ សុខ អាន ដូងខ្ពស់ បូរីជលសារ ក្នុងថ្ងៃនេះ។




សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ កំពុងអានពាក្យស្លោក ដែលនិយាយអំពីការអប់រំ និងការទប់ស្កាត់របបប្រល័យពូជសាសន៍ខ្មែរក្រហម រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ង៉ាន់ វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំសិក្ខាសាលា «ការអប់រំអំពីសុខភាព»

## ជាមួយនិស្សិតវិទ្យាសាស្ត្រសុខាភិបាល មកពីសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាល មូស្លីមកម្ពុជា

*សោម ប៊ុនថន*





ក្រុមនិស្សិតពេទ្យចូលរួមសិក្ខាសាលា «ការអប់រំអំពីសុខភាព» រៀបចំដោយគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា រយៈពេលមួយថ្ងៃ គឺនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារ កាំបូឌីយ៉ាណា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំសិក្ខាសាលា «ការអប់រំអំពីសុខភាព» រយៈពេលមួយថ្ងៃ គឺនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារ កាំបូឌីយ៉ាណា ជាមួយនិស្សិតវិទ្យាសាស្ត្រសុខាភិបាលមកពីសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាលមូស្លីមកម្ពុជា ចំនួន៥០នាក់ និងនិស្សិតអាហារូបករណ៍មុខវិជ្ជាសុខភាពសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន២នាក់។ សិក្ខាសាលានេះមានការចូលរួមពីវាគ្មិនឯកឧត្តម សាន់ សាប អ៊ី រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាល មូស្លីម កម្ពុជា, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, លោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាប្រធានគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម», លោក

គ្រីស្តូហ្វ័រ ឌៀរីង អ្នកវាយតម្លៃគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, បណ្ឌិត លីហ្សា ព្រោន សាស្ត្រាចារ្យនៅសាកលវិទ្យាល័យ ស្តែនហ្វត និង ប៉ាំ ឡូ អាតូ, វេជ្ជបណ្ឌិត ដេមី វ៉ែយ៍ ទីប្រឹក្សាគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» និងវេជ្ជបណ្ឌិត គួច ម៉េងលី ប្រធានមូលនិធិ ម៉េងលី ជេ. គួច។

ជាកិច្ចចាប់ផ្តើមនៅពេលព្រឹក លោកស្រី សូ ហ្វារីណា បានលើកឡើងអំពីគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» និងកិច្ចការរបស់មជ្ឈមណ្ឌលឯកសារថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ដោយធ្វើការផ្តោតលើការប្រមូល ការចងក្រងឯកសារ ការបោះពុម្ពសៀវភៅ និងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមដល់សិស្សានុសិស្ស ក្នុងគោលបំណងយុត្តិធម៌ និងការចងចាំ។ លោកស្រី សូ ហ្វារីណា បានបន្តថា ថ្មីៗនេះ មជ្ឈមណ្ឌលឯកសារបានធ្វើការងារទាក់ទងនឹងការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ គម្រោងនេះធ្វើយ៉ាងណាឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបាននូវសេវាសុខភាពកាន់តែប្រសើរឡើង និងចង់មានឲ្យមានការចូលរួមពីក្រុមនិស្សិតស្ម័គ្រចិត្តដែលត្រូវជាកូនចៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះ។ ក្រុមនិស្សិតស្ម័គ្រចិត្តអាចត្រឡប់ទៅធ្វើការងារនៅសហគមន៍របស់ខ្លួន។ អ្នកស្រី សូ ហ្វារីណា ក៏បានបង្ហាញអំពីដែនទីដែលក្រុមអ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន ១០៣០នាក់បានចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ៣២០០០ ដែលរស់នៅតាមតំបន់ជនបទដាច់ស្រយាលក្នុងប្រទេសកម្ពុជា និងគ្លីនិកឯកជនដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការជាមួយកន្លងមក។

បន្ទាប់មក លោក គ្រីស្តូហ្វ័រ ឌៀរីង អ្នកវាយតម្លៃគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងអំពីចំណុចសំខាន់ៗទាក់ទិនងបញ្ហាសុខភាព គឺការផ្លាស់ប្តូរឥរិយាបទ រួមមាន៖ ទម្លាប់នៃការរស់នៅ ទម្លាប់នៃការធ្វើការងារ និងទម្លាប់នៃការគិត។ ឧទាហរណ៍ទម្លាប់ដែលមិនល្អ ប៉ុន្តែបែរជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគិតថាល្អទៅ







ក្រុមនិស្សិតពេទ្យចូលរួមសិក្ខាសាលា «ការអប់រំអំពីសុខភាព» រៀបចំដោយគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា រយៈពេលមួយថ្ងៃ គឺនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារ កាំបូឌីយ៉ាណា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

វិញ ដូច្នេះ ប្រជាជនត្រូវតែផ្លាស់ប្តូរទម្លាប់មិនល្អបន្តិចម្តងៗ រហូតសុខភាពរបស់ពួកគាត់បានប្រសើរឡើង។ ទោះបីយ៉ាងណាការផ្លាស់ប្តូរទម្លាប់នេះ គឺមិនងាយស្រួលឡើយ ដោយសារប្រជាជនរស់នៅក្នុងស្ថានភាពផ្សេងៗគ្នា និងមានការយល់ឃើញខុសគ្នា។ យើងត្រូវប្រាប់ប្រជាជនពីចំណុចល្អដែលគាត់ត្រូវអនុវត្តក្នុងការថែទាំសុខភាព ត្រូវប្រាប់គាត់ជាប្រចាំ ត្រូវផ្តល់ព័ត៌មាននៃការពិនិត្យសុខភាពជូនពួកគាត់ ព្រមទាំងផ្តល់ប្រភពធនធានជូនគាត់ដូចជាមធ្យោបាយទៅពិនិត្យសុខភាពជាដើម។

តមក បណ្ឌិត លី ហ្សា ប្រោន សាស្ត្រាចារ្យនៅសាកលវិទ្យាល័យ ស្តេនហ្វត និង ប៉ា ឡូ អាតូ បានលើកឡើងអំពីសារសំខាន់នៃការព្យាបាលជំងឺផ្លូវ





ក្រុមនិស្សិតពេទ្យចូលរួមសិក្ខាសាលា «ការអប់រំអំពីសុខភាព» រៀបចំដោយគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា រយៈពេលមួយថ្ងៃ គឺនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារ កាំបូឌីយ៉ាណា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចិត្តជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថា ជំងឺទាំងនេះបានកើតចេញពីហេតុការណ៍ដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានជួបប្រទះកន្លងមក។ ជំងឺផ្លូវចិត្តនេះបានកើតឡើងភ្លាមៗបន្ទាប់ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានជួបហេតុការណ៍ភ្លាមៗ និងជំងឺផ្លូវចិត្តមួយចំនួនទៀតបានអូសបន្លាយរយៈពេលយូរៗ អ្នករស់រានមានជីវិតមួយចំនួនបានព្យាយាមលាក់បាំង និងគេចចេញពីជំងឺផ្លូវចិត្តដោយមិនមានការព្យាបាល ប៉ុន្តែជំងឺនេះនឹងត្រឡប់មកវិញនៅពេលអ្នកទាំងនោះមានវ័យកាន់តែចាស់ និងរស់នៅឯកោ។ ម្យ៉ាងទៀតអ្នកជំងឺត្រូវទទួលស្គាល់ថាគាត់មានបញ្ហាផ្លូវចិត្តដើម្បីឲ្យគាត់ត្រៀមខ្លួនដើម្បីប្រឹក្សាជាមួយក្រុមគ្រូពេទ្យជំនាញ។

ដោយឡែក វេជ្ជបណ្ឌិត គួច ម៉េងលី ប្រធានមូលនិធិ ម៉េងលី ជេ. គួច បានលើកឡើងថា សុខភាព និងការថែទាំសុខភាពគឺសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនកម្ពុជា។ ទោះបីយ៉ាងណា គាត់បានឲ្យដឹងថា បញ្ហាទាំងនេះក៏ជាប់ទាក់ទងនឹងការយល់ដឹងរបស់ក្រុមគ្រូពេទ្យដែលផ្តល់សេវាសុខភាពដែរ។ ជាក់ស្តែងគ្រូពេទ្យត្រូវមានពេលវេលាគ្រប់គ្រាន់ដើម្បីប្រឹក្សាដល់អ្នកជំងឺ ដើម្បីដឹងពីដើមហេតុដំបូងនៃជំងឺ ហើយត្រូវប្រើវិធីសាស្ត្រផ្សេងៗដើម្បីព្យាបាល។

ឯកឧត្តម សាន់ សាប់អី រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាលមូស្លីមកម្ពុជា បានគូសបញ្ជាក់ថា ការរៀនសូត្រមុខវិជ្ជាវិទ្យាសាស្ត្រសុខាភិបាលគឺមិនមែនងាយស្រួលឡើយ។ នៅពេលយើងចាប់យកមុខវិជ្ជានេះ គឺយើងត្រូវសួរខ្លួនឯងថា យើងរៀនដើម្បីអ្វី? ប្រសិនបើយើងរៀនដើម្បីជួយសង្គ្រោះដល់មនុស្ស នោះយើងនឹងពង្រឹងសមត្ថភាព និងមានក្រមសីលធម៌ល្អចំពោះអ្នកជំងឺ។ យើងនឹងឃើញពីតម្លៃការងារ និងមានមោទនភាពចំពោះខ្លួនឯង។ ឯកឧត្តមបានផ្តាំផ្ញើដល់និស្សិតទាំងអស់ឲ្យយកចិត្តទុកដាក់ត្រង់ត្រាប់ស្តាប់សិក្ខាសាលា និងចូលរួមឲ្យបានសកម្ម ហើយយកចំណេះដឹងដែលទទួលបានទៅអនុវត្តនៅក្នុងកិច្ចការរបស់ខ្លួន។



ក្រុមនិស្សិតពេទ្យដែលចូលរួមសិក្ខាសាលា «ការអប់រំអំពីសុខភាព» រៀបចំដោយគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» មកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកឧត្តម សាន់ សាប់អី បានគូសបញ្ជាក់ នៅក្នុងសាសនាអ៊ីស្លាមអ្វីដែលយើងអាចយកទៅតាមខ្លួនបានគឺមានតែបីចំណុចប៉ុណ្ណោះ គឺ៖

១) ការគោរពប្រណិប័តន៍សាសនាអ៊ីស្លាម
២) ការបរិច្ចាគទាន
៣) ការចែករំលែកចំណេះដឹងដល់សាសនិកអ៊ីស្លាមនិងមនុស្សទូទៅ

ជាចុងក្រោយ ឯកឧត្តមបានផ្តាំផ្ញើដល់និស្សិតទាំងអស់ឲ្យបេះបណ្តុះគំនិតទាំងអស់តាំងពីនៅរៀនហើយត្រៀមខ្លួនឲ្យបានរួចរាល់នៅពេលបញ្ចប់ការសិក្សានិងចេញទៅធ្វើការតាមមន្ទីរពេទ្យ។

ចំណែក វេជ្ជបណ្ឌិត ដេមី រៃយ៍ ទីប្រឹក្សាគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» បានលើកឡើងថា តាមបទពិសោធន៍របស់គាត់ដែលជាវេជ្ជបណ្ឌិតជនជាតិហ្វីលីពីន កាន់សាសនាគ្រិស្ត មុនពេលចេញប្រកបការងារពេទ្យរដ្ឋ ត្រូវឲ្យគាត់ស្បថ និងប្រកាន់ខ្ជាប់នូវចំណុចសំខាន់៤យ៉ាងគឺ៖ ទី១) បេះអាណិតអាសូរអ្នកដទៃដែលជួបការលំបាក ទី២) ត្រូវតាំងចិត្តថាជួយអ្នកដែលជួបការលំបាកនោះឲ្យបាន ទី៣) ត្រូវមានសមត្ថភាព និងវិធីសាស្ត្រដើម្បីជួយអ្នកជួបការលំបាក និងទី៤) ត្រូវមានសេចក្តីក្លាហាន និងដឹងការប្រព្រឹត្តខុសឬ

ត្រូវរបស់ខ្លួន។ ក្នុងន័យនេះគឺសំដៅលើភាពក្លាហានក្នុងការជួយអ្នកជំងឺដោយមិនរួញរា។

វេជ្ជបណ្ឌិត ដេមី រៃយ៍ ក៏បាននិយាយអំពីបទពិសោធន៍ដែលគាត់ធ្វើការងារជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាចាប់តាំងពីឆ្នាំ២០១៦មក។ ដំបូងគាត់បានធ្វើដំណើរទៅតំបន់ជនបទដាច់ស្រយាលនៅក្នុងប្រទេសកម្ពុជាជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីសាកសួរអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានដាក់ពាក្យបណ្តឹងទៅកាន់សាលាក្តីខ្មែរក្រហមអំពីបញ្ហាសុខភាព បន្ទាប់មកទើបគាត់ធ្វើការងារលើគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដើម្បីជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំឡើងទៅ។ តាមរយៈគម្រោងសុខភាពនេះបានរកឃើញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនកំពុងប្រឈមនឹងជំងឺ១០មុខគឺ១) ជំងឺលើសឈាម ២) ជំងឺក្រពះពោះវៀន ៣) ជំងឺគ្រុនចាញ់ ៤) ជំងឺផ្លូវចិត្តៈ ៥) ជំងឺបេះដូង ៦) ជំងឺឈឺសន្លាក់ ៧) ជំងឺហឺតរ៉ាំរ៉ៃ ៨) ជំងឺទឹកនោមផ្អែម ៩) ជំងឺរបេង និង១០) ជំងឺភ្នែកដូចជា ភ្នែកឡើងបាយ។ ក្នុងឱកាសនេះដែរ វេជ្ជបណ្ឌិត ដេមី រៃយ៍ ក៏ជំរុញឲ្យនិស្សិតដែលចូលរួមទាំងអស់ខិតខំប្រឹងរៀនរៀនសូត្រ និងធ្វើការ ហើយត្រូវគោរពតាមក្រមសីលធម៌ចំពោះអ្នកជំងឺ។

ទោះបីយ៉ាងណា ភាពភ័យខ្លាចដែលបន្សល់ទុកដោយរបបខ្មែរក្រហមបានកើតឡើងអស់ជាច្រើនឆ្នាំ ដូច្នេះរឿងរ៉ាវទាំងនេះ មិនគួរត្រូវបានបំភ្លេចចោលឡើយ ខណៈអ្នករស់រានមានជីវិតពីអំពើឃោរឃៅនេះកាន់តែមានវ័យចំណាស់ ពិសេសចាស់ៗនៅតាមទីជនបទដាច់ស្រយាលនៅក្នុងប្រទេសកម្ពុជា។ ជាង ៤០ឆ្នាំ បានកន្លងផុតទៅហើយ ហើយឥឡូវនេះ សំឡេងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតែត្រូវបានគេឮ ស្នាមរបួស និងការចងចាំមិនល្អរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានអូសបន្លាយពេលជាច្រើនឆ្នាំកន្លងមក និងមិនបានចាកចេញឆ្ងាយពីពួកគេឡើយ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមស្ទើរតែទាំងអស់សុទ្ធតែមានជីវភាពក្រីក្រ និងទទួលរងជំងឺដែលទាក់ទងនឹងវ័យចំណាស់ គួបផ្សំជាមួយការខ្វះខាតការយល់ដឹងអំពីការថែទាំសុខភាព និងកង្វះលទ្ធភាពទទួលបានការព្យាបាលនៅតាមគ្លីនិក និងមន្ទីរពេទ្យ។

គោលដៅសំខាន់មួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺការរក្សាការចងចាំពីសោកនាដកម្មពីអតីតកាល ដើម្បីឲ្យមនុស្សជំនាន់ក្រោយយល់ដឹងអំពីការពិតដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងកុំឲ្យប្រវត្តិសាស្ត្រនេះកើតឡើងម្តងទៀត ព្រមទាំងជួយថែរក្សាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យមានសុខភាពល្អ និងមានអាយុវែងដែលអាចប្រាប់រឿងរ៉ាវរបស់ខ្លួនដល់មនុស្សជំនាន់ក្រោយ។ ក្នុងន័យនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាដើរតួនាទីចម្បងក្នុងផ្តល់សេវាថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើកិច្ចការនេះតាំងពីដើមឆ្នាំ២០១៦មកម្ល៉េះ ហើយកម្រងសំណួរត្រូវបានបង្កើតឡើងសម្រាប់ប្រមូលទិន្នន័យផ្ទាល់ខ្លួន និងបញ្ហាសុខភាពដោយផ្អែកលើរោគសញ្ញានៃជំងឺទូទៅ និងផលប៉ះពាល់ផ្លូវចិត្តលើសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ បន្ទាប់ពីរយៈពេលជាង ១ឆ្នាំ ដែលស្ទើរតែ៩៥ភាគរយ នៃអ្នករស់រានមានជីវិតពីខ្មែរក្រហមចំនួន១៧៥០រស់នៅក្នុងខេត្តចំនួន ៧ ត្រូវបានសម្ភាសន៍ពិនិត្យសុខភាពនិងព្យាបាលតាមការណែនាំពីវេជ្ជបណ្ឌិត។ ចម្លើយរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមត្រូវបានប្រមូល វាយតម្លៃ និងវិភាគ ហើយលទ្ធផលបានបង្ហាញដូចខាងក្រោម៖

- ៧៥ ភាគរយ គឺមានអាយុ៦០ ឆ្នាំ ដែលមានវ័យចាស់ និងចាស់ជរា
- ៩៥ ភាគរយ រស់នៅក្នុងស្ថានភាពក្រីក្រ រស់នៅជាមួយសាច់ញាតិ
- ៧០ ភាគរយ មិនមានសុខភាពល្អ
- ១០ ភាគរយ នៅតែទទួលរងពីសុបិនអាក្រក់ និងការធ្លាក់ទឹកចិត្តដែលទាក់ទងនឹងបទពិសោធន៍នៃអំពើឃោរឃៅពីខ្មែរក្រហម



ក្រុមនិស្សិតពេទ្យដែលចូលរួមសិក្ខាសាលា «ការអប់រំអំពីសុខភាព» រៀបចំដោយគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» មកទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ែ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

- ជំងឺទូទៅគឺជំងឺទឹកនោមផ្អែមប្រភេទទី២ លើសឈាម ជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺបេះដូង ជំងឺរបេង ជំងឺ COPD ជំងឺមហារីក និងជំងឺគ្រុនចាញ់។

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា និស្សិតនឹងចូលរួមជាមួយយើងក្នុងនាមជាអ្នកស្ម័គ្រចិត្តផ្នែកវេជ្ជសាស្ត្រ ដើម្បីជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជិត៥លាននាក់។ ទាំងនេះ ក៏ជាឱកាសដែលអ្នកស្ម័គ្រចិត្តបង្ហាញពីការយកចិត្តទុកដាក់ ការប្ដេជ្ញាចិត្ត និងសមត្ថភាពនៃការធ្វើជាវេជ្ជបណ្ឌិតដ៏ល្អ។ បន្ទាប់ពីការធ្វើបទបង្ហាញរបស់វាគ្មិន និស្សិតដែលចូលរួមបានលើកជាសំណួរទៅកាន់បណ្ឌិត លីហ្សា ហ្រ្វាន ថា «តើត្រូវធ្វើដូចម្ដេចដើម្បីយកចិត្តទុកដាក់ថែទាំសុខភាពផ្លូវចិត្តប្រជាជនឲ្យបានល្អ ស្របពេលដែលយើងខ្វះធនធាន?»។ ជាការឆ្លើយតប បណ្ឌិត លីហ្សា ហ្រ្វាន លើកឡើងថា កង្វះធនធានអ្នកមានចំណេះដឹងអំពីសុខភាពផ្លូវចិត្ត កង្វះសម្ភារ និងព័ត៌មានសម្រាប់ផ្ដល់ឲ្យប្រជាជនពិតជាចាំបាច់ និងជាបញ្ហាប្រឈម ប៉ុន្តែយើងអាចនឹងមានការបណ្ដុះបណ្ដាលច្បាស់លាស់ ឈ្វេងយល់បន្ថែមពីអ្នកមានបញ្ហាផ្លូវចិត្ត និងពន្យល់គាត់ទាក់ទងសុខភាពផ្លូវចិត្ត។

ចំណែកនិស្សិតមួយចំនួនមានមតិយោបល់ទាក់ទងនឹងបទបង្ហាញរបស់លោក គ្រីស្តូហ្វ័រ ឌៀរីង អំពី «ការផ្លាស់ប្ដូរឥរិយាបថ» ថា វាពិតជាសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនកម្ពុជា ប៉ុន្តែវាពិបាកក្នុងការអនុវត្តព្រោះត្រូវចំណាយពេលវេលាយូរទៅមុខទៀត។

នៅពេលរសៀលថ្ងៃដដែល និស្សិតវិទ្យាសាស្ត្រសុខាភិបាល មកពីសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាល មូស្លីមកម្ពុជា ដឹកនាំដោយ ឯកឧត្ដម សាន់ សាប់អ៊ី រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានសមាគមនិសិ្សតវិទ្យាសាស្ត្រសុខាភិបាលមូស្លីមកម្ពុជា រួមទាំងសិក្ខាកាម មកទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅក្នុងឱកាសនោះលោក ឆាំង យុ នាយក

មជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រសាសន៍ថា «មានប្រជាជនចំនួន៥លាននាក់ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលស្មើនឹង ៣៣% នៃប្រជាជនទូទាំងប្រទេសកម្ពុជា ដែលហាក់មិនសូវទទួលបានការយកចិត្តទុកដាក់។ អ្នករស់រានមានជីវិតទាំងនេះបានកសាងប្រទេសឡើងវិញពីបាតដៃទទេ ដែលត្រូវជាមា មីង អ៊ំ យាយ និងតារបស់យើង។ បច្ចុប្បន្នអ្នកទាំងនេះមានវ័យកាន់តែចាស់ៗអស់ហើយ និងចាប់ផ្ដើមមានជំងឺ។ នៅក្នុងចំណោម៣៣% នៃអ្នករស់រានជីវិតពីរបបខ្មែរក្រហមទាំងនេះកំពុងប្រឈមនឹងជំងឺ១០យ៉ាងដូចគ្នារួមមាន១) ជំងឺលើសឈាម ២) ជំងឺក្រពះពោះវៀន ៣) ជំងឺគ្រុនចាញ់ ៤) ជំងឺផ្លូវចិត្ត ៥) ជំងឺបេះដូង ៦) ជំងឺឈឺសន្លាក់ ៧) ជំងឺហឺតរ៉ាំរ៉ៃ ៨) ជំងឺទឹកនោមផ្អែម ៩) ជំងឺរបេង និង១០) ជំងឺឆ្កួតជ្រូក។ នៅពេលមានតុលាការកាត់ទោស អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនេះមិនបានទទួលសំណងឡើយ ដោយសារឧក្រិដ្ឋកម្ម និងអំពើប្រល័យពូជសាសន៍មានទំហំធំធេង។ អ្នករស់រានមានជីវិតទាំងនេះខិតខំតស៊ូរកយុត្តិធម៌ហើយក្រោយមកគាត់ធ្លាក់ខ្លួនឈឺ។

លោក ឆាំង យុ បានបន្តថា ខ្ញុំគិតថាយើងគួរតែធ្វើអ្វីបន្តិចជាទឹកចិត្ត ភាពស្មោះត្រង់ ការបរិច្ចាគ (ក្នុងសាសនាអ៊ីស្លាម) ជូនដល់គាត់បន្តិចបន្តួច។ យើងចង់ឲ្យគាត់បានពិនិត្យសុខភាព ហើយយើងត្រូវចុះទៅជួបគាត់នៅភូមិ ទោះមិនអាចបានជួបទាំងអស់ គឺបានត្រឹម ១សែនឬ២សែននាក់ក៏ យើងធ្វើដែរ។ សព្វថ្ងៃប្រជាជនខ្លះ ដែលរួចរស់ពីសម័យខ្មែរក្រហមក៏មានជីវភាពធូរធារ ប៉ុន្តែអ្នកខ្លះក្រ និងអ្នកខ្លះទៀតពិការ ដូច្នេះយើងមើលថាអ្នកណាដែលពិបាកជាងគេ។ យើងធ្វើតាមលទ្ធភាពយើងអាចធ្វើបាន សំខាន់ចេញពីទឹកចិត្តស្មោះត្រង់។ ខ្ញុំចង់ឲ្យប្អូនៗរួមចំណែកជាមួយយើង គឺប្អូនអាចចុះទៅតាមសហគមន៍ជួបពួកគាត់។ ប្រសិនជាប្អូនឃើញថាគាត់លើសឈាម និងមានជំងឺរបេង តើប្អូនៗត្រូវធ្វើអ្វី? នេះជាកិច្ចការយើង។

ជាទូទៅយើងផ្ដល់អាហារ និងមធ្យោបាយធ្វើដំណើរជូនគាត់ដើម្បីទៅពិនិត្យសុខភាព និងពិនិត្យមើលឈាម។ កិច្ចការនេះតូច និងជាកិច្ចការដែលចាប់ផ្ដើមដំបូង ដែលយើងបានគិតគូរពីសុខភាពរបស់អ្នកដែលបានកសាងប្រទេសឡើងវិញ ដែលអ្នកទាំងនេះមិនត្រូវបានគេអើពើ។ ដូច្នេះបានជាយើងឲ្យសិស្ស និងនិស្សិតស្ម័គ្រចិត្តរាប់ពាន់នាក់ទៅជួបសួរសុខទុក្ខគាត់ និងយករបស់បន្តិចបន្តួចដែលគាត់នៅតែគិតថាមានតម្លៃជូនគាត់ ហើយឲ្យគាត់ប្រាប់រឿងរ៉ាវដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមប្រាប់មកយើងវិញ»។

បន្ទាប់ពីទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ែ ក្រុមនិស្សិតពេទ្យមូស្លីម បានត្រឡប់មកទីកន្លែងប្រជុំដើម្បីពិភាក្សាពីពេលវេលាដែលខ្លួនអាចធ្វើការងារជាមួយក្រុមការងារ គម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីជួយជនរងគ្រោះពីរបបខ្មែរក្រហមនៅតាមតំបន់ជនបទដាច់ស្រយាល និងថតរូបជុំគ្នាមុននឹងបញ្ចប់កម្មវិធីនៅថ្ងៃនេះ។



ក្រុមនិស្សិតពេទ្យចូលរួមសិក្ខាសាលា «ការអប់រំអំពីសុខភាព» រៀបចំដោយគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា រយៈពេលមួយថ្ងៃ គឺនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារ កាំបូឌីយ៉ាណា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម

វី ស៊ីថា





ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការតាំងពិព័រណ៍រូបថត ព្រះបរមរតនកោដ្ឋ ព្រះបាទ នរោត្តម សីហនុ នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣ ខ្ញុំឈ្មោះ វី ស៊ីថា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើដំណើរតាមរថយន្តក្រុងពីកោះថ្មទៅមជ្ឈមណ្ឌលឯកសារកំពង់ចាម។ ពេលមកដល់ក្រុងកំពង់ចាម ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានមកទទួលខ្ញុំនៅចំណតរថយន្ត បន្ទាប់មកបានដឹកខ្ញុំមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ វណ្ណេត បានសំដែងនូវការរាក់ទាក់មកកាន់ខ្ញុំ និងបាននិយាយរៀបរាប់ពីការរៀបចំការិយាល័យ ក្នុងនេះមានទូឯកសារចំនួន ២២ទូរ (ក្នុងនោះ ទូរ ៣ថត មានចំនួន ១៧ ទូរ និង ទូរ ៤ថតមានចំនួន៧) ដែលឯកសារភាគច្រើនគឺចម្លើយសារភាព ឬឯកសារតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម រួមទាំងប្រវត្តិរូបរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ក្នុងចំណោមឯកសារទាំងនេះ ក៏មានផ្ទាំងគំនូរ និងផ្ទាំងរូបភាពជាច្រើនទៀត។ ចំពោះផ្ទាំងរូបភាពខាងក្រៅ គឺនិយាយរៀបរាប់អំពីប្រវត្តិរូបរបស់មេដឹកនាំជាន់ខ្ពស់នៅក្នុងសម័យខ្មែរក្រហម ដូចជា នួនជា កើតនៅក្នុងឆ្នាំ១៩៦២ នៅខេត្តបាត់ដំបង។ ខៀវ សំផន កើតនៅខេត្តកំពង់ចាម នៅក្នុងឆ្នាំ១៩៣១។ អៀង សារី កើតនៅក្នុងឆ្នាំ១៩៣០ នៅខេត្តត្រាវិញ ប្រទេសវៀតណាមខាងត្បូង។ កាំង ហ្គេកអ៊ាវ ហៅ ឌុច កើតក្នុងឆ្នាំ១៩៤៥ នៅក្នុងខេត្តកំពង់ធំ ។ អៀង ធីរិទ្ធ ហៅ ភា កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅ

សង្កាត់លេខ៥ ក្នុងទីក្រុងភ្នំពេញ ព្រមទាំងផ្ទាំងរូបថត អំពីការធ្វើការរបស់ប្រជាជននៅទំនប់ «១ មករា» នៅស្ទឹងជីនិត ខេត្តកំពង់ធំ។

វណ្ណេត បានរៀបរាប់បន្តថា ចំពោះការរៀបចំវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមជារៀងរាល់ខែ គឺធ្វើនៅក្នុងការិយាល័យរបស់មជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម ផ្ទាល់តែម្តង។ ចំពោះការតុបតែងខាងក្នុងការិយាល័យ គឺមានការផ្លាស់ប្តូរជារៀងរាល់ខែដើម្បីឲ្យមើលទៅស្អាតប្លែក និងទាក់ទាញចំណាប់អារម្មណ៍អ្នកចូលមកសិក្សាស្រាវជ្រាវ។ ម្យ៉ាងទៀតការរៀបចំធ្វើរដាក់សៀវភៅក៏ត្រូវកែច្នៃ និងតុបតែងរចនាដើម្បីដាក់សៀវភៅឲ្យមានសណ្តាប់ធ្នាប់ដែរ។

នៅខាងក្រៅការិយាល័យមានទីធ្លាទូធំទូលាយ និងមានដើមឈើផ្តល់នូវម្លប់ត្រជាក់ ព្រមទាំងមានកន្លែងអង្គុយអានសៀវភៅទៀតផង។ លើសពីនេះ ក៏មានការដាំពោត ចេក ល្ហុង ស្វាយ ដែលសុទ្ធតែជាដំណាំធម្មជាតិ និងមើលទៅមានពណ៌បៃតងស្រស់។



ការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




ការតាំងពិព័រណ៍រូបថត ទាក់ទងនឹងរបបខ្មែរក្រហម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ វណ្ណេត បាននាំខ្ញុំទៅមើលចេតិយដែលបានកសាងឡើងនៅឆ្នាំ២០២១ ហើយបានសម្ពោធដាក់ឲ្យប្រើប្រាស់នៅឆ្នាំ២០២២ ។ ចេតិយនេះស្ថិតនៅក្នុងភូមិចំការ ៣០ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម និងមានចម្ងាយប្រមាណ ១២គីឡូម៉ែត្រ ពីមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ វណ្ណេត បាននិយាយរៀបរាប់ប្រាប់ខ្ញុំថា មូលហេតុដែលសាងសង់ចេតិយនេះឡើង ដោយសារទីតាំងនេះ គឺជាទីកន្លែងដែលធ្លាប់មានការសម្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហម គឺ ទី១) នៅ ឡផ្ទាំដក់ ទី២) នៅវត្តគគរ ទី៣) ទំនប់គគរ ឬទំនប់ធំ និងទី៤) ទីតាំងសម្លាប់រង្គាលទៅលើជនជាតិចាម។ វណ្ណេត បានបន្តថា មានពូម្នាក់ដែលមានឪពុករស់នៅក្នុងភូមិចំការ ៣០នេះ ក៏ត្រូវបានកម្មាភិ-បាលខ្មែរក្រហមចាប់ឪពុករបស់គាត់យកទៅសម្លាប់ចោលដែរ នៅអំឡុងពេលពូនោះកំពុងតែដេកគងលើដៃឪពុករបស់គាត់។ កម្មាភិបាលខ្មែរក្រហមបានហៅឪពុករបស់គាត់ទៅវាយចោល ដោយសារតែឪពុករបស់គាត់រើសពោតនៅដែលសេសសល់ពីចម្ការយកមកហូប។

បន្ទាប់មកខ្ញុំបានទៅទស្សនាវត្តរកាគយ ដែលជាបន្ទាយទាហានរបស់ លន់ នល់ ចន្លោះពីឆ្នាំ១៩៧០-១៩៧៥។



ព្រះវិហារវត្តរកាគយ នៅក្នុងខេត្តកំពង់ចាម ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុវជនមកពីឃុំដាំ និងឃុំចាន់មូល ស្រុកមេមត់

## រៀនសូត្រ អំពីប្រព័ន្ធសន្តិសុខ ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)

**ឡុង ដានី និង ទី ស៊ីថា**





ព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ យុវជនចំនួន៤៨នាក់ ក្នុងនោះមានស្រី៣៥នាក់ និងប្រុស១៣នាក់ មកពីឃុំដាំ និងឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រព័ន្ធសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៧:៣០នាទីព្រឹកថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២៣ យុវជនចំនួន៤៨នាក់ ក្នុងនោះមានស្រី ៣៥នាក់ និងប្រុស១៣នាក់ មកពីឃុំដាំ និងឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រព័ន្ធសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។

ជាកិច្ចចាប់ផ្តើម លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានដឹកនាំយុវជនដើរទស្សនាពិព័រណ៍នៃបណ្តុំរូបថតរូបគំនូរ និងផែនទីទាំង ១៣៣ នៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារកោះថ្មដោយចាប់ផ្តើមពីបណ្តុំរូបថតនៃសង្គ្រាមនៅក្នុងប្រទេសកម្ពុជានៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ចេញពីតំបន់កោះថ្ម, បណ្តុំរូបថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), បណ្តុំរូបថតនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩, បណ្តុំរូបថតភ័ស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) បណ្តុំរូបគំនូដែលសមមិត្ត ហ៊ុនសែន (សម្តេចតេជោ ហ៊ុនសែន) និងយុទ្ធមិត្ត ៨រូប ចាកចេញទៅប្រទេសវៀតណាមដើម្បីរៀបចំកម្លាំងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍

ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងដែនទីបង្ហាញផ្លូវដែលសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៤រូប បានចាកចេញពីបន្ទាយយោធានៅភូមិកោះថ្ម ទៅតំបន់ព្រៃដែនអាង ដាច់ដើមត្រយឹង (X-16) និងទីតាំងមួយចំនួននៅក្នុងស្រុកឡុកនិញ ខេត្តសុងប៊ែរ ប្រទេសវៀតណាម និងការបង្កើតអង្គភាព ១២៥ ដែលជាកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាដំបូងបង្អស់ ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨។

តមកលោក ឡុង ដានី បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ស្តីអំពី ប្រព័ន្ធសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

លោក ឡុង ដានី មានប្រសាសន៍ថា បើយោងតាមការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានប្រជាជនរាប់សែននាក់ត្រូវបានចាប់ខ្លួនយកទៅឃុំឃាំង ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់យ៉ាងព្រៃផ្សៃនៅតាមមន្ទីរសន្តិសុខនានានៅទូទាំងប្រទេសកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្មែរក្រហម បានបង្កើតមន្ទីរសន្តិសុខប្រមាណជិត២០០កន្លែងស្ទើរគ្រប់ទីកន្លែងនៅទូទាំងប្រទេស។ មន្ទីរសន្តិសុខ គឺជាពាក្យដែលខ្មែរក្រហមប្រើជំនួសពាក្យ គុក។

មន្ទីរសន្តិសុខឬគុកត្រូវបានខ្មែរក្រហមប្រើប្រាស់ជាកន្លែងឃុំឃាំង កន្លែងសួរចម្លើយ និងកន្លែងសម្លាប់អ្នកទោស។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមបានរៀបចំមន្ទីរសន្តិសុខតាមកម្រិតដូចខាងក្រោម៖

១) មន្ទីរសន្តិសុខពាកកម្រិតដំបូងគឺ (កម្រិតឃុំ កម្រិតស្រុក និងកម្រិតតំបន់) គឺភាគច្រើនជាកន្លែងឃុំឃាំងអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ និងអ្នកទោសផ្សេងទៀតដែលជាប្រជាជនសាមញ្ញជាប់ចោទពីបទលួចរបស់របរឬចំណីអាហារ ឬរត់ចោលកន្លែងធ្វើការងារ ឬនិយាយអាក្រក់ពីអង្គការ។

២) មន្ទីរសន្តិសុខកម្រិតភូមិភាគ គឺជាកន្លែងឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់យុទ្ធជនខ្មែរក្រហម និងក្រុមគ្រួសារ និងអ្នកទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសផ្សេងៗនៅក្នុងភូមិភាគនោះ។

៣) មន្ទីរសន្តិសុខកម្រិតខ្ពស់បំផុត គឺជាមន្ទីរសន្តិសុខមជ្ឈិម ដែលមានឈ្មោះសម្ងាត់ហៅថា មន្ទីរ ស-២១ ដែលទីតាំងនៅទីក្រុងភ្នំពេញ។ អ្នកទោសនៅមន្ទីរ ស-២១ ស្ទើរតែទាំងអស់ជាអតីតកម្មាភិបាលកងទ័ពខ្មែរក្រហម និងក្រុមគ្រួសារដែលជាប់ចោទពីបទក្បត់ខ្មែរក្រហម (បក្សកុម្មុយនីស្តកម្ពុជា)។ មានអ្នកទោសតិចតួចណាស់ដែលបានរួចជីវិតពីមន្ទីរ ស-២១។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានបែងចែកខ្មាំងជាពីប្រភេទគឺ សត្រូវខាងក្នុង និងសត្រូវខាងក្រៅ។

សត្រូវខាងក្នុង គឺជាប្រជាជនថ្មី មន្ត្រីរដ្ឋការពីរបបមុន ជនជាតិដើមភាគតិចតំបន់ភ្នំ ជនជាតិភាគតិចចាម ជនជាតិភាគតិចវៀតណាម ជនជាតិភាគតិចចិន បញ្ញវន្ត ជាដើម។

សត្រូវខាងក្រៅ គឺសំដៅទៅសហរដ្ឋអាមេរិក អតីតសហភាពសូវៀត ប្រទេសថៃ ប្រទេសវៀតណាម បណ្តាប្រទេសសង្គមនិយមមួយចំនួនទៀត។ ជនបរទេស ប្រជាជនខ្មែរ និងកម្មាភិបាល កងទ័ពខ្មែរក្រហមដែលបានជាប់ចោទថាបានបម្រើការងារជាភ្នាក់ងារឲ្យប្រទេសដូចបានរៀបរាប់ខាងលើស្ទើរតែទាំងអស់ត្រូវបានចាប់ខ្លួនបញ្ជូនទៅឃុំឃាំង ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់នៅមន្ទីរ ស-២១។

បន្ទាប់ពីបញ្ចប់ការធ្វើបទបង្ហាញអំពីប្រព័ន្ធសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) លោក ឡុង ដានី បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារស្តីអំពីគុកទួលស្លែង (ស-២១) ឲ្យយុវជនដែលចូលរួមវេទិកាបានទស្សនា។ ជាកិច្ចបន្ត លោក ឡុង ដានី ក៏បានធ្វើបទបង្ហាញបន្ថែមលើប្រធានបទស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ការប្រើប្រាស់អំពើហិង្សា ការរើសអើង និងផលវិបាករបស់វា។






*ព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ យុវជនចំនួន៤៨នាក់ ក្នុងនោះមានស្រី៣៥នាក់ និងប្រុស១៣នាក់ មកពីឃុំជាំ និងឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រព័ន្ធសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

មុនពេលបញ្ចប់វេទិកាថ្នាក់រៀននេះ យុវជនបានមានចំណាប់អារម្មណ៍ដូចខាងក្រោម៖

នាងខ្ញុំឈ្មោះស៊ិន សុម៉ាលីស ភេទស្រី មានអាយុ១៦ឆ្នាំ មកពីវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនស្រែតានុងកើត។ ខ្ញុំពិតជាមានអារម្មណ៍រំភើបនៅពេលដែលបានមកទស្សនកិច្ចសិក្សា និងចូលរួមវេទិកាស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ព្រោះនៅខាងសាលាវិទ្យាល័យស្រែតានុងកើតពុំធ្លាប់ដែលបានចូលរួមពីមុនមកទេ។ នៅពេលដែលខ្ញុំចូលមកដល់កន្លែងពិព័រណ៌ខ្ញុំឃើញថាមានការរៀបចំបានស្អាត ហើយមានទាំងផ្ទាំងគំនូរនៃការធ្វើដំណើរឆ្ពោះទៅកាន់ប្រទេសវៀតណាមដើម្បីស្នើសុំជំនួយក្នុងការរៀបចំបង្កើតកងកម្លាំងប្រដាប់អាវុធសង្គ្រោះជាតិកម្ពុជាដើម្បីរំដោះប្រទេស និងប្រជាជនកម្ពុជាចេញពីរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីបានស្តាប់ការពន្យល់ណែនាំរបស់លោកគ្រូ ឡុង ដានី រួចមកខ្ញុំទទួលបានចំណេះដឹងច្រើនជាងមុនទាំងវិធីទប់ស្កាត់ និងផលប៉ះពាល់ពីរបបប្រល័យពូជសាសន៍។

ខ្ញុំបាទឈ្មោះ គុណ ជិនប៉ាវ ភេទប្រុស មានអាយុ១៩ឆ្នាំ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន លាដលើ។ នៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្មខ្ញុំឃើញមានការរៀបចំបានស្អាតអំពីរូបថតជនរងគ្រោះខ្មែរក្រហម រូបភាពបន្ទាប់ពីរំដោះឆ្នាំ១៩៧៩ រួចផ្ទាំងគំនូរដែនទីរណ្តៅសាកសពជាច្រើនកន្លែងដែលលោក ឡុង ដានី ប្រធានមជ្ឈមណ្ឌលឯកសារកោះថ្ម បានពន្យល់ណែនាំអំពីរូបភាព ផ្ទាំងគំនូរដែលមាននៅក្នុងនោះ។

ក្រោយពីបានមកទស្សនកិច្ច និងចូលរួមវេទិកានៅទីនេះរួចមក ខ្ញុំទទួលបាននូវចំណេះដឹងថ្មីៗជាច្រើនដែលខ្មែរក្រហមបានធ្វើបាបប្រជាជនឲ្យធ្វើការលើសពី១២ម៉ោង នៅក្នុងមួយថ្ងៃ បំបែកបំបាក់គ្រួសារមិនឲ្យរស់នៅជួបជុំគ្នា ក្មេងដែលមានអាយុចាប់ពី១៥ទៅ១៦ឆ្នាំ ឡើងត្រូវធ្វើជាកងចល័តយោធា ហើយចំពោះកុមារក៏ត្រូវធ្វើការដូចគ្នា។ ស្រូវដែលប្រជាជនធ្វើបានយកទៅលក់ឲ្យបរទេស ហើយប្រជាជនត្រូវបរិភោគអាហារមិនគ្រប់គ្រាន់។ ខ្ញុំនឹងខិតខំរៀនសូត្រ ហើយចែករំលែកអ្វីដែលខ្ញុំទទួលបានទៅដល់ក្មេងៗជំនាន់ក្រោយដែលគាត់ពុំសូវបានរៀនសូត្រអំពីប្រវត្តិសាស្ត្រឲ្យគាត់បានដឹងអំពីផលវិបាក និងវិធីទប់ស្កាត់នៃរបបប្រល័យពូជសាសន៍។

# យុវនារីវ័យក្មេង រួមចំណែកដល់ការប្រារព្ធសិទ្ធិនារី ៨ មីនា

## តាមរយៈការរំឭកឡើងវិញពីបទពិសោធន៍ជីដូនរបស់ខ្លួនឆ្លងកាត់របបខ្មែរក្រហម

ថុន ស្រីពេជ្រ



យុវតី២១នាក់ ក្នុងចំណោមក្មេងៗជំនាន់ក្រោយ ៣៨ នាក់ មកពីវិទ្យាល័យអង្គសរ ស្រុកមេសាង ខេត្តព្រៃវែង ចូលរួមក្នុងកម្មវិធីវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម ក្រោមការរៀបចំពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យុវតី២១នាក់ ក្នុងចំណោមក្មេងៗជំនាន់ក្រោយ ៣៨ នាក់ មកពីវិទ្យាល័យអង្គសរ ស្រុកមេសាង ខេត្តព្រៃវែង បានចំណាយពេលវេលា ឈប់សម្រាកពីការរៀនសូត្ររបស់ខ្លួនក្នុងថ្ងៃទិវាសិទ្ធិនារីអន្តរជាតិ៨មីនា មកចូលរួមក្នុងកម្មវិធីវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម ក្រោមការរៀបចំពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅក្នុងការិយាល័យរបស់ខ្លួន នៅក្នុងទីរួមខេត្តព្រៃវែង។

វេទិកានេះ មិនត្រឹមតែផ្តល់នូវចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តោតជាសំខាន់លើការពិភាក្សាពីប្រធានបទ «ទារុណកម្មលើស្ត្រីក្រោមរបបខ្មែរក្រហម» ដែលជា

ប្រធានបទផ្ទះបញ្ចាំងពី៖ ១) ការរំលោភសិទ្ធិស្ត្រី និងការធ្វើទុក្ខបុកម្នេញទៅលើស្ត្រីក្នុងរបបខ្មែរក្រហម, ២) ការរំពុក និងការផ្សព្វផ្សាភ្ជាប់ទំនាក់ទំនងរវាងជីដូន និងចៅៗអំពីរឿងរ៉ាវលំបាកៗក្នុងរបបខ្មែរក្រហម, និង ៣) បណ្ដុះនូវអារម្មណ៍អាណិតអាសូរពីសំណាក់យុវជនជំនាន់ក្រោយ ចំពោះជីដូនរបស់ខ្លួនដែលធ្លាប់ទទួលរងដោយផ្ទាល់ពីបទពិសោធន៍ជូរចត់ក្នុងអតីតកាល។

ជាការចាប់ផ្ដើមវេទិកា លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកយកជំពូកមួយនៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺជំពូកទី ២ ៖ «តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?» មកបកស្រាយប្រាប់ដល់យុវជនទាំងអស់ ក្នុងគោលបំណងបង្ហាញពីឫសគល់នៃការបំបិទសិទ្ធិសេរីភាពរបស់ស្ត្រី និងប្រជាជនទាំងអស់ក្នុងរបបខ្មែរក្រហម និងកាលៈទេសៈដែលនាំឲ្យកើតមានសង្គ្រាមនៅតាមមូលដ្ឋាន ការរងទុក្ខលំបាកដោយសារសង្គ្រាម ការបាត់បង់សិទ្ធិរស់នៅ និងសិទ្ធិប្រកបរបរចិញ្ចឹមជីវិត និងការកើតមានរបបខ្មែរក្រហមដែលមនុស្សជាតិទាំងអស់ពុំទទួលបានសិទ្ធិអ្វីទាំងអស់រួមទាំងសិទ្ធិរស់រានមានជីវិត សិទ្ធិដើរហើរ សិទ្ធិទទួលបានអាហារហូបចុកគ្រប់គ្រាន់ សិទ្ធិថែទាំសុខភាព សិទ្ធិគោរពជំនឿសាសនា សិទ្ធិទទួលបានការអប់រំ និងសិទ្ធិជ្រើសរើសគូស្រករ។

បន្ទាប់ពីការធ្វើបទបង្ហាញ និងសំណួរ-ចម្លើយរួចមក វេទិកាបានផ្ដោតលើការពិភាក្សាពីរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហម ដែលជាបទពិសោធន៍កើតមានផ្ទាល់លើគ្រួសាររបស់យុវជនម្នាក់ៗ ជាពិសេស រឿងរ៉ាវជីវិតរបស់ជីដូនចាស់ៗ។ សំណួរពីរត្រូវបានសួរទៅកាន់ក្រុមយុវជនគឺ៖ ១) តើខ្មែរក្រហមបានប្រើឲ្យលោកយាយរបស់ប្អូនធ្វើការងារអ្វីខ្លះ? និង ២) តើលោកយាយរបស់ប្អូនធ្លាប់ត្រូវខ្មែរក្រហមវាយធ្វើបាបដែរឬទេ? ប្រសិនជាធ្លាប់ តើការវាយធ្វើបាបនោះបណ្ដាលមកពីអ្វី? សំណួរទាំងពីរនេះ រំលេចពីភាពជាអ្នកដឹកនាំរបស់ខ្មែរក្រហម ដែលមិនបានឲ្យតម្លៃចំពោះស្ត្រី និងការមិនអើពើដល់ទុក្ខលំបាករបស់ស្ត្រី។ ខាងក្រោមនេះ ជាការឆ្លើយតបរបស់យុវជនចំពោះសំណួរទាំងពីរ៖



យុវតី២១នាក់ ក្នុងចំណោមក្មេងៗជំនាន់ក្រោយ៣៨នាក់ មកពីវិទ្យាល័យអន្លង់សរ ស្រុកមេសាង ខេត្តព្រៃវែង ចូលរួមក្នុងកម្មវិធីវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម ក្រោមការរៀបចំពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បាន សុឃីម រៀននៅថ្នាក់ទី១២D៖ លោកយាយខ្ញុំត្រូវខ្មែរក្រហមប្រើឲ្យធ្វើការងារធ្ងន់ៗជាច្រើន ដូចជា៖ ជីកប្រឡាយ ជីកព្រែក រែកដី ធ្វើស្រែប្រាំង ដើររើសអាចម៍គោ និងលាមកមនុស្ស។ លោកយាយធ្លាប់ខ្មែរក្រហមធ្វើបាប និងបង្អត់បាយលោកយាយ។ ខ្មែរក្រហមធ្វើបាបលោកយាយដោយឲ្យប្រូតស្រូវចំនួន១២ម៉ោង ព្រោះលោកយាយបានលួចកាស់ដំឡូងស្វាហូប។

វ៉ាន់ ចាន់រ៉ុង រៀននៅថ្នាក់ទី១២D៖ លោកយាយខ្ញុំប្រាប់ថា កាលនោះកម្មាភិបាលខ្មែរក្រហមប្រើឲ្យគាត់ធ្វើស្រែ ជីកស្រះ ជីកប្រឡាយ ធ្វើផ្លូវថ្នល់ លើកប្រព័ន្ធភ្លឺស្រែ លើករបស់ធ្ងន់ៗ ធ្វើពលកម្មលើសកម្លាំង និងធ្វើការលើសពី១២ម៉ោងក្នុងមួយថ្ងៃ។ លោកយាយខ្ញុំហូបចុកមិនបានគ្រប់គ្រាន់បណ្ដាលឲ្យវិលមុខខ្យល់គ និងធ្វើឲ្យគាត់គ្មានកម្លាំងធ្វើការងារ។

ចយ ស្រីម៉ៅ រៀននៅថ្នាក់ទី១២C៖ លោកយាយខ្ញុំប្រាប់ខ្ញុំថា គាត់ធ្វើការងារដូចជា ប្រូតស្រូវ ជីកព្រែក



យុវតី២១នាក់ ក្នុងចំណោមក្មេងៗជំនាន់ក្រោយ៣៨នាក់ មកពីវិទ្យាល័យអង្គសរ ស្រុកមេសាង ខេត្តព្រៃវែង ចូលរួមក្នុងកម្មវិធីវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម ក្រោមការរៀបចំពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជីកប្រឡាយ រើសអាចម៍គោ រែកដី មើលក្មេងៗ និងបុកស្រូវ។ ខ្មែរក្រហមធ្លាប់ធ្វើបាបលោកយាយព្រោះលោកយាយបានធ្វើខុសគោលការណ៍របស់អង្គការ។ គាត់បានលួចអាហារមកបរិភោគ ដូចជា ដំឡូង ពោតមាន់ និងលួចដាំបាយ ហូប។

ហៀម ស្រីលីស រៀននៅថ្នាក់ទី១២D ៖ លោកយាយធ្វើការងារធ្ងន់ដូចជា ជីកព្រែក ជីកស្រះ ទប់ភ្លឺស្រែ រែកដីធ្វើផ្លូវថ្នល់ និងប្រើឲ្យធ្វើការងារគ្មានពេលសម្រាកដោយមិនកំណត់ម៉ោងការងារឡើយ។ ខ្មែរក្រហមហៅយាយឲ្យទៅធ្វើការពេលណា គឺគាត់ត្រូវទៅពេលនោះ។ ខ្មែរក្រហមបានបង្ខំឲ្យលោកយាយខ្ញុំធ្វើការ ទាំងលោកយាយកំពុងពពោះអ៊ំប្រុស។ ពេលសម្រាលកូនហើយ លោកយាយក៏នៅតែលំបាក។ អង្គការចោទថាលោកយាយខ្ជិលច្រអូស ប៉ុន្តែលោកយាយពិតជាឈឺវិលមុខអស់កម្លាំងមែន។

ខែម ស្រីពៅ រៀននៅថ្នាក់ទី១២ C ៖ លោកយាយខ្ញុំធ្វើស្រែ ជីកប្រឡាយ រែកដី បុកស្រូវ កាប់កូនឈើ មើលក្មេងតូចៗ និងដើររើសអាចម៍គោធ្វើជី។ លោកយាយត្រូវបានអង្គការបង្អត់អាហារ ព្រោះលោកយាយលួចគាស់ដំឡូងហូបម្នាក់ឯង និងលួចធ្វើមាន់ហូប។ លោកយាយបានបន្ថែមថា ដោយសារតែទទួលបានរបបអាហារតិចតួច ហើយគ្មានកម្លាំងក្នុងការធ្វើការងារទើបគាត់ដាច់ចិត្តលួចហូប។

រឿន សុនីតា រៀននៅថ្នាក់ទី១២ B ៖ លោកយាយខ្ញុំបានធ្វើការងារ ដូចជា ជីកប្រឡាយ ជីកស្រះ ជីកព្រែក ទប់ភ្លឺស្រែ ដកស្ទូង ធ្វើផ្លូវថ្នល់ និងការងារជាច្រើនទៀតដែលអង្គការប្រើឲ្យធ្វើ។ លោកយាយឈឺអស់កម្លាំង ទៅធ្វើការមិនរួច អង្គការបានចោទយាយថា គឺជាមនុស្សខ្ជិលច្រអូស គេចវេសពីការងារ។



យុវតី២១នាក់ ក្នុងចំណោមក្មេងៗជំនាន់ក្រោយ៣៨នាក់ មកពីវិទ្យាល័យអង្គសរ ស្រុកមេសាង ខេត្តព្រៃវែង ចូលរួមក្នុងកម្មវិធីវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម ក្រោមការរៀបចំពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ទួលពិឃាដ» (ត)

# ១១. ទំព័រជីវិតទី២លើទឹកដីចាស់ (ត)

## វិប្បដិសារីច្រំដែល (ត)

...តាមផ្លូវខ្ញុំមើលទៅមុខបងប្រុស បងស្រីប្អូនអារម្មណ៍ក្រៀមក្រំសោកស្តាយនៃវិប្បដិសារីដេរស្តីគ្មានពេលល្ហែ ថាសង្ឃឹមនឹងជីវិតថ្មីរីកស្រស់បំព្រងតែអ្វីៗប្រែប្រួលមិនដូចបំណងដែលចិត្តខំប៉ងក្នុងការរស់នៅសុខដុមក្នុងគ្រួសារកំព្រាក្មេងខ្ចីៗ នឹកអាណិតដល់ក្រុមគ្រួសារជួបតែការភ័យខ្លាចធ្វើឲ្យបងប្អូនបីនាក់ហាយំលែងចេញដូចជាតំណក់ភ្លៀងធ្លាក់មិនដាច់សោះមកលើយើងៗ

យើងទាំងអស់គ្នាបានដើរមកដល់ផ្ទះ តែមិនបាននិយាយរ៉ាប់រឿងនេះប្រាប់យាយទេរួចក៏នាំគ្នាហូបនំអន្សមទំពាក្នុងក្តីស្រមៃឥតព្រំដែនដែលកើតឡើងក្នុងថ្ងៃចូលឆ្នាំដំបូង គួរតែទទួលបាននូវសព្ទសាធុការពរ សិរីសួស្តីពីទេវតាឆ្នាំថ្មីៗ

តែណើយ យើងបំភ្លេចវាចុះ ចាត់ទុកថា គ្រោះកម្មកំណាចទាំងឡាយវានឹងរសាត់អណ្តែតបាត់អស់ពីវង្វង់គ្រួសារយើងចុះ ហើយសង្ឃឹមនឹងជីវិតថ្មី ដែលមានពន្លឺឆព្វណ្ណរង្សីដ៏ត្រចះត្រចង់ ដោយមានការតាមថែរក្សាពីព្រលឹងឪពុកម្តាយ គ្រូបាធ្យាយ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកចំពោះគ្រួសារបរិសុទ្ធមួយនេះឲ្យក្តៅថ្កើនផុតទុក្ខភ័យៗ នេះជាការញញឹមសង្ឃឹមដើម្បីលើកកម្លាំងចិត្តសើចចំអកខ្លួនឯងប៉ុណ្ណោះៗ

តែអ្វីៗនៅតែមានការសោកស្តាយចេញពីបេះដូងចំពោះបងប្អូនបីនាក់ ដែលបានប្រាស់ចាកពីទុក្ខកង្វល់ ហើយមិនគួរមកជួបវិញ តែមួយប៉ប្រិចភ្នែកធ្វើឲ្យលស់ព្រលឹងដែលគ្រប់គ្នានឹកស្មានមិនដល់ៗ



ទិដ្ឋភាពៈ បងណាតត្រូវទាហានវៀតណាមចាប់ទៅ ដោយចោទថា ប៉ុល ពត ហើយធំតែម និងបងស្រីនិយាយអង្វរដល់កងទ័ពវៀតណាម ទាំងនោះថាមិនមែនពួកប៉ុល ពតទេៗ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

# ១២. លាភូមិកំណើតលុះអវសានជាតិ

សំណាល់ទិព្បដិសារី

ប្អូនដប់ថ្ងៃកន្លងទៅ។ ពេលព្រឹកព្រលឹមស្រាងៗបន្ទាប់ពីខ្ញុំនិងប្អូនរ៉ាយកបាយកកដែលសម្បូរដោយផ្កាស្មៅនិងស្រូវមួយៗសល់ពីការបុក និងរើសមិនអស់មកដាក់ក្នុងមាត់ទំពាម្នាក់មួយដុំជាមួយល្ហុងត្រាំ។

ពេលនោះយាយនិយាយមកកាន់ខ្ញុំថា "ចៅវង្ស ចៅរ៉ា ចៅឯងទៅលេងតារបស់ចៅឯងផងទៅ នៅផ្ទះអ៊ីទូច នៅឯភូមិព្រៃក្រឡាញ់តូច គាត់បានផ្តាំថាបើមិនឃើញគាត់ត្រលប់មកវិញទេ ឲ្យចៅៗទៅលេងគាត់ផង។"

តាបានចាកចេញពីភូមិក្រាំងតាំងព្រលឹមស្រាងៗ ថ្ងៃចូលឆ្នាំខ្មែរមុនកងទ័ពវៀតណាមចូលមកក្នុងភូមិ។ ដោយគាត់មានការនឹករលឹកកូនស្រីគាត់ គឺអ៊ីទូច ដែលត្រូវជាបងស្រីម្តាយខ្ញុំបង្កើត បន្ទាប់មកយាយបន្ថែមថា"ទៅៗចៅ ទាំងពីរនាក់ អ៊ីទូចក៏នឹកចៅឯងដែរ"។ មិនយូរប៉ុន្មានខ្ញុំទាញក្រមាមកចងចង្កេះលើខោខ្លី ក្រណាត់តេតារ៉ុងពណ៌ខៀវ ចង្កេះកៅស៊ូកងដែលបងស្រីទើបនឹងដូរស្រូវបណ្តាក់ជំពាក់ ពេលប្រមូលផលស្រូវទើបសងគេវិញ ឲ្យប្អូនម្នាក់មួយស្លៀកយ៉ាងហ៊ឺហា។

ខ្ញុំពីរនាក់ប្អូនដើរកាន់ដៃគ្នាចេញពីភូមិក្រាំង ដើរតាមទំនប់បឹងឆ្លងកាត់ភូមិជ្រៃ។ ចេញពីភូមិជ្រៃ មិនហ៊ានដើរតាមទំនប់ឆ្លងកាត់ទួលកុកក្រូចទេ ព្រោះទួលនោះសម្បូរផ្នូរខ្មោចហើយពួកគេថាខ្មោចលងទៀតផង។ រួចក៏ដើរវាងតាមស្រែឆ្ពោះទៅទិសខាងលិច ដែលសម្បូរទៅដោយជព្រាំងនិងទឹកដក់ ដែលមានភ្លៀងម្តងមួយកាលនៅដើមរដូវវស្សា។

ខ្ញុំលួចមើលក្រោយទៅរកទួលកុកក្រូចម្តងៗដូចជាមានអារម្មណ៍ខ្លាច។ ដើរឆ្ងាយពីទួលនោះឆ្ងាយទៅៗ យើងបានឆ្លងកាត់វាលពោធិ៍ចង្ក្រាន។ ខ្ញុំមើលឃើញភូមិព្រៃក្រឡាញ់តូចជិតដល់ដែរ។ មិនយូរប៉ុន្មានខ្ញុំពីរនាក់ប្អូនចូលទៅក្នុងភូមិសំដៅទៅផ្ទះអ៊ីទូច។ ខ្ញុំឈរវេរារួចសួរទៅប្អូនថា៖

"ប្អូនមានចាំផ្ទះអ៊ីទូចនៅកន្លែងណាទេ?" ប្អូនឆ្លើយថា៖

"បង! ខ្ញុំដូចជាភ្លេចដែរ។ តែខ្ញុំខំរកនឹកកាលពីគេជម្លៀសគ្រួសារយើងមករស់នៅភូមិព្រៃក្រឡាញ់ធំ"។ ខ្ញុំធ្លាប់មកមើលកុនឯកសារដែលកម្មាភិបាលខ្មែរក្រហមបញ្ចាំងឲ្យប្រជាជនមើលពីស្នាដៃលើកទំនប់ ជីកប្រឡាយ ធ្វើស្រែ ភ្ជួររាស់ ដកស្ទូង ច្រូតកាត់យ៉ាងសកម្ម ដើម្បីបង្ហាញពីភាពជឿនលឿនមហាលោតផ្លោះ មហាអស្ចារ្យ រុះសាលាធ្វើរោងបាយ វាយព្រះវិហារយកថ្មទប់ទន្លេដែលគេគិតថាជាបច្ចេកវិទ្យាដ៏ទំនើប ដែលកើតឡើងតាមផ្នត់គំនិតឆ្កួតៗរបស់គេនោះ។

ពេលនោះខ្ញុំនឹកឃើញផ្លូវចូលផ្ទះគាត់ មានដើមខ្វិតក្រសាំងមួយដើម ព្រោះកាលនោះខ្ញុំនៅចាំពេលខ្ញុំមកមើលកុន ហើយឆៀងមកលេងគាត់ គឺគាត់ពិតជាមានចិត្តអាណិតអាសូរក្មួយណាស់ដែលមានរូបរាងស្គមស្គាំងគួរឲ្យអាណិតខ្លោចចិត្ត។ គាត់ប្រាប់ថាក្មួយចាំមួយភ្លែត រួចគាត់ដើរទៅក្រោយផ្ទះយកដើមបុស្សីពីងពង់មកបេះផ្លែខ្វិតឲ្យខ្ញុំមួយ ដោយនិយាយថា "ក្មួយទុកហូបនៅពេលមើលកុនណា"។

បន្ទាប់មក ខ្ញុំដឹកដៃប្អូនដើរតាមផ្លូវរកដើមខ្វិត មិនយូរប៉ុន្មានខ្ញុំងើយទៅលើឃើញដើមខ្វិតដែលជ្រុះស្លឹកអស់ ហើយមានផ្លូវអែបនឹងដើមខ្វិត ខ្ញុំប្រាប់ថា តស់ចូលតាមផ្លូវនេះទៅ គឺឃើញផ្ទះអ៊ីហើយ។

ដើរបានដប់ម្ភៃជំហាន ខ្ញុំឃើញ

ផ្ទះអ៊ីដែលចាំយ៉ាងច្បាស់ គឺរោងបាយជំនាន់ខ្មែរក្រហម ដែលគេរុះសាលារៀនមកធ្វើ។ រោងបាយនេះវែងនៅពេលរបបខ្មែរក្រហមដួលរលំដោយកងទ័ពវៀតណាម គេឲ្យប្រជាជនខ្លះដែលគ្មានផ្ទះសំបែងនៅមួយចំហៀង។

រំពេចនោះខ្ញុំឃើញតាកំពុងតែឈរបោសសំរាមនឹងអំបោសដើមកន្តាំងបាយស។ ខ្ញុំនិយាយទៅកាន់គាត់ថា តា។ គាត់ងាកមើលខ្ញុំស្រឡាំងកាំង យកដៃញីភ្នែក រួចស្ទុះមកឱបខ្ញុំជាមួយសំណួរសួរនាំ៖ "យីចៅមកពីអង្កាល់ហ្នឹង?"

"ខ្ញុំមកដល់មិញហ្នឹងជាមួយប្អូនវ៉ា" ខ្ញុំតបទៅគាត់ គាត់បានដឹកដៃខ្ញុំទាំងពីរអ្នកទៅក្រោយផ្ទះ ហើយស្រែកថា៖

"នែមីងទូចៗ ចៅវង្ស ចៅវ៉ាមកលេង" ពេលនោះខ្ញុំក្រឡេកឃើញអ៊ីកំពុងតែដាក់បាយជ្រូកនៅទ្រុងក្រោយផ្ទះ។ អ៊ីទូច ស្ទុះមកឱបខ្ញុំ និងប្អូនវ៉ាដោយពោលលាយឡំទឹកភ្នែកថា ពីណាជូនមក ខ្ញុំឆ្លើយថា ខ្ញុំដើរមកតែពីរនាក់ទេ។ អ៊ីគាត់យកដៃជូតទឹកភ្នែកដោយអាណិតក្មួយកំព្រាទាំងពីរ។

ខ្ញុំស្ងួតអារម្មណ៍ដោយឃើញកាយវិការអ៊ី ធ្វើឲ្យខ្ញុំក្តុកក្តួលអួលដើមកន្ទួលចុងច្រមុះ ហូរទឹកភ្នែកចេញមកមិនដឹងខ្លួន ព្រោះរូបរាង អ៊ីមើលទៅដូចជាម្តាយខ្ញុំ ធ្វើឲ្យខ្ញុំនឹករលឹកឃើញម្តាយមួយរំពេច។ តានិងអ៊ីបានសួរខ្ញុំថា "តើយាយក្មួយចិន្តាក្មួយណាតសុខសប្បាយទេ?" ខ្ញុំឆ្លើយថា "សុខសប្បាយទាំងអស់គ្នាទេ"។ ហើយយាយបានប្រាប់ខ្ញុំនិងប្អូនឲ្យខសង្រាហ៍មកលេងតា និងអ៊ីផង។

ការងារដែលគាត់ទាំងពីរកំពុងធ្វើបានបោះបោលទាំងអស់។ ជ្រូកដែលគាត់បម្រុងផ្តល់ចំណីកំពុងតែស្រែកចេញពីទ្រុងទាររកបាយ តែគាត់មិនខ្វីរវល់ ដោយងាកមកឱបខ្ញុំនិងប្អូនមានទឹកភ្នែករលីងរលោង មើលទៅគាត់ដូចជានឹកប្អូនស្រីបង្កើតរបស់គាត់ណាស់។ នៅពេលគាត់ឃើញខ្ញុំទាំងពីរ តាក៏មានទឹកភ្នែករលីងរលោងដែរ ហើយគាត់ពោលទៅអ៊ីថា "នែកូនទៅដាំបាយធ្វើម្ហូបឲ្យក្មួយហូប និងធ្វើបង្អែមខ្លះផ្ញើទៅយាយវ៉ា និងក្មួយចិន្តា ក្មួយណាតផង។

ពេលនោះខ្ញុំឃើញអ៊ីគាត់ទៅបេះស្លឹកបាស់ ស្លឹកគ្រៃ និងស្លឹកងប់មកធ្វើសម្ល អំឡុងពេលនោះ តាគាត់នៅតែអង្អែលក្បាលខ្ញុំនិងប្អូនក្នុងក្តីអាណិត ចៅកំព្រា ដែលមិនអាចបំភ្លេចបានក្នុងជម្រៅចិត្តរបស់គាត់។

"នែក្មួយៗមកញាំបាយសិនទៅម្ហូបឆ្អិនហើយ។" អ៊ីស្រែកប្រាប់ពីក្រោយ រួចតាពោលបន្ថែម "តស់ចៅមកហូបបាយ អ៊ីឯងស្លឆ្អិនហើយ"។

ខ្ញុំគោងដៃតាមកកាន់គ្រែដែលមានម្ហូបគាត់រៀបចំជាស្រេចនៅលើស្តុក មានសម្លប្រហើរស្លឹកបាស់ ស្លឹកងប់ និងកូនត្រីកញ្ចុះដែលគាត់ទើបតែយកអង្ករដូរពីព្រឹកមិញនេះ។ អ៊ីដួសបាយឲ្យខ្ញុំហើយពោលថា ក្មួយទាំងពីរហូបឲ្យឆ្អែតចុះ។ ខ្ញុំលួចសម្លឹងមើលទៅតា និងអ៊ី គាត់មិនហូបបាយទេ ដោយអង្គុយមើលកាយវិការចៅនិងក្មួយ។

ខ្ញុំទំពាបាយដែលមានទឹកភ្នែកហូរមក ក្នុងចិត្តពិតជានឹកស្រណោះខ្លួន ក្រោមទម្ងន់នឹករលឹកពីតានិងអ៊ីប្រៀបបានទៅនឹងសត្វលលក ដែលត្រូវព្រានប្រមាញ់ឲ្យស្លាប់តែម្នាងនៅកណ្តោចកណ្តែងឯកាក្នុងវាលវដ្តសង្សារនេះ។

ពេលតាសម្លឹងមើលចៅក្នុងក្តីសង្វេគឥតឧបមាហើយ ក៏ពោលថា "នែកូនទូច កូនធ្វើបង្អែមនំគូរ ឬបាយដំណើបផ្ញើម្តាយឯង និង ក្មួយចិន្តា ក្មួយណាតផង។" មិនបង្អង់យូរ អ៊ីគាត់ស្ទុះទៅរៀបចំធ្វើបង្អែមដែលតាបានប្រាប់។

ទោះជាយ៉ាងណា តានៅតែអង្គុយជជែកនិយាយលេងជាមួយខ្ញុំនិងប្អូន នូវភាពសោកសៅដែលកន្លងទៅ។ ខ្ញុំមើលទៅគាត់មានទឹកមុខស្រពោនបន្តប់ទៅដោយរយលានអាល័យ នឹកស្រណោះកូនស្រីពៅរបស់គាត់។

ពេលនោះអ៊ីគាត់រៀបចំបង្អែមនំគូ និងបាយដំណើបដាក់ក្នុងស្រាក់ពីរ ហើយមានស្ករត្នោតដាក់ក្នុងស្តុក រួចហុចឲ្យខ្ញុំ"នេះនែរបស់នេះ ក្មួយយកទៅឲ្យយាយ ក្មួយចិន្តា និងក្មួយណាតហូបចុះ"។

តាមិនចង់ឲ្យខ្ញុំនិងប្អូនចេញពីរូបគាត់ទេ គាត់យកដៃមកអង្អែលក្បាលចៅទាំងពីរហើយពោលថា "តើចៅដឹងទេក្រោយពីពួកខ្មែរក្រហមយកឪពុកម្តាយ និងប្អូនពៅភ្លោះរបស់ឯងទៅសម្លាប់នៅទួលស្លាំង។ តាមានការសោកស្តាយ និងអាណិតពួកគេខ្លាំងណាស់ ចាប់តាំងពីពេលនោះមក តាមិនដែលដេកលក់ទេ។ យប់ណាក៏ដូចយប់ណាដែរ តែងតែយកដៃគេងគងថ្ងាស ពិតជាវេទនាក្នុងចិត្តណាស់ នឹកស្រណោះកូនស្រីពៅដែលជាម្តាយរបស់ឯង។ ដូច្នេះហើយបានជាតាមកនៅជាមួយអ៊ីឯងដើម្បីបំភ្លេចទុក្ខ"។

គាត់បន្តថា ចាស់ៗក្នុងភូមិក្រាំងជំនាន់គាត់ស្រលាញ់គ្នាណាស់ តាតែងតែបំផុសអ្នកស្រុកឲ្យជួយលើក

ទំនប់ បឹង ធ្វើជាផ្លូវ និងដាំដើមឈើអមសងខាងផ្លូវ គ្រាន់បានអ្នកភូមិដើរឆ្លងកាត់ពីភូមិជ្រៃមកភូមិក្រាំងៗ មិនតែប៉ុណ្ណោះ តាក៏បានចំណាយប្រាក់កាក់ខ្វះក្នុងការសង់សាលាឆទាននៅលើទំនប់បឹងទុកគ្រាន់អ្នកស្រុកធ្វើដំណើរហត់នឿយហើយឈប់សម្រាកនៅទីនោះ និងមានពាងតូចមួយផងដាក់ទឹកសម្រាប់ផឹកពេលស្រេកៗ ចុះហេតុអ្វីពួកគេមិនមានក្ដីអាណិតដល់គ្រួសារតា ដែលបន្សល់ទុកស្នាដៃជាច្រើនដូច្នេះៗ

ពេលនោះតានិយាយដូចជាមានកំហឹងក្នុងខ្លួន គាត់បានចុះពីលើគ្រែហើយបែរទៅក្រោយផ្ទះយកដៃជូតទឹកភ្នែក និងពោលបន្តទាំងអួលដើមក "ចៅដឹងទេគូប៉ៅដែលជាបងរបស់ម៉ែឯង ពេលគេជម្លៀសពីក្រុងភ្នំពេញមកនៅភូមិក្រាំងនេះមិនបានប៉ុន្មានថ្ងៃផង ឈ្មោះ ខុន ដែលជាមេកងឈ្លបភូមិមកប្រាប់គូប៉ៅឯងថា ថ្នាក់លើឲ្យអ្នក១៧ មេសា ទៅរៀនសូត្រនៅសាលាកូលេស ស្ពាយពលដែលប្រពន្ធកូនខ្ញុំទើបតែឆ្លងទន្លេបាន ២០ថ្ងៃប៉ុណ្ណោះ ពេលនោះដែរខុនបានបណ្ដើរគូឯងចេញពីផ្ទះរហូតដល់ផុតភូមិត្រូវកម្មាភិបាលចាប់ចងស្ពាបសេកបណ្ដើរ ទៅស្រុកពារាំង ក្រោយមកឮដំណឹងថា ពួកគេសម្លាប់ចោលមកដល់សព្វថ្ងៃនេះរកសពមិនឃើញផងៗ ទុកឲ្យប្រពន្ធមេម៉ាយមើលកូនៗមួយសំបុកធំ វាជាសម្រែកការឈឺចាប់ដែរលដិតដាមក្នុងជីវិតតាគ្មានថ្ងៃរលត់ទោះជាស្លាប់ក៏បិទភ្នែកមិនជិតដែរពីទុក្ខកង្វល់ដែលបន្សល់យកទៅជាមួយតាមព្រលឹងៗ

# សម្រែកបណ្ដាំចុកឈាម



ទិដ្ឋភាព៖ តាចង្អុលទៅភូមិក្រាំង ភូមិកំណើតជីវិត ហើយបានផ្ដាំថា គាត់មិនត្រឡប់ទៅរស់នៅក្នុងភូមិនោះវិញទេៗ (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

តាពិតជាឈឺចាប់ណាស់ បន្ទាប់មកគាត់ងាកមករកខ្ញុំនូវសំឡេងខ្លាំងៗ យំអណ្ដឹតអណ្ដក ពេលចៅទៅវិញប្រាប់យាយឯង និងចៅចិន្ដា ចៅណាតថា តាមិនត្រលប់ទៅរស់នៅភូមិក្រាំងវិញទេៗ ភ្លាមនោះគាត់និយាយទៅកាន់អ៊ីថា នែមីទូចកូន! កូនត្រូវចាំថា ពេលពុកស្លាប់ទៅមិនត្រូវយក ពុកទៅបញ្ចុះបុប្ផជា នៅលើ ទឹកដីភូមិក្រាំងជាដាច់ខាតៗ

គាត់ដូចជាមានកំហឹងក្ដៅគគុកនិយាយខ្លាំងៗ បែរមុខទៅទិសខាងជើង ហើយលើកដៃចង្អុលទៅភូមិក្រាំងជាមួយក្រសែភ្នែក ឡើងក្រហម និងទឹកភ្នែកហូរមករហាមៗ កូន និងចៅ ចាប់ពីពេលនេះទៅ សូមកុំឲ្យពុក និងតាឮឈ្មោះភូមិនេះអី វាពិតជាធ្វើឲ្យតាមានវិប្បដិសារីរហូតដល់ថ្ងៃរលត់ជីវិតៗ ព្រោះតាបានបាត់បង់កូន និងចៅស្ទើរកន្ទះពូជៗ

ពេលនោះខ្ញុំមើលទៅអ៊ីកំពុងអង្គុយត្របោមក្បាលជង្គង់ យកដាយសារុងមកជូតទឹកភ្នែកដោយស្រណោះពាក្យសម្ដីតាៗ

ទឹកភ្នែកខ្ញុំនៅតែហូរស្រក់លើរនាបគ្រែមិនដាច់ រួចគាត់ក៏ដើរទៅក្រោយផ្ទះ ទាញកាំបិតខ្វែវទៅជាមួយផងៗ អ៊ីគាត់សម្លឹងមើលមកក្មួយ ទាំងពីរពោរពេញទៅដោយទឹកមុខក្រៀមក្រំលាយ ឡំនឹងទឹកភ្នែកនឹកស្រណោះភព អន្ទការកន្លងទៅ ដែលដៅជាប់ដួងចិត្តមិនអាចបំភ្លេចបាននូវស្លាកស្នាមអនុស្សាវរីយ៍ឈឺចាប់នេះៗ

**ឡុង វង្សសមិទ្ធ**

**(តទៅលេខក្រោយ)**

រូបក្របមុខ៖

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត
មកទទួលសេវាពិនិត្យសុខភាពបឋម ដោយឥតគិតថ្លៃរៀបចំដោយក្រុមការងារគម្រោង " ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យ
ប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម"។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មកចូលវេទិកាអប់រំ អំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ
(១៩៧៥-៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 279, March 2023 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.